# ទ្វារដែលនាំទៅឯជីវិត

អរគុណ បងប្អូនប្រុសនេវីល(Neville)។ អរគុណ វាជាការល្អដែលត្រឡប់មកក្នុង ដំណាក់ព្រះអម្ចាស់។ ខ្ញុំតែងរីករាយដែលបានត្រឡប់មកវិញនៅរោងឧបោសថ មិន ថាខ្ញុំទៅទីណានោះឡើយ។ មានអ្វីមួយពីកន្លែងចាស់នេះ ដែលខ្ញុំចូលចិត្ត ត្រឡប់មកវិញ។វាគ្រាន់តែអូខ្ញុំ...វាជាក្រុមជំនុំដំបូងនិងតែមួយដែលខ្ញុំធ្លាប់ធ្វើជាគ្រូគង្វាល។ ហើយវាហាក់ដូចជាល្អណាស់ដែលបានត្រឡប់មកវិញម្តងទៀត។ ហើយខ្ញុំជឿថានៅព្រឹកអស្ចារ្យនោះពេលដែលព្រះអាទិត្យមិនបំភ្លឺ និងផ្កាយបានអស់ពន្លឺទៅ ខ្ញុំជឿថានឹងមានពន្លឺខ្លះចេញពី រោងឧបោសថដែលបំភ្លឺនៅថ្ងៃនោះ ដែលបានលាងដោយព្រះលោហិតនៃចៀម។ ខ្ញុំរងចាំសម្រាប់ពេលវេលានោះ។

2 ពេលខ្ញុំដើរកាត់តាមបន្ទប់មក ខ្ញុំជួបបងប្អូនស្រីអ័ហ្គានប្រាយ(Arganbright) នៅត្រង់នោះ។ នាងបានប្រាប់ខ្ញុំថាមានមនុស្ស នៅទីនេះ ដែលធ្លាប់ជាអ្នកប្រជុំគ្នានៅឃីងស្តុន (Kingston) ដែលធ្លាប់បានទៅទស្សនៈកិច្ច ហើយខ្ញុំ...គឺ...រីករាយដែលបានជួបពួកគេនៅទីនេះជាទីបន្ទាល់។ មិនថាពួកគេនៅឯណា បើសិនជាពួកគេនៅតែលើកដៃ គឺនៅការប្រជុំគ្នា នៅឃីនស្តុន (Kingston) ក្នុងចាម៉ៃកា(Jamaica)។ ត្រឹមតែ មែន ត្រឡប់ទៅវិញ។ ពិតណាស់ នោះគឺមិនអីទេ។

3 ខ្ញុំឃើញកាតអូរ៉ាល់(Oral)។ ខ្ញុំគិតថា អ្នកទទួលបានការប្រកាសការប្រជុំគ្នារបស់គាត់រួចហើយ។ ខ្ញុំមិនបានដឹងទេរហូតដល់ កាលបរិសច្ឆេទ កាលពីម្សិលមិញ។ ខ្ញុំគិតថាវានៅថ្ងៃទីប្រាំមួយ មិនចឹងឬ? ទីប្រាំមួយរហូតដល់ថ្ងៃទីដប់ប្រាំបងប្អូនប្រុសរ៉ូប៊ីត(Roberts) ក្នុងក្រុងល្វីសវីល(Louis ville)។ ឥឡូវ ទៅស្តាប់គាត់ចុះ។ បងប្អូនប្រុសRobertsគឺ—មិត្តរួមទ្រូងជាមួយខ្ញុំ និងជាអ្នកបម្រើពិតរបស់ព្រះគ្រីស្ទ។ ហើយខ្ញុំជឿជាក់ថាអ្នកនឹងរីករាយជាមួយសាររបស់គាត់ ពីមួយយប់ទៅមួយយប់។ និង...របស់គាត់។ ពេលគាត់អធិស្ឋានសម្រាប់អ្នកជំងឺខ្ញុំ—ខ្ញុំប្រាកដថាអ្នកនឹងឃើញព្រះធ្វើចលនា ព្រោះគាត់ជាអ្នកចម្បាំងដ៏ធំនៃជំនឿ បងប្អូនប្រុសRoberts ជាមនុស្សដែលព្រះប្រើយ៉ាងអស្ចារ្យ។ ហើយពន្ធកិច្ចរបស់គាត់ឡើង មកពី...

4 ខ្ញុំចាំ ថាពេលខ្ញុំជួបបងប្អូនប្រុស Roberts ដំបូង គាត់នៅក្នុងតង់ដាច់រហែកមួយនៅផ្លូវល្វីស(St.Louis)រដ្ឋមីសូរី(Missouri) ហើយខ្ញុំនៅ...ទេ ក្រុងកាន់សាស (Kansas), រដ្ឋមីសូរី(Missouri)។ ហើយខ្ញុំនៅក្រុង កានសាស(Kansas)កានសាស ក្នុងសវនដ្ឋានតន្ត្រី។ គាត់អង្គុយនៅជួរខាងមុខ។ បន្ទាប់ពីកម្មវិធីចប់ យើងទៅខាងក្រោយដើម្បីនិយាយ។ គេណែនាំខ្ញុំទៅកាន់គាត់។ គាត់មានវ័យក្មេងជាងខ្ញុំ អូរ៉ាល់(Oral)នៅក្នុងភ្នែកគាត់ប្រហែលសែសិបឆ្នាំ។ ហើយគាត់និយាយ "តើអ្នកគិតថាព្រះស្តាប់ខ្ញុំពេលអធិស្ឋានសម្រាប់អ្នកជំងឺ?"

ខ្ញុំនិយាយ "បងប្អូនប្រុស ទ្រង់នឹងឮគ្រប់អស់អ្នកអធិស្ឋានដែលនឹងអធិស្ឋាន" ល្អ គាត់ចាប់ផ្តើម និងគាត់និយាយ "ទីនេះ ខ្ញុំទៅ!"

5 ហើយគាត់ជាមនុស្សវ័យឆ្លាត និងទទួលការអប់រំកម្រិតមហាវិទ្យាល័យ បួនឆ្នាំផ្នែកចិត្តវិទ្យា និងខ្ញុំជឿជាក់ថាគាត់-គាត់ជាមនុស្សពូកែ។ ហើយគាត់បានចាប់ផ្តើមទៅកន្លែងឥឡូវដែលគាត់មានបុគ្គលិកនៃអ្នកប្រឹក្សាជុំវិញគាត់ និងអ្វីរហូតដល់ ពេលគាត់និយាយ គាត់—គិតចេញ។ ហើយអ្នកនឹងរីករាយជាមួយគាត់ ខ្ញុំជឿជាក់។

6 ដូច្នេះឥឡូវខ្ញុំចង់ធ្វើការរាយការណ៍បន្តិចពីអ្វី ដែលព្រះអម្ចាស់បានធ្វើក្នុងកម្មវិធី ការប្រជុំតូចរបស់យើងនៅចាមៃកានិងនៅក្នុងព្យែតូរីកូ(Puerto Rico)។ វាជារឿងចម្លែកដែលខ្ញុំបានឆ្លងកាត់ ព្រោះមនុស្សជាច្រើនត្រូវបានហៅមក។ ដូចលីអូ(Leo)នៅទីនេះបានដឹង ហើយទូរស័ព្ទ...និងដំណើរការពេញមួយសប្តាហ៍មានកន្លែងរាប់រយបានហៅសម្រាប់ការជួបជុំគ្នា។ ប៉ុន្តែខ្ញុំចូលចិត្តមានអារម្មណ៍ទទួលការដឹកនាំកន្លែងដែលខ្ញុំទៅ ចូលចិត្តវា។ បើសិនជាខ្ញុំទៅដោយព្រោះមនុស្សបញ្ជូនខ្ញុំមក ដូច្នេះគឺខ្ញុំមកក្នុងនាមនៃក្រុមជំនុំឬអង្គការ។ បើសិនជាខ្ញុំទៅដោយបងប្រុសនេវីល(Neviile) និយាយថាខ្ញុំគួរតែទៅ ខ្ញុំអាចទៅក្នុងនាមរបស់បងប្អូនប្រុសនេវីល(Neville)។ ប៉ុន្តែខ្ញុំចូលចិត្តទៅពេលព្រះយេស៊ូវបញ្ជូន ដូច្នេះអ្នកអាចទៅ ក្នុងព្រះនាមព្រះយេស៊ូគ្រីស្ទ ទៅជួបមនុស្សទាំងនោះ។

7 ហើយខ្ញុំបានដេកនៅលើគ្រែ ហើយខ្ញុំមានសភាពរាងហត់បន្តិច។ ជ្រលងភ្នំនេះ មិនយូមិនឆាប់ ខ្ញុំត្រូវចាកចេញពីជ្រលងនេះ ព្រោះវាបានធ្វើឲ្យបំពង់ករបស់ ខ្ញុំឈឺ កន្លែងបែបនេះខ្ញុំមិនអាចទ្រាំទ្របានទេ។ ខ្ញុំអាចចេញទៅហើយត្រឡប់មក វិញ...យើងត្រលប់មកវិញ ថ្ងៃក្រោយមកទៀតលីអូ និងខ្ញុំក្នុងចំងាយ

ប្រហែលសែសិបម៉ាយបន្ទាប់ពី ឆ្លងកាត់វាលភកនៅផ្លូវរីដា បំពង់កររបស់ខ្ញុំបានជា ៤0ម៉ាយពីល្វីសវីល(Louise ville)ក៏ឈប់ម្តងទៀត។ បងប្អូនប្រុសប៉ែងវូដគួរតែនៅកន្លែងណាមួយនៅព្រឹកនេះ។ ហើយថ្ងៃមួយកំពុងមកពីឃីងស្តូន ហើយ—ហើយពើទូរីកូ កន្លែងដែលបំពង់ករបស់ខ្ញុំបានជាដាច់ ហើយខ្ញុំចេញយន្តហោះទៅមិនមានបញ្ហាអ្វីឡើយនិងមុនពេលខ្ញុំទៅដល់ជេហ្វឺសាន់វីល(Jefferson ville) វាមានបញ្ហាម្តងទៀត។ ឃើញទេ វាជាជ្រលងនៅទីនេះ។ វាមានបាក់តេរីក្នុងខ្យល់ ឬអាចមកពីព្រះ ទ្រង់ ព្យាយាមយកខ្ញុំចេញ។ ដូច្នេះខ្ញុំ—ខ្ញុំមិនយល់ឡើយ។ ខ្ញុំអធិស្ឋាននិងសួរជាច្រើនដង។

8 ប៉ុន្តែទោះជាយ៉ាងណា ខ្ញុំទើបក្រោកឡើង ហើយវាប្រហែលជាម៉ោងបីពេលព្រឹក។ ហើយប្រពន្ធខ្ញុំនិងកូនប្រុសខ្ញុំកំពុងដេក។ ហើយខ្ញុំក្រោកឡើងនៅម្ខាងគ្រែ ហើយខ្ញុំឃើញមនុស្សជាច្រើន បានប្រជុំគ្នានៅកន្លែងធំមួយ ហើយខ្ញុំនិយាយទៅកាន់ប៊ីលីប៉ុល "ចូរអ្នកទៅទីនោះហើយចែកកាតអធិស្ឋានដល់អ្នកទាំងនោះចុះ"។

9 រួចគាត់និយាយ "បាទ ពុក" ក្នុងបីបួននាទីក្រោយមកគាត់ត្រឡប់មកវិញ ហើយនិយាយថា "អ្នកមិនអាចចែកកាត អធិស្ឋានដល់មនុស្សទាំងនោះឡើយ" គាត់និយាយទៀតថា "អ្នកឃើញបុរសម្នាក់ឈរនៅទីនេះទេ?"

ខ្ញុំនិយាយថា "មែន។"

10 គាត់និយាយ "គាត់នៅទីនេះ និងខ្ញុំនិយាយ 'នរណាចង់បានកាតសូមលើកដៃ'" និងនិយាយ "ខ្ញុំទៅចែកកាតអធិស្ឋានឲ្យគាត់ គាត់ដើរចេញ។ រួចខ្ញុំបន្តទៅទីនោះ ហើយគាត់ដើរចេញទៀត។ ឥឡូវនេះគាត់នៅខាងក្រោយនេះ" បន្តថា "ខ្ញុំមិនអាចចែកកាតសូម្បីតែមួយ"។

11 ខ្ញុំនិយាយ "ល្អ Billy អ្នកមិនចាំបាច់ចែកកាតឡើយ ព្រោះមានកន្លែងធំនៅទីនេះដែលគ្រប់គ្នាអាច..."កាតអធិស្ឋានគឺកុំឲ្យគាត់ជ្រួលច្របល់ ប៉ុណ្ណោះ...អ្នកឃើញទេ ពួកគេតាមរបៀបល្អណាស់។ ខ្ញុំនិយាយថា "អូ ខ្ញុំអាចជួបអ្នកគ្រប់គ្នានៅទីនោះ មិនមានអ្វីក្រៅពីនៅកន្លែងវាលខ្ញុំមានឡើយ និងតម្រង់ពួកគេជាជួរ ម្តងមួយៗ"។

12 ហើយគាត់និយាយ "ត្រូវហើយ"។ ហើយគាត់ត្រឡប់ ទៅស្តាំនិងចេញពីខ្ញុំទៅ។ ហើយខ្ញុំបែរមកវិញ របៀប*នេះ*ពេលគាត់ចេញទៅ*ផ្លូវនោះ* និងមើលគាត់។

13 ហើយខ្ញុំឮសម្លេងចុះមកពីលើមេឃ ហើយនិយាយ "ប៉ុន្តែនៅពេលនេះយើងនឹងចាប់ផ្តើមចំរើនអ្នក។" ហើយខ្ញុំមើល ហើយខ្ញុំមិនដែលឃើញ ហ្វូងមនុស្សបែបនេះឡើយ ពួកគេមានគ្នាទាំងហ្វូងគ្រប់កន្លែង។

14 ហើយឈ្មោះរបស់បងប្អូនប្រុសរ៉ូបឺត (Roberts) ត្រូវបានហៅនិយាយ "ឥឡូវបងប្អូនប្រុសអូរ៉ាល់រ៉ូបឺត(Oral Robert)នឹងមករកអ្នក"។

ហើយខ្ញុំនិយាយ "តើខ្ញុំស្វាគមន៍បងប្អូនប្រុសរ៉ូបឺតយ៉ាងម៉េច?"

និយាយថា "ដូចរបៀបដែលគាត់ស្វាគម៍អ្នក"។

15 ល្អ ខ្ញុំឃើញបងប្អូនប្រុសរ៉ូបឺតចូលមកស្លៀកឈុតពណ៌ខ្មៅ និងមួកតូចដូចប៊ីងក្រូសប៊ីពាក់(Bing Crosby)ពួកគេបែរបន្តិច ហើយទាញចុះក្រោមបន្តិច មួកតូចខ្មៅមួយ។ ហើយខ្ញុំកំពុងឈររាងឡើងបន្តិច គាត់មើលហើយនិយាយ "សួស្តីបងប្អូនប្រុសប្រានហាំ"។

ហើយខ្ញុំនិយាយ "សួស្តី បងប្អូនប្រុសរ៉ូបឺត" ចាប់អង្រួនដៃ។

និយាយ "អ្នកមានហ្វូងមនុស្សល្អណាស់"។

16 ខ្ញុំនិយាយ "ត្រូវហើយ បងប្អូនប្រុស Roberts" ហើយគាត់ងាកមកខាងប៊ីលី (Billy) ចេញទៅស្តាំ។

17 ហើយខ្ញុំគិត "តើខ្ញុំនិយាយជាមួយពួកគេពីកន្លែងណា?" ហើយខ្ញុំព្យាយាមគ្រប់កន្លែងដើម្បីរកកន្លែងនិយាយ។ ខ្ញុំកំពុងនៅក្នុងស្ថានភាពមួយគឺភ្លេចអស់ហ្មងដែលខ្ញុំមិនអាចរកឃើញកន្លែងដែល—និយាយជាមួយពួកគេ។

ហើយមានម្នាក់និយាយថា "ល្អ មកទីនេះ"។

18 ខ្ញុំនិយាយ "ល្អ អ្នកមិនអាចឃើញថាមិនមានអ្វីប្រសើរទីនោះទេ" ហើយខ្ញុំចាប់ផ្តើមដើរកាត់កន្លែងនោះ។ ហើយខ្ញុំចងចាំពីការនេះ ខ្ញុំនិយាយ "រឿងធំដែលត្រូវធ្វើគឺខ្ញុំត្រូវបន្ទាបខ្លួនក្នុងចិត្តជានិច្ច នៅចំពោះព្រះ និងកូនរបស់ទ្រង់"។

19 ហើយខ្ញុំចេញពីនិមិត្តមក។ ហើយខ្ញុំគិត "តើវាមានន័យយ៉ាងណា? ប្រហែលមានន័យថាយើងនឹងមានដូច...ឬកន្លែងដែល—កន្លែងវានឹងទៅឯណា?" អ្នក

ឃើញ ជួនកាលក្នុងនិមិត្ត ទ្រង់មិនប្រាប់អ្នកថាកន្លែងណាឡើយទ្រង់—ទ្រង់មានបន្ទូលនិងអ្នកគ្រាន់តែ...ជាប្រស្នា ដូចជា។ ហើយខ្ញុំជឿជាក់ថាអ្នកដែលអានព្រះគម្ពីរយល់ការនោះ។

20 ហើយខ្ញុំទៅបន្ទប់ខាងមុខនិងអង្គុយខាងមុខមួយស្របក់ហើយម៉ោងប្រហែលបីកន្លះឬបួនពេលព្រឹក។ ខ្ញុំងងុយដេកណាស់។ ខ្ញុំត្រឡប់ទៅវិញនិងដេក ហើយខ្ញុំយល់សប្តិ ហើយវាជាសុបិនចម្លែកមួយ។ ហើយភាគច្រើននៃអ្នកជាអ្នកគ្រប់គ្រងអ្នកដឹងជេកម័រ បងប្អូនប្រុសជេកម័រ(Jack Moore)។ ខ្ញុំស្គាល់គាត់ជាច្រើនឆ្នាំមកហើយ។ ខ្ញុំគិតថាខ្ញុំចេញទៅក្រៅ ជាមួយការណាត់ជួបជាមួយកូនស្រីរបស់គាត់ជាក្មេងស្រីអាយុប្រហែលដប់ប្រាំពីរឆ្នាំ និងចាប់ដៃនាង នាំនាងឡើងលើភ្នំក្មេងតូចជេកគី។ ល្អ ខ្ញុំស្គាល់នាងតាំងពីនាងនៅជាទារកតូច។ ហើយខ្ញុំនាំនាងទៅលើភ្នំ ហើយខ្ញុំបានទៅទីក្រុងបីនៅជុំវិញភ្នំ នាំក្មេងស្រីទៅ។ ហើយយើងមកក្រោមដើមឈើធំ ហើយនាងអង្គុយចុះ។ ហើយដូចជាក្មេងស្រីវ័យជំទង់សព្វថ្ងៃស្លៀកសំពត់ទាំងនោះ អ្នកដឹង ប្រភេទប៉ោងចេញ និងនាងស្លៀកសំពត់មួយប្រភេទបែបនោះ។ ហើយនាងយកសំពត់នេះរាយពន្លានិងអង្គុយចុះ។ ហើយពេលមនុស្សក្មេងតែងសម្លឹងមើលគ្នា នាងបត់ដៃបែប*នេះ*និងចាប់ផ្តើមសម្លឹងមើលទៅលើមេឃ។ ល្អ ជេកគី(Jakie)គឺជាក្មេងស្រីតូចស្អាតម្នាក់ ប៉ុន្តែនាងមានមាត់ធំនិងភ្នែកធំ និងមានសក់ពណ៌ខ្សាច់ មិនសូវជាទាក់ទាញប៉ុន្មានទេ ប៉ុន្តែជាស្ត្រីតូចមួយ។ ហើយខ្ញុំអាចមើលឃើញភ្នែកធំរបស់នាងសម្លឹងមើលទៅលើមេឃ និងមានរូបឆ្លុះរបស់មេឃក្នុងភ្នែករបស់នាង។

21 ល្អ ខ្ញុំចេញទៅប្រហែលប្រាំហ្វីតពីនាង ហើយដេកចុះទៅម្ខាងរបៀប ដូច*នេះ* ហើយខ្ញុំយកទុយោមក ហើយដាក់វាក្នុងមាត់ហើយទំពារទុយោនេះ។ ហើយខ្ញុំចាប់ផ្តើមគិត "តើខ្ញុំធ្វើអ្វីនៅទីនេះ? ហេតុអ្វីខ្ញុំជាមនុស្សចាស់ និងនៅជាមួយក្មេងស្រី។ ហេតុអ្វី?" ខ្ញុំនិយាយ "ខ្ញុំរៀបការនិងមានកូនច្រើនមកហើយ។ ខ្ញុំមិនគួរមានភារៈ កិច្ចអ្វីទីនេះជាមួយក្មេងស្រីឡើយ"។

22 ហើយខ្ញុំក្រោកឡើង។ ហើយ ពេលខ្ញុំក្រោកហើយមានសម្លេងពីដើមឈើ និងនិយាយ "នេះសម្រាប់ជាទីសម្គាល់និងសម្រាប់ហេតុផល"។

23 ហើយខ្ញុំភ្ញាក់ឡើង ហើយស្ទើរតែស្រែកផង—ជាសុបិន្តអាក្រក់។ ខ្ញុំគិត "អូឆ្ងល់ថាតើមានន័យថាខ្ញុំនឹងរវាតចិត្តឬអ្វីមួយកើតឡើងចំពោះខ្ញុំឬ? ល្អ" ខ្ញុំគិត "បើ

សិនជាខ្ញុំទៅនៅតែបន្តប្រើគំនិតរបស់ខ្ញុំ ដូច្នេះខ្ញុំនឹងមានភាពច្របូកច្របល់។ដូច្នេះខ្ញុំត្រូវរង់ចាំព្រះ˝ ហើយខ្ញុំចាប់ផ្តើមអធិស្ឋាន។ ខ្ញុំនិយាយ "ព្រះអម្ចាស់ តើសុបិននោះមាននិមិត្តដូចយប់ដំបូង ឬក៏វាមានន័យយ៉ាងណា?˝

24 បន្ទាប់ពីរង់ចាំ ពេលវេលា ប្រហែលរយៈពេលមួយម៉ោង(ប្រពន្ធរបស់ខ្ញុំក្រោកឡើងនិងរៀបចំអាហារពេលព្រឹកជាស្រេច) ដូច្នេះសម្លេងមកម្តងទៀត និងនិយាយ "ទៅឃីងស្តុន(Kingston) ហើយនឹងប្រាប់អ្នកនៅទីនោះថាធ្វើអ្វី˝។

25 ដូច្នេះភ្លាមៗនោះខ្ញុំចេញទៅឃីងស្តុន។ ហើយពួក—ពួកគេដឹងថារសៀលថ្ងៃ ព្រហស្បតិ៍ ដែលខ្ញុំត្រូវទៅដល់ទីនោះថ្ងៃសុក្រ។ នោះជាអ្វីដែលយើងបានផ្សព្វផ្សាយ។ ខ្ញុំមិនសូវពូកែរាប់...?...ឬរាប់ស្មានចំនួនមនុស្ស ព្រោះខ្ញុំតែងតែពន្លើសវា។ ប៉ុន្តែយប់ដំបូង ខ្ញុំនិយាយយើងមានប្រហែលដប់ពីរ អូ ប្រហែលមនុស្សមួយពាន់ពីររយលើស ព្រោះវាត្រឹមតែមួយថ្ងៃ។ ហើយថ្ងៃបន្ទាប់ពួកគេចាប់ផ្តើមមានអ្នករត់ រត់ចំងាយបួនម៉ាយ និងមានអ្នករត់ឡើងលើភ្នំ។ អ្នករត់ម្នាក់ត្រូវប្រើរយៈពេល4ម៉ោងហើយអ្នកផ្សេងទៀតត្រូវរត់ឡើងលើភ្នំ។ ហើយយប់ទីពីរមានប្រហែលប្រាំពាន់នាក់។ ហើយយប់ទីបីវាត្រូវបានគណនាប្រហែលដប់ប្រាំពាន់នាក់ប្រហែលពីរម៉ឺនផង។ ហើយរាប់ពាន់ដង ហើយមនុស្សរាប់ពាន់ចូលមកក្នុងព្រះអម្ចាស់។

26 ហើយនិមិត្តគឺក្រុមជំនុំតូចមួយ ស្ត្រីគឺព្រហ្មចារី ដូចជាកូនក្មេង ហើយនោះមានន័យថាក្រុមជំនុំបរិសុទ្ធ។ ហើយទីក្រុងបីនៅជុំវិញភ្នំ ជារយៈពេលបីថ្ងៃដែលខ្ញុំនឹងដឹកនាំ។ ហើយមានក្រុមជំនុំបរិសុទ្ធដោយការដឹកនាំបម្រើរបស់ខ្ញុំ ពីកន្លែងដែលនាងនៅទៅកម្រិតខ្ពស់ឡើងក្នុងការងាររបស់ព្រះ រហូតដល់វាកក្រើកកោះទាំងមូល។

27 ហើយអូ អ្នកដឹកនាំមនុស្សជុំវិញ យំនិងអង្វរនិងជម្រុញឡើង "ត្រឹមមួយយប់ឬពីរលើសនេះ˝ មន្ត្រីក្រុង។

28 យើងចេញពីទីនោះ ទៅពួតូរីកូ(Puerto Rico)។ ទីនោះយើងជួបជាមួយភាពជោគជ័យធំខ្ពស់ ហើយមនុស្សរាប់ពាន់ក្នុងចំណោមរាប់ពាន់ប្រមូលមកតាមផ្លូវរហូតដល់វាត្រូវបានប៉ាន់ស្មានថាមាន ព្រលឹងដ៏មានតម្លៃបួនម៉ឺននាក់ បានចូលមកក្នុងព្រះអម្ចាស់យេស៊ូវ។ ហើយពេលបន្ត ខ្ញុំសង្ឃឹមខ្ញុំ...ខ្ញុំនិយាយរឿងនេះទៅក្រុមជំនុំផ្ទាល់របស់ខ្ញុំ ប៉ុន្តែខ្ញុំមិនអាចនិយាយវាជាសាធារណៈ ដែលជាកន្លែងមិន

មានអ្នកស្រុកចាស់ៗ ព្រោះប្រហែលជាគេមើលទៅឃើញផ្លូវខុស។ ប៉ុន្តែខ្ញុំមានបញ្ជីរឈ្មោះអ្នកគ្រប់គ្រងទីនេះជាអ្នកផ្តល់ការពិភាក្សាមុនយើងចាកចេញទីនេះ គាត់និងបុគ្គលិករបស់គាត់។

29 ហើយខ្ញុំ...គាត់—គាត់និយាយ "យើងមានកិត្តិយសនៅលើកោះដែលមានអ្នកដឹកនាំផ្សេងៗគ្នា" គាត់និយាយ "ពេលលោកប៊ីលីហ្គ្រាហាំ(Billy Graham)ទើបតែចេញពីកោះថ្មីៗ" និងនិយាយថា "យើងមាន—ការប្រជុំមួយដ៏មានសិរីរុងរឿង" គាត់បន្ត "ប៉ុន្តែប៊ីលីហ្គ្រាហាំ គ្រាន់តែនាំឲ្យយើងនូវដំណឹងល្អដូចគ្នាដែលយើងមាន និងបានឮរួចមកហើយ" គាត់និយាយបន្តថា "រួចយើងមានកិត្តិយសដែលមានលោក រ៉ូប៊ឺតនៅលើកោះ" គាត់និយាយ "ហើយលោករ៉ូប៊ឺតផ្តល់ឲ្យយើងនូវការជុំគ្នាបីថ្ងៃយ៉ាងអស្ចារ្យ។ ប៉ុន្តែ" គាត់បន្តថា "ការចំណាយខ្ពស់ណាស់នៅសណ្ឋាគារ" និយាយ "ចំណាយបីម៉ឺនប្រាំពាន់ដុល្លាក្នុងបីយប់សម្រាប់ការចំណាយសណ្ឋាគារ" គាត់បន្តថា "រួចលោកអូស្បូន(Osborn)នៅទីនេះ ដែលជាអ្នកបម្រើអស្ចារ្យរបស់ព្រះគ្រីស្ទ។ ប៉ុន្តែ" និយាយ "ពេលលោកអូស្បូនចាកចេញទៅ មានភាពធ្លាក់ចុះបន្តិច" និយាយ "វាហាក់ដូចជាអ្វីៗ ទៅបាត់ដែរ"។

30 "ប៉ុន្តែ" និយាយ "យើងសម្គាល់នៅការជួបជុំនេះថាពិតជាមិនពិបាកដល់នរណាម្នាក់ឡើយនៅលើឆាកសម្រាប់បងប្អូនប្រុសប្រាណហាំឲ្យអធិស្ឋានឲ្យ។ ប៉ុន្តែ" និយាយ "បន្ទាប់ពីកម្មវិធីចប់ទៅ យើងបានប្រមូលដឹកកៅអីចាស់ និងកៅអីជើងខ្វែង និងគ្រប់យ៉ាងសម្រាប់អ្នកចូលរួម" គាត់និយាយថា "មិនមែនជាមនុស្សទេ នៅពេលនេះ គឺព្រះបានមករកយើង" នេះជាសំដីគាត់។

31 ខ្ញុំនិយាយ "កុំរំពឹងលើការអធិស្ឋានរបស់ខ្ញុំ ប៉ុន្តែការអធិស្ឋានរបស់អ្នកនៅទីនោះ ដាក់ដៃលើគ្នាទៅវិញទៅមក។" ហើយអាចនាំ មនុស្សមកមួយចំនួន ឬពីរនាក់លើវេទិលការ និង ពេលការយល់ខាងវិញ្ញាណធ្លាក់មក មនុស្សបានស្រែក។ យើងស្នាក់នៅសណ្ឋាគាលំដាប់ទីបួន ហើយការចំណាយចាយវាយនិងការធ្វើដំណើររបស់យើងគឺដោយផ្ទាល់ខ្លួន"។

32 អ្នកជួយធ្វើបែបនោះ ខ្លួនឯង ដោយតង្វាយមួយភាគដប់របស់អ្នកដែលផ្ញើមកឲ្យខ្ញុំ។ នោះជាអ្វីដែលបានធ្វើ។ ហើយខ្ញុំចង់ឲ្យអ្នកដឹង ចេញពីអ្វីទាំងនោះ អ្នក មានចំណែកនោះ។ ហើយថ្ងៃដ៏មានសិរីរុងរឿងមកដល់ ព្រះនឹងប្រទានរង្វាន់អ្នក សម្រាប់សេចក្តីនោះ។ ឃើញទេ អ្នកមិនចាំបាច់ចំណាយទេ...

33 បើសិនជាមនុស្សទៅសម្ដែងអ្វីមួយខ្លួនឯង។ ដូច្នេះអ្នកឃើញទេ ពេលមនុស្ស នោះចេញទៅ ពួកគេយល់ថា"មានការធ្លាក់ចុះធំមួយ ព្រះចាកចេញពីយើង"។ ព្រះ មិនបានចាកចេញពីអ្នកឡើយ។ ទ្រង់គង់ជាមួយអ្នកជានិច្ច។ មើល វាជាខ្លួនអ្នក ផ្ទាល់ដែលជ្រុលចូលទៅ ក្នុងអ្វីមួយ ជានរណាម្នាក់។ ព្រះអាចប្រើមនុស្សណា ម្នាក់សម្រាប់ព័ន្ធកិច្ចអ្វីមួយ ប៉ុន្តែមិនមានន័យថាមនុស្សនោះជាជម្រើសរបស់ព្រះ ឡើយ។ វាជាជំនឿអ្នកផ្ទាល់ក្នុងព្រះ។

34 ហើយពួកគេចេញទៅទីនោះនៅក្នុងរទេះតូច ដែលពួកគេមានស្រដៀងរទេះ ទារក និង—និងមានកង្កា និងដាក់មនុស្សលើវានិងបររុញទៅមុខ។ បន្ទាប់ពីកម្មវិធី ចប់ រាល់ស្នាមដានប្រណាំងបានសំអាតឡើង ពួកគេចាក់ចេញជាមួយរទេះកង់បួន និងមានកន្លែងផ្ទុកដូចរទេះចាស់និងមានកង់ធំៗ និងមានកៅអីខ្វែងនិងជើងម៉ា និង គ្រែ និងនោះជារបៀបគេចាកចេញនិងលើកឡើង ព្រោះនោះជាព្រះវត្តមានរបស់ ព្រះនៅទីនោះ។ នោះជាអ្វីដែលយើងចង់ឃើញ។ មនុស្សចេញពីរូបភាព ព្រះធ្វើ ចលនា។

35 ត្រឡប់មកវិញ គ្រាន់តែជួយនៅព្រឹកនេះ ខ្ញុំត្រូវនិយាយក្នុងបីបួននាទី។ ហើយ ខ្ញុំស្នើរឲ្យក្មេងប្រុសកុំចែកខ្សែរអាត់។ បីថ្ងៃខ្ញុំព្យាយាមគិតយ៉ាងខ្លាំង "តើខ្ញុំនឹង និយាយអ្វី?" ហើយ នៅព្រឹកនេះ មុនខ្ញុំចាកចេញ ខ្ញុំមានអារម្មណ៍ថាមានភាព តានតឹងពីការព្រមានក្នុងចិត្តសម្រាប់ក្រុមជំនុំ។ និងខ្ញុំប្រាប់ពួកគេ "យកខ្សែរអាត់ ប៉ុន្តែកុំចែកចាយលក់ឡើយ"។

36 ប៉ុន្តែមុនយើងធ្វើបែបនេះ ខ្ញុំចង់ចែកចាយទីបន្ទាល់តូចមួយ ដែលអាចល្អជួយ អ្នកបាន។ វាល្អសម្រាប់ខ្ញុំ។ យើងចេញទៅស្ទូចត្រីដំណើរបីថ្ងៃលីអូ(Leo) និង ហ្ស៊ីន(Gene) ជាមួយខ្ញុំដែរ និងកូនប្រុសរបស់ខ្ញុំប៊ីលីប៉ុល(Billy Paul) និងប្រពន្ធ របស់គាត់ ទៅកាន់មិត្តដែលមកទីនេះនៅរោងឧបសថ ចុះមកពីចចហ្គ Georgia។ ហើយពួកគេយកយើងទៅវិញនៅកន្លែងវាលភក់ ខ្ញុំមិនដឹងថាវានៅឯណាទេឥឡូវ ក្បែរអូគីឈូប៊ី(Okeechobee)ឬ អ្វីស្រដៀងនោះខ្ញុំមិនស្គាល់ឈ្មោះគេស៊ីមីនូលឥ ឌៀនជាអ្នកដាក់(Seminole Idians)។ ប៉ុន្តែទោះជាយ៉ាងណា យើងមាន ចំងាយ រាប់ម៉ាយ។

37 ហើយនេះបងប្អូនប្រុសអ៊ីវ៉ាន (Evans) បងប្អូនប្រុសរបស់ គាត់ជាមនុស្សមាន បាប។ ហើយគាត់ជាមនុស្សពូកែស្ទូចត្រីម្នាក់ និងគាត់បានត្រឡប់ទៅវាលភក់

វិញបីបួនខែកន្លងទៅ។ ហើយពួកគេមានអ្វីដែលហៅថា "ពស់មានពិសម្យ៉ាង" ហើយពស់នោះក៏ចឹកគាត់ គាត់ពិបាកនឹងរស់ណាស់។ ជើងគាត់ហើម និងគេយកគាត់ទៅឲ្យដុកទ័រហើយពួកគេឲ្យស្រោបន្និចផឹក។ អ្វីនោះគឺជាសចក្តីស្លាប់។ ហើយពួកគេមានបង់សំឡីដែរ បង់សំឡី ស្បែកជើងជនស្បែកក្រហម ស្បែកក្រពើប្រវែងម៉្តហ្វីត។

38 ហើយពេលយើងកំពុងស្ទូចត្រីនៅទីនោះខ្ញុំចាប់បានត្រីធំមួយ។ អូ វាជាថ្ងៃ—សំរាកពិតៗ។ ហើយវាធំណាស់រហូតខ្ញុំមិនអាចយកវាចេញពីទឹកបាន ហើយវាធ្វើឲ្យសន្ទូចលា និងរួចបាត់ទៅ វាដោះខ្លួនរួច។ ហើយយើងមានត្រីជាច្រើន វាមានទំងន់ប្រហែលហាសិបទៅមួយរយផោនសម្រាប់ត្រីធំ។ ហើយមួយចំនួននៃពួកវាមានទំងន់បីបួនផោន និងពីបួនទៅប្រាំពីរផោន ប្រាំបីផោន។ ហើយខ្ញុំចាប់បានអាធំមួយ ហើយវារបូតទៅ។

39 ហើយខ្ញុំបោះទៅវិញ ហើយខ្ញុំ—ខ្ញុំចាប់បានមួយទៀតប្រហែលប្រាំមួយ ប្រាំពីរផោន។ ហើយខ្ញុំមានដងសន្ទូចវែងដែលអ្នកត្រូវទប់មានទាំងស្លឹកផ្កាទឹក។ ហើយបងប្អូនប្រុសអ៊ីវ៉ានបាន...យើងទាំងអស់គ្នាបានទទឹកដោយសារដើរលុយទឹកព្រោះវាជាវាលភក់។ ហើយគាត់ទាញស្បែកជើងចេញ និងមូរខោឡើង ហើយរៀបចំដាក់កន្លែងស្ងួត ដូចហាលខោអាវចឹង។ ហើយគាត់ឃើញត្រីធំមួយននៀលជិតគម្ពោតព្រៃហើយខ្ញុំលុយទៅរកវា។ គាត់និយាយ "រង់ចាំមួយភ្លែត បងប្អូនប្រុសប្រានហាំខ្ញុំនឹងយកវាឲ្យអ្នក។" រួចគាត់រត់ទៅទីនោះ។ ហើយខ្ញុំទាញវាមកមើលទៅត្រីនោះជិតងាប់ហើយ ដេកលើស្លឹកឈើ។ ហើយគាត់រត់ទៅយកវា។ ហើយ ពេលគាត់ធ្វើដូច្នោះ គាត់ក៏ស្រែក ហើយគាត់ក៏មកវិញ។ ពស់ពិសចឹកគាត់។

40 ហើយយើងសម្លឹងមើលវា ហើយទីនេះមានប្រហោង ចង្កូមក្នុងជើងរបស់គាត់ដែលជាកន្លែងពស់ពិសបានចឹកគាត់ ហើយវាធ្វើឲ្យគាត់ឈឺខ្លាំងណាស់រហូតដល់ទឹកភ្នែកចេញពីភ្នែកគាត់។ និយាយថា មានអារម្មណ៍ដូចជាឆ្អឹងរបស់គាត់បានខ្ទិនទៅហើយ។ ហើយយើង មានចំងាយរាប់ម៉ាយដើម្បីចេញពីវាលភក់។ ហើយគាត់ជាមនុស្សមាឌធំណាស់មិនអាចសែងបាន។ ហើយពេលពស់ចឹកអ្នក អ្នកមានអារម្មណ៍ឈឺចាប់ខ្លាំងណាស់ រយៈពេលបីបួននាទី រហូតដល់អ្នកស្ទើរស្លាប់ផង។ ហើយលីអូក៏នៅទីនោះដែរ។ ហើយមានអ្វីមួយមកក្នុងគំនិតខ្ញុំ "ទ្រង់នៅតែជា

ព្រះ!” ហើយពេលគាត់កាន់ ជើងរបស់គាត់ដោយការឈឺចាប់ ហើយប្រហោងចង្កូមពីរធំនោះជាកន្លែងដែលពស់ពិសខាំគាត់ ខ្ញុំដាក់ដៃត្រង់នោះហើយនិយាយ “ព្រះអម្ចាស់ មានសេចក្ដីចែងទុកនៅក្នុងព្រះគម្ពីររបស់ទ្រង់ ‘គេនឹងកាន់ក្បាលពស់និងខ្លាដំរី តែគ្មានអ្វីដែលធ្វើទុក្ខដល់គេវិញឡើយ’” ហើយភ្លាមៗនោះ គ្រប់ទាំងការឈឺចាប់បានចេញពីជើងគាត់ទៅ។ គាត់ពាក់ស្បែកជើងវិញ និងស្ងួចត្រីពេញមួយថ្ងៃ។

41 ចេញទៅយប់នោះនិងប្រាប់គេពីរឿងនោះ ពួកគេនិយាយថា “អ្នកគួរទៅជួបដុកទ័រប្រសើរជាង។”

42 គាត់និយាយ “បើសិនជាព្រះការពារខ្ញុំកន្លងមក ទ្រង់នឹងថែររក្សាខ្ញុំរឿងនេះទាំងស្រុង” យើងទៅស្ទូចត្រីបីថ្ងៃ គ្មានជំងឺណាមានឥទ្ធិពលទ្បើយ។

43 ព្រះទ្រង់នៅតែជាព្រះ។ ទ្រង់រក្សាគ្រប់ទាំងក្ដីសន្យារបស់ទ្រង់។ ហើយអស់ទាំងពន្ធ័កិច្ចរបស់ខ្ញុំនោះជាលើកទីមួយដែលខ្ញុំឃើញព្រះយាងមកលើពស់ចឹក។ ព្រោះនោះជាលើកទីមួយដែលខ្ញុំមានឱកាសដើម្បីអធិស្ឋានសម្រាប់អ្នកដែលត្រូវពស់ចឹក។ ចូរឲ្យអ្នកដឹងថាទ្រង់រក្សាគ្រប់ទាំងសេចក្ដីសន្យាទ្រង់ ហើយព្រះបន្ទូល ទ្រង់ល្អ ហើយពិត។ អាម៉ែន។

44 សូមចងចាំកម្មវិធីយប់នេះ និងពេលព្រឹកថ្ងៃ ពុធ។ និងអធិស្ឋានសម្រាប់នរណាដែលពិតជាចាំបាច់សម្រាប់អធិស្ឋានឲ្យ នោះគឺខ្ញុំ។ ហើយចងចាំ ពីការចូលរួមកម្មវិធីជួបជុំរបស់បងប្អូនប្រុសរ៉ូប៊ីត(Roberts) ពេលដែលធ្វើនៅក្នុងក្រុង ហើយជំរាបសួរគាត់ពីរោងឧបោសថ។

45 មុនយើងអានបទគម្ពីរ។ ខ្ញុំ—ខ្ញុំចង់ឲ្យយើងក្រោកឈរទ្បើងមួយនាទី។ ហើយដោយមិនបាច់មានតន្ដ្រី ចូរច្រៀងកន្លែងបន្ទរ ឬពីរជួរនៃចម្រៀងសរសើរតំកើងដ៏មានសិរីល្អនៃក្រុមជំនុំ។ “ជំនឿខ្ញុំមើលទៅកាន់ ទ្រង់” ត្រូវឲ្យគ្រប់គ្នាចូលរួមជាមួយខ្ញុំឥឡូវហើយច្រៀង។ កុំគិតថាត្រូវច្រៀងយ៉ាងម៉េចគ្រាន់តែច្រៀងថ្វាយសិរី រុងរឿងដល់ព្រះប៉ុនោះ។តើអ្នកនឹងដឹកនាំយើងបានទេ បងប្អូនប្រុសនេវីល(Nerville)?

ជំនឿខ្ញុំមើលទៅកាន់ទ្រង់
ទ្រង់ជាចៀមនៅកាល់វ៉ារី
ព្រះអង្គសង្គ្រោះ
ឥឡូវសណ្ដាប់ពេលខ្ញុំអធិស្ឋាន
យកទោសទូលបង្គំចេញ
អូ ឲ្យខ្ញុំរួចថ្ងៃនេះ
ជាទ្រង់ទាំងមូល!

ពេលភាពងងឹតក្នុងខ្ញុំ
និងទុក្ខសោកខ្ញុំរីកសាយ
សូមទ្រង់នាំខ្ញុំ
ធ្វើឲ្យងងឹតប្រែថ្ងៃនេះ
សំអាតភាពសោកសៅ ខ្លាចចេញ
ក៏កុំឲ្យខ្ញុំវង្វេង
ឆ្ងាយពីទ្រង់ឡើយ។

46 ជាមួយក្បាលរបស់យើងឱនស្រាប់ ខ្ញុំសូមឲ្យយើងអានពីសំណេរវិសុទ្ធពីព្រះគម្ពីរ ម៉ាថាយជំពូកទី៧ ខ១៣និង១៤។ ហើយសូមឲ្យព្រះអម្ចាស់បន្ថែមភាពបរិបូរណ៍នៃព្រះពរទ្រង់ពេលយើងអានវា។

*ចូរឲ្យចូលតាមទ្វារចង្អៀតដ្បិតទ្វារដែលនាំទៅឯសេចក្ដីហិនវិនាសនោះធំហើយទូលាយផង ក៏មាននមនុស្សជាច្រើនដែលចូលតាមទ្វារនោះ*

*តែឯទ្វារដែលនាំទៅឯជីវិត នោះតូច ហើយចង្អៀតវិញ ក៏មានមនុស្សតិចណាស់ដែលរកផ្លូវនោះឃើញ។*

47 ចូរយើងអធិស្ឋាន។ អូ ព្រះ ដែលទ្រង់បាននាំព្រះយេស៊ូវឲ្យរស់ឡើងវិញពីការសុគតក្នុងផ្នូរ និងបង្ហាញព្រះអង្គទ្រង់ដល់ទូលបង្គំ នៅព្រឹកនេះជាយញ្ញបូជារស់ ពួកទូលបង្គំលះបង់ដោយបន្ទាបខ្លួននៃជីវិតរបស់ទូលបង្គំចំពោះទ្រង់ជាថ្មី ជាគំនិតដែលទ្រង់យកព្រះទ័យទុកដាក់ នឹងទូលបង្គំ។ កាលបើទូលបង្គំនៅជាមនុស្សមានបាបស្លាប់ក្នុងបាបនិងអំពើរំលង ទ្រង់បានបញ្ជូនព្រះបុត្រាទ្រង់តែមួយប្រសូត្រជារូបរាងសាច់ឈាមមានបាប ក្លាយជាថ្លៃលោះបាបទូលបង្គំ ជាអង្គមិន

មានកំហុសត្រូវរងទុក្ខចំពោះកំហុសដែលអាចផ្សះផ្សាពួកទូលបង្គំទាំងអស់គ្នាម្តង ទៀតក្នុងការប្រកបជាមួយទ្រង់។

48 ហើយអូ ព្រះបើសិនពួកទូលបង្គំមានបាបនៅព្រឹកនេះ ជាអ្វីដែលអាចជារនាំងដល់ព្រះវិញ្ញាណបរិសុទ្ធ ពីការនាំពួកទូលបង្គំ ឲ្យចូលក្នុង សាររបស់ព្រះចំពោះចិត្តទូលបង្គំម្នាក់ៗ ពួកទូលបង្គំអធិស្ឋាន បន្ទាបខ្លួន ព្រះអម្ចាស់ ទ្រង់បានអត់ទោសអំពើរំលងរបស់ទូលបង្គំ។ សូមសំអាតទូលបង្គំ ដោយ ព្រះលោហិតព្រះយេស៊ូវ។ ជាអង្គ...យើងដឹង ក្នុងខ្លួនយើងទូលបង្គំមិនជា អ្វីឡើយ ហើយពួកទូលបង្គំសារភាព ថាពួកទូលបង្គំមិនជាអ្វីឡើយ។ ប៉ុន្តែទ្រង់ ជាអង្គបរិសុទ្ធ ទ្រង់ជាអង្គពិត ទ្រង់សុចរិត ទ្រង់ជាប្រភពនៃសេចក្តីមេត្តា។ ហើយ ទូលបង្គំបន្ទាបខ្លួនដោយលូនទៅទីនោះនៅថ្ងៃនេះ ជាអ្នកជំងឺខាងព្រលឹង។ ដូចជា ទីបន្ទាប់ទើបតែបានបញ្ជូនទៅ ពីចាម៉ៃកា(Jamaica)និងពីពួតូរីកូ(Puerto Rico)និងកន្លែងដែលទ្រង់ធ្វើការយ៉ាងធំ អូ ព្រះ វាជាទីសម្គាល់នៃការយាងមក របស់អង្គសុចរិតមួយ។

49 ទ្រង់បានរំដោះបងប្អូនប្រុសអ៊ីវ៉ាន(Evans)ពីចង្កូមពិសនៃពស់នោះ ព្រោះ គាត់ជាអ្នកជឿ និងព្រះបន្ទូលទ្រង់តែងតែពិត។ ឥឡូវព្រះអម្ចាស់ សូមរំដោះ ទូលបង្គំពីចង្កូមនៃសេចក្តីស្លាប់ព្រឹកនេះ ដែលពួកខ្មាំងសត្រូវបានខាំនិងបំពុល ពួកទូលបង្គំ។ សូមឲ្យការប្រោសឲ្យជារបស់ទ្រង់ក្លាយជាថ្នាំព្យាបាល ព្រឹកនេះ ព្រះអម្ចាស់សូមជ្រាបចូលវិញ្ញាណរបស់ពួកទូលបង្គំនិងសំអាតពួកទូលបង្គំពីគ្រប់ អស់ទាំងសេចក្តីទុច្ចរិត។ សូមប្រោសព្យាបាលអ្នកជំងឺរាងកាយ ដែលខ្ទេចខ្ទាំ ដោយអំណាចរបស់ពួកខ្មាំងសត្រូវ។ អ្វីទាំងអស់នៅក្នុងព្រះវត្តមានព្រះ សូមឲ្យ ពួកគេបានជា។

50 សូមមានបន្ទូលមកកាន់ ទូលបង្គំឥឡូវតាមរយៈ ព្រះបន្ទូលដែលបានកត់ទុក មករបស់ទ្រង់ ព្រះអម្ចាស់។ ដោយមិនដឹងថានិយាយអ្វី ប៉ុន្តែទ្រង់នឹងប្រទាន មក។ ហើយទ្រង់ព្រមានយើង ព្រះអម្ចាស់ និងធ្វើឲ្យយើងបានត្រៀមខ្លួនសម្រាប់ ការយាងមករបស់ទ្រង់។ សូមអធិស្ឋានទូលសូមក្នុងព្រះនាមព្រះយេស៊ូវនិងជា ប្រយោជន៍ទ្រង់។ អាម៉ែន។

51 ខ្ញុំតែងតែឃើត ព្រោះខ្ញុំរង់ចាំឥឡូវ។ ហើយថ្នាក់ថ្ងៃអាទិត្យប្រហែលចប់ហើយ។ ប៉ុន្តែមានអ្វីអំពីវាពេលខ្ញុំមកផ្ទះ ខ្ញុំមានអារម្មណ៍ថាមានពេលច្រើន។ អ្នកដឹងទេថា យើងប្រញាប់ពេក យ៉ាងណាក៏ដោយ។ ដូច្នេះយើងត្រូវជឿព្រះ។

52 ព្រះអម្ចាស់របស់យើងប្រទានការព្រមានច្បាស់ៗ ដល់មនុស្សនៃសម័យរបស់ទ្រង់ ជាពួកដែលមានភាពសាសនាជ្រុល។ ហើយទ្រង់មានបន្ទូល "ឯទ្វារដែលនាំ ទៅឯជីវិតនោះតូច ហើយចង្អៀតវិញ ក៏មានមនុស្សតិចណាស់ដែលរកផ្លូវនោះឃើញ។" ឥឡូវមិនមែនដោយសាពួកគេមិនកាន់សាសនាជ្រុលពេកទេឬ។ ហើយដោយសារពួកគេទុកចិត្តនឹងក្រុមជំនុំនៅក្នុងលទ្ធិ និងនិកាយ និងបានជឿ(ដើម្បីពង្រីក)ក្នុងព្រះពួកគេគិតថាគ្រប់យ៉ាងគឺមិនអីទេ។ ប៉ុន្តែទ្រង់កំពុងមានបន្ទូលប្រាប់គេថាមានមនុស្សតិចដែលចូលបាន។

53 ហើយខ្ញុំឆ្ងល់ថាព្រឹកនេះខ្ញុំអាចមិនដូចជាមនុស្សនៅជំនាន់នោះជាមួយជំនាន់នេះ។ ឃើញ វាស្រដៀងគ្នាណាស់ជាមួយការបែងចែករបស់យូដា និងទ្រង់សំដៅលើមនុស្សដែលខុសគ្នានិងការបញ្ជាប់ខុសគ្នានៃការបែកខ្ញែកខុសគ្នា និងកំពុងប្រាប់ពួកគេថាភាពជាក់ច្បាស់ដែលកំពុងធ្វើឡើងកាលពីការបែងចែកមុនគឺបានម្រេចនៅពីមុខពួកគេ។ ហើយពួកគេមិនបានស្គាល់។ ហើយចូរមើលអ្វីដែលទ្រង់កំពុងមានបន្ទូល។

54 ពួកគេ ជាឧទាហរណ៍ មិនអាចជឿថាព្រះនៅក្នុងមនុស្ស។ នោះជារនាំងមួយយ៉ាងធំដែលពួកគេត្រូវឆ្លងកាត់ គឺរបៀបដែលទ្រង់ជាមនុស្សប៉ុន្តែនៅតែជាព្រះ។ ពួកគេមិនអាចឃើញរបៀបដែលព្រះអាចរស់ក្នុងសាច់ឈាមមនុស្ស។ និងគ្រប់សម័យកាល គ្រប់ពេលវេលា ព្រះតែងគង់នៅក្នុងមនុស្ស។ មនុស្សជាមធ្យោបាយឧបករណ៍របស់ព្រះ។ គ្រប់ទាំងជំនាន់ ព្រះមានបន្ទូលទៅកាន់រាស្ត្រទ្រង់តាមរយៈបបូរមាត់របស់មនុស្ស។ ទ្រង់តែងជ្រើសរើសនរណាម្នាក់ ឬអ្វីមួយដែលទ្រង់អាចប្រើ។

55 ហើយទ្រង់សំដៅទៅពួកគេភាពជាការជំពប់ពីអ័ប្រាហាំ។ ទ្រង់មានបន្ទូល ចូរប្រាប់ពួកគេ "បើសិនជាអ្នកហៅខ្លួនថាជា 'កូនអ័ប្រាហាំ' អ័ប្រាហាំជា 'ឪពុករបស់អ្នក' គាត់ឃើញថ្ងៃ របស់យើងហើយមានអំណរ។ អ័ប្រាហាំជាព្យាការី" ហើយមិនសង្ស័យឡើយ ដែលព្រះយេស៊ូវសំដៅដល់ពួកគេថាទ្រង់បានប្រទានឲ្យគេនូវភាពជាព្រះមេស្ស៊ីរបស់ទ្រង់ព្រោះទីសម្គាល់នៃព្រះមេស្ស៊ី កំពុងតែតាមទ្រង់។

ហើយនោះជារបៀបដែលមានគ្រប់ជំនាន់ នៃទីសម្គាល់នៃព្រះមេស្ស៊ី។ ប៉ុន្តែ ទ្រង់បានប្រកាសថាទ្រង់ជាព្រះ ជាព្រះមេស្ស៊ីផ្ទាល់ ជាហេតុនាំឲ្យគេមិនយល់។ ពួកគេ មិនអាចយល់បាន។

56 ឥឡូវពេលអ័ប្រាហាំ (ដែលពួកគេបានហៅថាជាឪពុក) ជួបព្រះ ទ្រង់ក៏មាន ភាពជាសាច់ឈាម ព្រោះទ្រង់បរិភោគកូនគោ បរិភោគនំប៉័ងម្សៅពោត និងផឹកទឹក ដោះគោនិងប័រក្នុងវត្តមានរបស់អ័ប្រាហាំ តែទ្រង់នៅតែជាព្រះ។ អ័ប្រាហាំស្គាល់ ទ្រង់ ព្រះ និងហៅទ្រង់ "អេឡូហ៊ីម" ជាព្រះយ៉េហូវ៉ាមានឫទ្ធិចេស្តា។ មនុស្ស ស្លៀកពាក់ មានដីជាប់នឹងរាងកាយទ្រង់ និងគង់ក្រោមដើមឈើ ជ្រកម្លប់ និង បរិភោគសាច់និងផឹកទឹកដោះគោ។ ហើយពួកអ្នកមានចិត្តអាក្រក់ ចិត្តឃោឃៅ អាត្មានិយម ពួកយូដាសុចរិតមិនអាចជឿថាទ្រង់ជាព្រះរាជបុត្រាព្រះ និងហៅអ័ ប្រាហាំថាជាឪពុក។ ហើយទ្រង់បានឲ្យគេដឹងថាទ្រង់ធ្វើការដូចគ្នា ក្នុងសាច់ឈាម ទ្រង់ដែលទ្រង់ធ្វើការក្នុងសាច់ឈាម ពេលទ្រង់ជួបឪពុករបស់ពួកគេអ័ប្រាហាំ។ ហើយអ័ប្រាហាំបានជឿ។ តែពួកគេមិនជឿ។

57 អ្នកឃើញពេលអ័រប្រាហាំអង្គុយក្រោមតង់របស់គាត់ដែលគាត់បាន ជ្រើសរើស ហើយជម្រើសនោះបាននាំឲ្យមនុស្សគ្រប់គ្នាដែលកើតមកក្នុងលោក នេះ។ ដើមឈើល្អនិងអាក្រក់ដាក់ពីមុខមនុស្សគ្រប់គ្នា។ ហើយពេលឡុត ក្មួយប្រុសរបស់គាត់ និងពួកគង្វាលរបស់គាត់បានឈ្លោះគ្នាពីរឿងទឹកដី អ័ប្រា ហាំ ជាមនុស្សសុចរិត និយាយទៅកាន់ពួកគេ "សូមកុំឲ្យមានជម្លោះក្នុងចំណោម យើងឡើយ។ អ្នកអាចជ្រើសរើសផ្លូវដែលអ្នកទៅ។" ដែលជាកន្លែងត្រូវមកសម្រាប់ ជីវិតអ្នកជឿគ្រប់គ្នា។ ហើយវានៅពីមុខអ្នកនៅព្រឹកនេះ ហើយវាក៏នៅពីមុខខ្ញុំដែរ។

58 ឡុតមិនគិតថាគាត់នឹងទាសចេញឡើយ ប៉ុន្តែ គាត់បានសម្លឹងរកក្រុងសូ ដុំដែលជាកន្លែងងាយស្រួល។ ហើយជាច្រើនដង ដែលយើងសម្លឹងមើលអ្វីដែ លងាយៗ។ "ខ្ញុំនឹងចូលរួមក្រុមជំនុំនេះ-នេះ ហើយអ្នកឃើញ គ្មាននរណានិយាយ អ្វីទាស់នឹងវាឡើយ ព្រោះវាជាក្រុមជំនុំធំនៅក្នុងក្រុង" ផ្លូវស្រួល! មានពេលជាច្រើន យើងធ្វើបែបនោះ ពេលដែលយើងកំពុងតែខុស!

59 ចងចាំ បើអ្នកតាមព្រះគ្រីស្ទ អ្នកនឹងត្រូវបានស្អប់ពីមនុស្ស ព្រោះអស់អ្នក ដែលរស់កោតខ្លាចព្រះគ្រីស្ទយេស៊ូនឹងរងទុក្ខបៀតបៀន។ ហើយបើសិនជាអ្នក មកឯព្រះគ្រីស្ទ អ្នកនឹងមកមិនមែនដោយក្រុមជំនុំណាមួយ ឬនិកាយណាមួយ ឬ

គោលលទ្ធិណាមួយឡើយ។ អ្នកនឹងមកដោយព្រះលោហិត នោះជាផ្លូវតែមួយ។ ហើយអ្នកមិនអាចនាំនរណាម្នាក់មកជាមួយអ្នក អ្នកមកម្នាក់ឯងនឹងឈរលើការសារភាពផ្ទាល់និងជំនឿផ្ទាល់ខ្លួន។ អ្នកនឹងមិនស្ថិតនៅលើជំនឿគ្រូគង្វាល ឬជំនឿដើមរបស់អ្នកទេ។ អ្នកនឹងមកដោយបុគ្គល ពេលអ្នកមករកព្រះ! ហើយមានពេលជាច្រើនដែលជ្រើសជម្រើសល្ងីល្ងើរ។

60 ចុះបើឡុត ពេលគាត់ឃើញអ្វីៗ ងាយស្រួល...? គាត់ឃើញកន្លែងមានលុយ ច្រើននិងមានប្រជាប្រិយច្រើន ព្រោះគាត់ជាមនុស្សថ្មី និងជាមនុស្សឆ្លាតមានការអប់រំមានចិត្តសាស្រ្តច្រើននិងគាត់អាចធ្វើការជាក់លាក់តែនៅតែអាចរក្សាសាសនារបស់គាត់បាន។ គាត់គិត "ខ្ញុំមានជំនឿនៅក្នុងព្រះ ដូច្នេះខ្ញុំគ្រាន់តែទៅក្រុងសូដុមហើយខ្ញុំ—ខ្ញុំអាចរកលុយបានក្រៅច្រើន ហើយខ្ញុំក្លាយជាមនុស្សអស្ចារ្យម្នាក់ ប្រហែលក្លាយជាអ្នកអធិប្បាយអស្ចារ្យម្នាក់" ឃើញ អ្នកមានជម្រើសត្រូវធ្វើ។

61 ភាពជាសង្ឃរបស់ព្រះមានជម្រើសត្រូវរើស។ "ខ្ញុំនឹងទៅក្រុមជំនុំនេះទីនោះ។ អូ គ្រប់គ្នានៅក្នុងក្រុងគិតថានេះជាអ្វីសំខាន់! ហេតុអ្វី ចៅហ្វាយក្រុងជាសមាជិកក្រុមជំនុំនោះ" ឥឡូវ គាត់អាចទៅជាកម្មសិទ្ធិរបស់ក្រុមជំនុំដែលល្អ ប៉ុន្តែអ្នកនៅតែត្រូវតែកាត់ទោសក្រុមជំនុំ និងមនុស្សទាំងនោះតាមរយៈបទគម្ពីរ។ ជួនកាលពួកគេទៅដោយព្រោះ នោះជាប្រជាប្រិយភាព មនុស្ស—មនុស្សស្លៀកពាក់ប្រសើរជាងកន្លែងណាមួយទៀត។ ហើយនោះជាចំណុចដែលយើងបង្កើតកំហុស—ជៀសមិនរួច។ ឥឡូវចំណាំបែបនេះ។

62 ហើយអ័ប្រាហាំ អ្វីមួយដែលគាត់អាចធ្វើគឺរើសជម្រើសទីពីរ។ ហើយជួនកាលជម្រើសទីពីរប្រសើរជាងទីមួយ បើវាមើលទៅដូច្នោះ។ ចំណាំ មិនយូទេ ពេលឡុតបានឃើញក្រុងធំ គាត់មិនបានឃើញប្រពន្ធគាត់ ប្រែទៅជាសសរអំបិលឡើយ ទោះបីគាត់មិនបានឃើញភ្លើងឆេះក្រុងដំបូង។ ប៉ុន្តែអ័ប្រាហាំបានយកផ្លូវជាមួយព្រះអ្វីដែលព្រះអម្ចាស់ស្អប់ខ្ពើម គាត់ក៏ស្អប់ដែរ។ គាត់ស្នាក់នៅក្នុងវាលខ្សាច់។

63 ហើយ អ្វីទៅ ដែលសារ៉ានិយាយ...ឥឡូវសូមចងចាំ សារ៉ាស្រ្តីដែលស្អាតជាងគេក្នុងដែនដីទាំងអស់។ មិនមានស្រ្តីណាស្អាតដូចជាសារ៉ាឡើយ។ គ្រប់គ្នាឃើញនាង ស្រឡាញ់នាង។ ឥឡូវ នោះវាងាយប៉ុណ្ណាសម្រាប់សារ៉ាដែលងាយជ្រើសរើសជម្រើសបែបនោះ។ ប៉ុន្តែនាងជ្រើសរើសនៅជាមួយអ័ប្រាហាំ។

64 អូ ស្រ្តី កុំអនុញ្ញាតិឲ្យអារក្សបាំងភ្នែកអ្នក ក្នុងប្រជាប្រិយភាពនិងចូលរួម*នេះ* និង*នោះ*។ អ្នកស្នាក់នៅជាមួយព្រះគ្រីស្ទ! ព្រោះ ពេលវេលាជិតដល់ហើយ សេចក្តីហិនវិនាសធំនៅចាំ ពីមុខ អាក្រក់ជាងក្រុងសូដុម និងកូម៉ូរ៉ាផង សម្រាប់ប្រទេសនេះ។ សូដុមនិងកូម៉ូរ៉ានឹងល្អជាង។

65 ឥឡូវពេលអ័ប្រាហាំយកផ្លូវ ដែលព្រះជាម្ចាស់បានប្រទានមក និងមានភាពមិនមានជីវជាតិនៃទឹកដី គាត់មិនបានចម្រុងចម្រើនឡើយ។ ប៉ុន្តែគាត់ស្គាល់សេចក្តីម្យ៉ាងគាត់បម្រើព្រះនិងជឿដល់ព្រះ។

66 ដូច្នេះនៅថ្ងៃមួយមានមនុស្សបីនាក់ចូលមក ហើយពួកគេមានធូលីហុយនិងសម្លៀកបំពាក់ដាច់រហែក ហើយអ័ប្រាហាំមានចិត្តអាណិតដល់ពួកគេនិងនិយាយ "ចូលមក និង អង្គុយក្រោមដើមឱកមួយភ្លែតសិន។" ហើយពេលគាត់ឈរនៅទីនោះនិយាយជាមួយពួកគេគាត់ស្គាល់ថាពួកគេមិនមែនជាមនុស្សធម្មតាឡើយ។ តាមរបៀបគេនិយាយពួកគេមានភាពខុសប្លែក។ ហើយអ័ប្រាហាំចេញទៅសម្លាប់កូនគោនិងរៀបចំហើយសារ៉ាត្រូវធ្វើនំប៉ុងនិងរៀប ចំអិនស្រេចសំរាប់ចំអែតពួកគេ។

67 ឥឡូវ សូមចងចាំ ពីរនាក់នៃពួកគេជាទេវតា ទេវតាក្នុងសាច់ឈាមមនុស្ស និងម្នាក់ក្នុងចំណោមពួកគេជាព្រះអម្ចាស់ផ្ទាល់។ ហើយមួយអង្គដែលជាព្រះបែរខ្នងទៅតង់។

68 ហើយសារ៉ានៅក្នុងតង់។ ខ្ញុំចូលចិត្តឲ្យស្ត្រីនៅទីនោះ និងមិនចេញក្រៅដើម្បីបង្គាប់ប្តីឲ្យធ្វើអ្វីឡើយ និងគ្រប់ពេលមានគេមកលេង។ ប៉ុន្តែនាងនៅក្នុងតង់។ មិនសង្ស័យ ប្រហែលលាងចាន ឬ ធ្វើអ្វីមួយ។

69 ហើយអង្គដែលជាព្រះ ទ្រង់សម្លឹងមើលក្រុងសូដុមជានិច្ច ហើយទ្រង់មានបន្ទូលប្រាប់គេពីអ្វីដែលត្រូវធ្វើ។ ហើយទេវតាពីររូបបានចេញទៅដើម្បីផ្សាយដំណឹងល្អ។ ប៉ុន្តែមានមួយអង្គនៅខាងក្រោយ នោះជាអង្គមួយដែលជាព្រះហើយទ្រង់មានបន្ទូល "យើងនឹងមិនលាក់អ័ប្រាហាំពីអ្វីដែលយើងដឹងឡើយ ព្រោះគាត់នឹងក្លាយជាអ្នកស្នងកាន់កាប់ផែនដី។

70 អូ យើងមានសិទ្ធិនៅព្រឹកនេះ ក្រុមជំនុំ ដើម្បីស្គាល់អាថ៌កំបាំងនៃការយាងមករបស់ព្រះអម្ចាស់។ ព្រោះ "មានពរហើយអស់អ្នកដែលផ្សះផ្សាគេ ពួកគេនឹងហៅថាជាកូនរបស់ព្រះ។ មានពរហើយអស់អ្នកដែលស្រេកឃ្លាន ពួកគេនឹងបាន

ឆ្អែត។ មានពរហើយអ្នកមានចិត្តបរិសុទ្ធ ព្រោះពួកគេនឹងឃើញព្រះ។ មានពរហើយអ្នកមានចិត្តសុភាព ពួកគេនឹងគ្រងផែនដីជាមរតក"។ ដូច្នេះ បើសិនជាក្រុមជំនុំនៃព្រះដ៏មានព្រះជន្មនឹងគ្រងផែនដីជាមរតក នោះមិនមានអាថ៌កំបាំងដែលត្រូវលាក់ឡើយ។

71 "អស់ទាំងឪពុកប្រាប់ខ្ញុំ ខ្ញុំប្រាប់អ្នក" និយាយ ព្រះយេស៊ូវ ហើយពួកគេមិន ជឿទ្រង់ឡើយ។

72 ដូច្នេះក្នុងថ្ងៃនៃអ័ប្រាហាំ ដូចជាទ្រង់សំដៅលើពួកគេ ទ្រង់មានបន្ទូលថាអ័ប្រាហាំនិយាយទៅកាន់ទេវតា ហើយខ្នងរបស់ទ្រង់បែរទៅតង់ ហើយទ្រង់មានបន្ទូលប្រាប់អ័ប្រាហាំថាទ្រង់នឹងយាងមកជួបគាត់ជាមួយកូនម្នាក់។ ហើយសារ៉ានៅក្នុងតង់សើច។ ហើយទ្រង់មានបន្ទូល "ហេតុអ្វីបានជាសារ៉ាសើច?" តើទ្រង់កំពុងបង្ហាញអ្វី?"ហេតុអ្វីបានជាសារ៉ាសើច?" គឺមុនពេលបីបួនម៉ោងនៃការបំផ្លាញកើតឡើង។ មុនការបំផ្លាញ ដែលភ្លើងធ្លាក់មកពីលើមេឃនិងឆេះបំផ្លាញទីក្រុង ហើយទីសម្គាល់នោះបានកើតមានឡើង។

73 ហើយព្រះយេស៊ូវមានបន្ទូល "អ្នកប្រព្រឹត្តិខុសហើយ" ទៅកាន់ពេទ្យធំនៃអំណាចព្រះ ទៅកាន់ប្រជាជាតិកាន់សាសនា ដែលមានអ្នកជឿរាប់លាននាក់។ ទ្រង់មានបន្ទូល "អ្នកប្រព្រឹត្តិខុសហើយមិនស្គាល់បទគម្ពីរ ក៏មិនស្គាល់ឫទ្ធានុភាពព្រះផង"។ ទៅកាន់មនុស្សជំនាន់នោះ នោះជាពួកមនុស្សទទួលការហ្វឹកហាត់បានល្អ ជាពួកគ្រូនិងអ្នកបង្កើតក្រុមជំនុំ។ ពេលទារកកើតមក វាជាភាពស្រស់ស្អាតរបស់ក្រុមជំនុំ។ អ្នកត្រូវតែជាអ៊ីស្រាអែល។ ប្រាំបីថ្ងៃបន្ទាប់ពីកំណើតរបស់អ្នក វាជាការកាត់ស្បែក និងអ្នកជាជនជាតិអ៊ីស្រាអែលដែលត្រូវចាប់ផ្តើមមក។ ហើយពួកសង្ឃចេញពីលេវី ដែលទទួលបានការហ្វឹកហាត់ព្រះគម្ពីររាប់រយឆ្នាំ។ ប៉ុន្តែព្រះយេស៊ូវនៅតែមានព្រះបន្ទូល "អ្នកប្រព្រឹត្តិខុសហើយ មិនស្គាល់បទគម្ពីរផង!" ពួកគេស្គាល់បទគម្ពីរ តាមការរៀនក្នុងសៀវភៅរបស់គេ ពួកគេស្គាល់វាតាមរបៀបសាសនានិយមពួកគេស្គាល់តាមរបៀបទេវវិទ្យារបស់ពួកគេ។ ប៉ុន្តែព្រះយេស៊ូវមានបន្ទូល "អ្នកមិនស្គាល់វា គឺបទគម្ពីរ ក៏មិនស្គាល់ឫទ្ធានុភាពរបស់ព្រះផង។ បើអ្នកស្គាល់អ័ប្រាហាំ អ្នកនឹងស្គាល់ខ្ញុំ។ បើសិនអ្នកជាកូនអ័ប្រាហាំ អ្នកនឹងស្គាល់ខ្ញុំ ព្រោះអ័ប្រាហាំរីករាយដោយបានឃើញថ្ងៃរបស់ខ្ញុំ ព្រោះគាត់បានឃើញមុនថ្ងៃមកដល់។ ពេលខ្ញុំឈរជាមួយគាត់នៅពេលនោះ ក្នុង

រាងកាយសាច់ឈាម និងសម្ដែងការនេះ គាត់ដឹងថាគឺជាខ្ញុំ ហើយគាត់ហៅខ្ញុំថា 'អេឡូហ៊ីម'។ ប៉ុន្តែនៅទីនេះខ្ញុំធ្វើការដូចគ្នាចំពោះអ្នក ហើយអ្នកហៅខ្ញុំថា 'បៀលសេបាប់'"។

"អូ" ពួកគេនិយាយ "យើងមានអ័ប្រាហាំជាឪពុក?"

"ហៅអ័ប្រាហាំឪពុក 'របស់អ្នក'?"

74 ទ្រង់មានបន្ទូល "ហេតុអ្វីយើងជាកម្មសិទ្ធិនៃក្រុមជំនុំ។ យើងជាប្រជាជាតិកាន់សាសនា។ យើងជាមនុស្សអស្ចារ្យ យើងជារាស្ត្ររបស់ព្រះ យើងជារាស្ត្ររបស់ព្រះ!"

ព្រះយេស៊ូវមានបន្ទូល "អ្នកជាអារក្ខ វាជាឪពុករបស់អ្នក"

75 ខ្ញុំចង់ឲ្យជំនាន់នោះចំពោះរឿងនេះ។ ថ្ងៃនេះ ពេលមនុស្សរាប់លាននាក់ដែលប្រកាសជាគ្រីស្ទបរិស័ទ និងស្គាល់ពីព្រះ ថែមទៀតជាងហូតថិនថូត (Hottentot) ដែលអាចដឹងរាត្រីអេហ្ស៊ីប។ មានបុរសនិងស្ត្រីសព្វថ្ងៃនៅក្នុងជំនឿគ្រីស្ទាន ដែលប្រកាសថា ជាគ្រីស្ទាន មិនស្គាល់ពីគោលការណ៍នៃអំណាចនៃការរស់ឡើងវិញ និងមិនដែលភ្លក្សសេចក្ដីល្អ របស់ទ្រង់។ ពួកគេមិនដែលមានអារម្មណ៍ពីអំណាចទ្រង់។ ភ្នែករបស់ពួកគេងងឹតចំពោះសេចក្ដីពិត។

76 និយាយ "អ្នកខ្វាក់ហើយ អ្នកដឹកនាំខ្វាក់។ តើមិន...បើ...បើសិនដូចជាអ្នកខ្វាក់ដឹកនាំអ្នកខ្វាក់ តើពួកគេទាំងអស់មិនធ្លាក់ក្នុងរណ្ដៅទេរឺ?"

77 រួចពួកគេគិត "យើងជាគ្រិស្ទាន។ យើងជាអ្នកជឿ។ យើងជាកម្មសិទ្ធិក្រុមជំនុំដ៏ខ្ពស់។ គ្រូរបស់យើងជាគ្រូមានការអប់រំល្អបំផុត" ហើយព្រះយេស៊ូវមានបន្ទូលប្រាប់ពួកគេថា ពួកគេមិនស្គាល់បទគម្ពីរផង។

78 មើលយ៉ាងណាដែលព្រះបានលាក់វាពីភ្នែកមនុស្សមានប្រាជ្ញានិងអ្នកវៃឆ្លាត ហើយបង្ហាញវាដល់ទារកដែលជាការគួរហាត់រៀនយ៉ាងណា? អូ អំណាចអស្ចារ្យ និងភាពមិនកំណត់បានរបស់ព្រះ! តើល្អយ៉ាងណាអស់អ្នកមានបំណងចិត្តដើរដោយសុចរិតនៅពីមុខទ្រង់! ទ្រង់មិនលាក់ទុកអ្វីដែលល្អឡើយ។

79 ហើយក្នុងការមើលឃើញពេលប្រជាជាតិរបស់យើង ពិភពលោករបស់យើងបានពុកផុយជាមួយអ្វីដូចគ្នា!

80 ព្រះយេស៊ូវមានព្រះទ័យចង់កែតម្រង់ពួកគេឲ្យបានត្រង់។ ពួកគេនិយាយ "អូ អ័ប្រាហាំជាឪពុករបស់យើង។ ហើយយើងនឹងនៅក្នុងសិរីរុងរឿងកុំបារម្ភពីការនោះ ព្រោះយើងជឿងដល់ព្រះ។ យើងជាសាស្រ្តាចារ្យ និងយើងជឿដល់ព្រះហើយយើង បង្រៀនមនុស្សរបស់យើង។ ហើយអ្នកជានរណា ដែលមកទីនេះជាមួយអាថ៌ —អាថ៌កំបាំងទីសម្គាល់តិចតួចនិង ព្យាយាមហៅវាថាជាព្រះ? អ្នកមិនជាអ្វីក្រៅពី បៀ សេបាប់ឡើយ" អ្នកគឺ ពួកគេមានគោលលទ្ធិនិងនិកាយរបស់គេ។

ព្រះយេស៊ូវបានប្រាប់ពួកគេ "អ្នកជាវិញ្ញាណអាក្រក់" គិតអំពីវា!

81 ហើយខ្ញុំចូលចិត្ត ជំនាន់នោះបែបនេះ សព្វថ្ងៃពេលយើងមានក្រុមជំនុំដែល មានមនុស្សចូលរួមរាប់លាន បើមានតែ១០នាក់ក្នុងចំនោម១០០០នាក់។ នោះ ព្រះយាងមកគង់ក្នុងក្រុមជំនុំរបស់ទ្រង់ម្តងទៀតនិងធ្វើការដូចគ្នា គឺទ្រង់ធ្វើអង្គ ទ្រង់ផ្ទាល់ឲ្យដូចកាលពីម្សិលមិញ ថ្ងៃនេះ និងរៀងរហូត។ ហើយមនុស្សបាន បែរខ្នងចេញពីវា ជានិច្ច ខ្លះដោយសារប្រជាប្រិយភាព ខ្លះរក្សាវាពីជម្រើស។ វា ជាការបង្ខំដល់មនុស្ស! អ្នកត្រូវតែធ្វើការសម្រេចចិត្ត។ អ្នកមិនអាចជាអព្យាក្រិត្យ ឡើយ។ អ្នកត្រូវតែនិយាយ "បាទ" ឬ "ទេ"។ អ្នកមិនត្រូវចាកចេញពីទ្វានោះដូចជា មនុស្សដដែលពេលអ្នកចូលមកឡើយ។ អ្នកមិនអាចធ្វើបែបនោះឡើយ។ អ្នកមាន ជម្រើសត្រូវធ្វើ។ ធ្វើវាសម្រាប់ព្រះគ្រិស្ទនៅព្រឹកនេះ។

82 ពួកគេគិតថាគ្រប់យ៉ាង ជាកម្មសិទ្ធិរបស់ ក្រុមជំនុំនឹងទទួលបានការ សង្គ្រោះ។ ព្រះយេស៊ូវមានបន្ទូលថា "តែឯទ្វារដែលនាំទៅឯជីវិតនោះតូចហើយ ចង្អៀតវិញក៏មានមនុស្សតិចណាស់ដែលអាចរកឃើញវា"។

83 សូមឲ្យខ្ញុំព្រមានអ្នកនៅព្រឹកនេះ ក្រុមជំនុំ ចូរប្រយ័ត្ន។ វាត្រូវការពេលវេលានៅ ថ្ងៃនេះ ក្នុងសេចក្តីសុចរិតផ្ទាល់ខ្លួនរបស់យើង ជំនាន់នៃការស្អប់ចិត្តផ្ទាល់ខ្លួនដែល ជាការកំពុតដែលយើងកំពុងរស់នៅ។ ជាពេលដែលមនុស្សប្រុស ស្រីឈរក្នុង ព្រះវិហារនិងនៅក្នុងកៅអី និងច្រៀងចម្រៀងព្រះ ហើយចេញពីព្រះវិហារក៏ជក់បារី និងផឹកស្រាវីស្គីនិងចេញទៅរាំនិង—និងរស់នៅសម្រាប់លោកកិយ និងនិយាយ រឿងកំប្លែងស្មោគគ្រោគ កំប្លែងកខ្វក់ហើយហៅខ្លួនពួកគេថា "គ្រីស្ទាន" ពេលមនុស្ស ប្រុសនិងស្រីអាចដើរពីតុវេទិកា ឬចេញពីក្រុមជំនុំ និងកន្លែងនៃអំណាចនៃការរស់ ឡើងវិញ កន្លែងដែលជាទីសម្គាល់នៃព្រះមេស្ស៊ីកំពុងធ្វើចលនាចំណោមពួកគេ ហើយមិនបានមានជីវិតថ្មីក្នុងព្រះគ្រីស្ទ នោះមានអ្វីមួយខុសហើយ។ ពេលដែល

ក្រដាសអាចរុំបាន និងពីឆ្នេរមួយទៅឆ្នេរមួយ ត្រឡប់ចុះឡើងទៅក្រោយទៅមុខ ពីតំបន់កកត្រជាក់នៅប៉ូលខាងជើងទៅកាន់តំបន់ព្រៃត្រូពិកខាងត្បូង ព្រះបញ្ជូនវា តែមនុស្សបែរខ្នងដាក់វាជានិច្ច។ រួចតើយើងនិយាយថា តើយើងអាចធ្វើអ្វីបាន? យើងត្រឡប់ទៅបទគម្ពីរវិញដែលទ្រង់មានបន្ទូល "តែឯទ្វារដែលនាំទៅឯជីវិត នោះតូច ហើយចង្អៀតវិញក៏មានមនុស្សតិចណាស់ដែលរកផ្លូវនោះឃើញ។"

84 ទ្រង់មានបន្ទូល "ដ្បិតកាលណាកូនមនុស្សមក នោះនឹងបានដូចជានៅជំនាន់លោកណូអេដែរ" ចូរស្តាប់ នៅថ្ងៃរបស់ណូអេ ពិភពលោកមានមនុស្សច្រើនដូចសព្វថ្ងៃ។ វិទ្យាសាស្ត្ររបស់គេរីកមកលើយើង។ ពួកគេសង់ស្ពីនសឺស(Sphinxes) និងពីរ៉ាមីត និងធ្វើអ្វីដែលយើងមិនអាចធ្វើនៅសព្វថ្ងៃ។ ជាការរីកចម្រើន អស្ចារ្យ មនុស្សឆ្លាត។ ហើយចងចាំ វិទ្យាសាស្ត្រនិយាយសព្វថ្ងៃ "វាមានពេលមួយនាទីមុនកណ្តាលយប់"។ វាមានពេលមួយនាទីមុននាឡិកាវាយចំម៉ោងសេចក្តីស្លាប់។ វាមកក្រោយយើងគិត។ ខ្ញុំសង្ឃឹម—ទុកចិត្តថាព្រះវិញ្ញាណបរិសុទ្ធនឹងពន្លិចសេចក្តីនេះទៅក្នុងគ្រប់ចិត្តរបស់អ្នកជឿ "ដូចសម័យណូអេ!"

85 តើមនុស្សប៉ុន្មាននាក់ទទួលបានការសង្គ្រោះនៅសម័យណូអេ? ប្រាំបី ប្រាំបីនាក់ក្នុងចំណោមមនុស្សរាប់លាននាក់។ ទ្រង់មានបន្ទូល "ដ្បិតកាលណាកូនមនុស្សមក នោះនឹងបានដូច"។

86 "ហើយដ្បិតកាលណាកូនមនុស្សមក នោះនឹងបានដូចសម័យ ក្រុងសូដុម។" មនុស្សជាងមួយម៉ឺននាក់ មានតែបីនាក់ទទួលការសង្គ្រោះ។

87 អ្នកនឹងនិយាយមកកាន់ខ្ញុំ "គ្រូអធិប្បាយ ចុះមនុស្សរាប់ពាន់នាក់ដែលនឹងមកជាមួយទ្រង់?" តឡូវបងប្អូន នោះគឺបូកបញ្ចូលគ្នាជាច្រើនជំនាន់។

88 ខ្ញុំនឹងភ្ញាក់ផ្អើលបើមានមនុស្សជាងមួយឡចេញមកពីជំនាន់នេះ "តែឯទ្វារដែលនាំទៅឯជីវិត នោះតូច ហើយចង្អៀតវិញ ក៏មានមនុស្សតិចណាស់ដែលរកផ្លូវនោះឃើញ"។

89 អូ ខ្ញុំស្គាល់ក្រុមជំនុំ អ្វីដែលគេនិយាយ "បើសិនជាអ្នកចុះឈ្មោះក្នុងសៀវភៅ និងអ្នកក្លាយជាសមាជិក *នេះ* អ្នកបានត្រឹមត្រូវហើយ" មិនមានបទគម្ពីរដែលនិយាយបែបនោះឡើយ។ បើគ្រប់យ៉ាងមានឈ្មោះរបស់វាលើសៀវភៅ និងក្នុង—ក្រុមជំនុំ នឹងមានមនុស្សរាប់ពាន់លាន នៃរាប់ពាន់លានដង គ្រប់យ៉ាងនឹងចូល

ទៅ។ ដូច្នេះគ្រប់ប្រភេទវិញ្ញាណក៏ទៅទីនោះដែរ និងអ្វីជាលក្ខខ័ណរបស់ស្ថានសួគ៌ វាយ៉ាងណាទៅ? គិតពីវាឥឡូវ។

90 ដូចមានអ្នកនិយាយមកកាន់ខ្ញុំថា "ឥឡូវរងចាំមួយនាទី បងប្អូនប្រុសប្រាន ហាំ។ *បែបនេះ–និង–បែបនេះ* ខ្ញុំឮពួកគេនិយាយភាសាដទៃ ខ្ញុំដឹងថាពួកគេអាច ធ្វើបាន"។

91 នោះមិនមានន័យថាពួកគេនឹងអាចធ្វើបានទាំងអស់នោះទេ។ ប៉ូលនិយាយ ក្នុងកូរិនថូសខ្សែទីមួយជំពូក13 " ទោះបើខ្ញុំចេះនិយាយ ជាភាសារបស់មនុស្សជាតិ ទាំងប៉ុន្មាន និងភាសារបស់ពួកទេវតាផង តែគ្មានសេចក្តីស្រឡាញ់ នោះខ្ញុំបាន ត្រឡប់ដូចជាលង្ហិនដែលឮខ្ទរ ឬដូចជាឈឹង ដែលឮទ្រហឹងប៉ុណ្ណោះ"។

92 "អូ ខ្ញុំបានទៅការប្រជុំ*បែប–នេះបែប–នេះ*។ អូ គាត់ធ្វើបានអស្ចារ្យ ករងារធំ។ ខ្ញុំឃើញគាត់អាចធ្វើឲ្យមនុស្សខ្វាក់អាចមើលឃើញ"

93 តែគាត់ក៏អាចជាអ្នកវង្វេងដែរ "នៅថ្ងៃនោះ នឹងមានមនុស្សជាច្រើននិយាយ មកខ្ញុំថា 'ឱព្រះអម្ចាស់ៗអើយតើយើងខ្ញុំមិនបានទាយដោយនូវព្រះនាមទ្រង់ទេ ឬអី? ហើយដេញអារក្សដោយនូវព្រះនាមទ្រង់ទេឬអី? ព្រមទាំងធ្វើការឫទ្ធិបារមី ជាច្រើន ដោយនៅព្រះនាមទ្រង់ទេឬអី?' នោះទ្រង់នឹងបន្ទូលថា អញមិនដែល បានស្គាល់ឯងរាល់គ្នាទេ នែ ពួកទទឹងច្បាប់អើយ ចូរថយចេញពីអញទៅ។" "តែ ឯទ្វារដែលនាំទៅឯជីវិត នោះតូច ហើយចង្អៀតវិញ ក៏មានមនុស្សតិចណាស់ដែល រកផ្លូវនោះឃើញ"។

94 សូមឲ្យខ្ញុំផ្តល់នូវការគណនាខ្លះៗដែលអង្រួនអ្នកបាន។ តាមរយៈវេជ្ជសាស្ត្រ បែបវិទ្យាសាស្ត្រ ក្នុងក្រុងឈីកាហ្គោ តាមរយៈស្ថិតិដុកទ័រ មានករណីរំលូតកូន បីម៉ឺននាក់ក្នុងឈីកាហ្គោតែមួយប៉ុណ្ណោះ ក្នុងរយៈពេលសាមសិបថ្ងៃ នោះជាអ្វី ដែលដុកទ័រមាន។ ចុះចំនួនប៉ុន្មានដែលនៃថ្នាំតូចៗទាំងនេះនិងអ្វីដែលពួកគេធ្វើ នៃករណីរំលូតកូន?

95 ស្ថិតិបង្ហាញថានៅ ក្នុងសហរដ្ឋអាមេរិក មានកូនមិនស្របច្បាប់ ជាច្រើនកើតមកច្រើនជាងកូនកើន មកមិនបានរៀបការត្រឹមត្រូវ។ តើ អ្នកដឹងទេថាព្រះគម្ពីរនិយាយថាក្នុងចោទិយកថា14:2 ថា "ត្បិតកូនមិន ស្របច្បាប់ វានឹងមានរយៈពេលបួនរយឆ្នាំទើបផុត"? ចៅទួត ចៅទួត

ថៅទូត ថៅទូត ថៅទូតរបស់ពួកគេមិនអាចឈរក្នុងក្រុមជំនុំរបស់ព្រះអម្ចាស់ឡើយ បួនរយឆ្នាំ ដប់ជំនាន់។ សែសិបឆ្នាំក្នុងជំនាន់។ ជីតាទូត-ជីតាទូត-ជីតាទូត-ជីតាទូត-ជីតាទូត-ជីតាទូត-ជីតាទូត-ជីតាទូតរបស់ពួកគេ ជាកូនមិនស្របច្បាប់ គាត់ជារូបភាពខាងក្រៅ! ឥឡូវ អ្វីវិញ? បង្ហាញខ្ញុំមើលថាវាប្តូរត្រង់ណា។

96 តើយើងមកត្រង់ណា? ហើយ ឥឡូវ ភាពមិនស្របច្បាប់ ព្រោះការកំផិត និងស្ត្រីមានបាបស្លៀកពាក់ចេញក្រៅដូចបុរស នោះជាការស្អប់ខ្ពើមក្នុងព្រះនេត្ររបស់ព្រះ អ្នកជក់បារី អ្នកផឹកស្រា ហៅថាជាគ្រីស្ទបរិស័ទពិត។ ព្រះបានហាមក្រុមនៃពួកពេស្យាទាំងនេះ! នោះត្រូវហើយ។ រួចហៅខ្លួនឯងថាជាគ្រីស្ទានឬ? មិនគួរឲ្យឆ្ងល់ទេដែលព្រះយេស៊ូមានបន្ទូល "តែឯទ្វារដែលនាំទៅឯជីវិត នោះតូច ហើយចង្អៀតវិញ ក៏មានមនុស្សតិចណាស់ដែលរកផ្លូវនោះឃើញ។"

97 ពួកគេមិនបន្ទាបខ្លួន។ ពួកគេដូចម្សៅ។ មើល ពេលដាវីឌត្រូវបានបង្ហាញពីបាបរបស់គាត់ដែលបានធ្វើ គាត់ប្រែចិត្តភ្លាម ហើយព្រះទ្រង់ស្រលាញ់គាត់ចំពោះវា។ អ្នកប្រាប់ពួកគេពីបាបរបស់គេ គេនឹងនិយាយ "ខ្ញុំមិនពួននៅកន្លែងងងឹតទៀតឡើយ។" ហេតុអ្វី? ពួកគេមានកន្លែងច្រើនត្រូវទៅពួកគេអាចទៅកន្លែងរូងដែលមិនស្របច្បាប់ ហើយប្រព្រឹត្តិអាក្រក់ជាដើម។ ប៉ុន្តែវាជាពេលវេលាដែលគ្រូអធិប្បាយដាក់គ្រឿងសឹករបស់ព្រះ និងអធិប្បាយព្រះបន្ទូល មិនមែនដោយលំៗឡើយ គឺដំណឹងល្អ។ មនុស្សគួរតែបន្ទាបខ្លួន។

98 មិនមានភាពស្មោះស្ម័គ្រ ចំណោមគ្រីស្ទានទៀតឡើយ។ ពួកគេចង់និយាយ "ខ្ញុំជាមេតូឌីស្ទ ខ្ញុំជាបាបទីស្ទ ខ្ញុំជាពេនទីកុស្ទ" នោះមិនមានន័យប្រងប្អូនប្រុសប្រានហាំចង្អុលម្រាម—Ed។] *នោះ*គឺព្រះ។

99 "ខ្ញុំនិយាយភាសាដទៃ ខ្ញុំធ្វើការអស្ចារ្យ" យើងបានដាក់ ការសង្កត់ធ្ងន់ទៅលើនោះដែលនោះជាម្នាក់ក្នុងចំណោមភាព ងងឹតដែលពួកគេអាចធ្វើ។ ប្រាកដ។ ភ្លៀងធ្លាក់លើមនុស្សសុចរិតនិងទុច្ចរិត។ ភ្លៀងស្រោចស្រប់ទាំងលើដំណាំនិងលើស្រូវស្រងែរ៉យ(Roy)។ ភ្លៀងដដែល ព្រះវិញ្ញាណបរិសុទ្ធដដែលធ្លាក់លើមនុស្ស។ នោះមិនមានន័យថា...និស្ស័យរបស់ពួកគេផ្លាស់ប្តូរឡើយពីក្នុងមកក្រៅ។ មិនមែនជាការបង្ហាញខាងក្រៅ ឬ បញ្ជាក់ឡើយ ប៉ុន្តែនៅក្នុងព្រះវិញ្ញាណនៃព្រះមាន

ព្រះជន្មដែលធ្វើឲ្យមនុស្សបានកើតជាថ្មី និងបន្ទាបចិត្តរបស់គាត់ ឬចិត្តរបស់នាង ពី មុខព្រះ។

100 អ្នកនិយាយ "គ្រូអធិប្បាយ លោកមានន័យថា ចង់ប្រាប់ខ្ញុំថាអ្នកសង្ស័យមនុស្សមួយចំនួនក្នុងចំណោមរាប់លាននាក់នេះ និងមនុស្សបួនពាន់លាននាក់ក្នុងពិភពលោកឬ?" ខ្ញុំសង្ស័យថាតើនឹងមានមនុស្សមួយចំនួន ដែលនឹងបានលើកឡើង។ គិតវាទៅ! ខ្ញុំប្រាប់អ្នកពីអ្វីដែលព្រះយេស៊ូវ មានបន្ទូលត្រង់នេះជាដំណឹងល្អ។ គិតចុះ!

101 វាត្រូវជាអ្វី? ព្រោះភាពអសីលធម៌មានក្នុងចំណោមមនុស្ស កូនមិនស្របច្បាប់ចាប់ផ្ដើមកើតមក ដែលនាំឲ្យប្រឡាក់។ ឃើញ យើងគួរឈរត្រង់នេះជាយូម៉ោងដាក់អ្វីទាំងអស់នោះ ហើយអ្នកអាចឃើញថា យើងកំពុងរស់នៅក្នុងអ្វីដែលពុកផុយ ខូចខាតជំនាន់មនុស្សរលួយដល់ស្នូល។ មិនចម្លែកទេដែលគេមិនអាចឃើញទីសម្គាល់មិនចម្លែកទេដែលគេមិនអាចឮដំណឹងល្អ ពួកគេក្លាយជារឹងទទឹង ប៉ុន្តែគ្រាន់តែជាសាសនានិងការជឿស៊ប់ប៉ុណ្ណោះ។

102 តើព្រះយេស៊ូវមិនបានមានបន្ទូលទេរឺថា "ព្រះវិញ្ញាណបើកសម្ដែង នៅជាន់ក្រោយបង្អស់ នឹងមានគ្រាលំបាកណាស់ ដ្បិតនៅគ្រានោះ មនុស្សនឹងស្រឡាញ់តែការសប្បាយខ្លួនឯង ជាជាងស្រលាញ់ព្រះ មានចិត្តមិនបរិសុទ្ធ គ្មានអធ្យាស្រ័យ និយាយបង្កាច់គេ មិនចេះទប់ចិត្ត មានចិត្តសាហាវ មិនចូលចិត្តនឹងការល្អ គេមានឫកពាជាអ្នកគោរពប្រតិបត្តិដល់ព្រះ"? ឃើញទេ? អូ អ្នកអាចស្រែកប្រាកដណាស់។ អ្នកអាចនិយាយភាសាដទៃ ប្រាកដណាស់។ មានជំនឿអាចដេញអារក្សប្រាកដណាស់។ ប៉ុន្តែនោះមិនមែនជាអ្វីដែលយើងនិយាយឡើយ។

103 ដូច្នេះអ្នកអាចនិយាយមកកាន់ខ្ញុំ "បងប្អូនប្រុសប្រានហាំ អ្វីទៅជាទីសម្គាល់គ្រីស្ទាន? នរណានឹងបានសង្គ្រោះ? ចុះអ្នកវិញ បងប្អូនប្រុសប្រានហាំ?" ខ្ញុំទុកចិត្តការនោះចំពោះព្រះ។ ខ្ញុំមិនដឹងទេ។ ខ្ញុំជឿថាខ្ញុំនឹងបាន។ ខ្ញុំប្រៀបធៀបជីវិតខ្ញុំរាល់ថ្ងៃ ជាមួយព្រះបន្ទូល។ បើវាមិនរស់នៅតាមព្រះបន្ទូលនេះ ដូច្នេះមានអ្វីដែលខុសប្លែកហើយ ខ្ញុំនឹងត្រឡប់ទៅរកអ្វីត្រូវវិញ។

104 "ល្អ" និយាយ "បងប្អូនប្រុសប្រានហាំ ពេលមនុស្សនិយាយភាសាដទៃ តើនោះមិនមានន័យថាពួកគេទទួលបានការសង្គ្រោះទេរឺ?" ទេ លោក! ទេ ប្រាកដណាស់! ខ្ញុំឮមេធ្មប់និងមនុស្សចេះមន្តអាគមនិយាយភាសាដទៃ និងអ្វីដែលមិន

យល់។ ខ្ញុំឃើញមនុស្សនិយាយភាសាដទៃនិងរស់ជាមួយប្រពន្ធគេ។ ខ្ញុំឃើញមនុស្សនិយាយភាសាដទៃ ប៉ុន្តែស្រែកលោតចុះលោតឡើងដូចភ្លើងឆេះផ្ទះ និងចេញទៅក្រៅនិងកោងរៀច និងលួចគេ និយាយកុហក និងគ្រប់យ៉ាង។ តើអ្នកអាចរំពឹងបែបនោះយ៉ាងណា? ទេ អត់ទេ។

105 ជាកម្មសិទ្ធិក្រុមជំនុំ ចាស់ទុំក្នុងព្រះវិហារ ក៏អាចប្រឡាក់បានដែរ។ ហេតុអ្វីអ្នកគិតថាគេទិញសាំងថ្ងៃអាទិត្យរឺ? ទេ។ ប៉ុន្តែ នៅថ្ងៃច័ន្ទធ្វើអ្វីដែលកខ្វក់និងពុកផុយ និងចុះទាប។ ព្រះគង់ក្នុងចិត្ត មិនមែនខាងក្រៅឡើយ ជាអ្វីមកពីចិត្ត។

106 "តែឯទ្វារដែលនាំទៅឯជីវិត នោះតូច ហើយចង្អៀតវិញ ក៏មានមនុស្សតិចណាស់ដែលរកផ្លូវនោះឃើញ" ដូចនៅសម័យណូអេដែរ គឺប្រាំបីនាក់ក្នុងចំណោមរាប់លានទាំងនោះ ក៏ដូចជាសម័យក្រុងសូដុមដែរ បីនាក់ក្នុងចំណោមមនុស្សរាប់លាននាក់ ដូច្នេះពេលបុត្រមនុស្សយាងមកក៏ដូច្នោះដែរ។

107 ហើយអ្នកឃើញភាពពុករលួយ ដែលយើងនៅក្នុងនោះ។ អ្នកឃើញរបៀបអ្វីដែលជាការស្រមៃ មនុស្សចេញពីនោះ ហើយអារក្សបង្កើតគ្រូគង្វាលឆ្លាតឈរនៅតុវេទិកានិងឲ្យមនុស្សទៅក្បែរវា។

108 នៅថ្ងៃផ្សេង មានមនុស្សនិយាយ "ខ្ញុំមិនឲ្យអ្នកឈរលើវេទិការរបស់ខ្ញុំឡើយ អ្នកអាចធ្វើឲ្យស្រីៗរបស់ខ្ញុំទៅជាឆ្កួត" ទេ ពួកគេឆ្កួតស្រេចហើយ។ ខ្ញុំនឹងនាំពួកគេឲ្យមានគំនិតត្រឹមត្រូវ ប្រាប់ពួកគេ ឲ្យបោះបង់ ការស្លៀកពាក់បែបនោះ។ ហើយ ល្អត្រូវមាននរណាម្នាក់ប្រាប់ពួកគេ។

109 ខ្ញុំនិយាយទៅកាន់ប្រពន្ធរបស់ខ្ញុំ "ខ្ញុំខ្លួនឯងឆ្កួតមែនទេ? ខ្ញុំវង្វេងស្មារតីរឺ? ឬមានបញ្ហាអ្វីជាមួយខ្ញុំ?" មានអ្វីនៅខាងក្នុងមិនអាចទប់ស្ងៀម។ ខ្ញុំត្រូវតែប្រាប់វា ខ្ញុំមិនខ្វល់ថាមានគេនិយាយអ្វីឡើយ។

110 និយាយ "អ្នកនឹងបំផ្លាញព័ន្ធកិច្ចរបស់អ្នក" ល្អ ព័ន្ធកិច្ចណាមួយដែលដំណឹងល្អបំផ្លាញ គួរតែត្រូវបំផ្លាញ។

ព្រះប្រទានឲ្យយើងច្បាស់លាស់ដើម្បីឈរសម្រាប់អ្វីជាសេចក្តីពិតនិងប្រាប់សេចក្តីពិតពីវា! វាជាបាប ភាពថោកទាប!

111 "ទ្វារដែលនាំទៅឯជីវិត" ព្រះយេស៊ូវមានបន្ទូល "ទ្វារតូចហើយចង្អៀត" ហើយអ្នកដែលគិតថារាប់លាននាក់ ហើយអ្នកជាមេតូឌីស្ទ បាបទីស្ទ ព្រីប៊ី

សធីរៀន ពេនទីកុស្ទនឹងបានចូល អ្នកឆ្លុតហើយនៅថ្ងៃនោះ។ ព្រះយេស៊ូវមានបន្ទូល "មនុស្សជាច្រើននឹងមកអង្គុយក្នុងនគរ និយាយ 'ខ្ញុំមានសិទ្ធិនៅទីនេះ'" ទ្រង់មានបន្ទូល "ប៉ុន្តែកូននៃអាណាចក្រនឹងបោះអ្នកចោល។ អ្នកនឹងយំនិងថ្ងូរសង្កៀតធ្មេញ" វាជាការល្អត្រូវធ្វើបញ្ជីរនៅព្រឹកនេះចុះ គ្រីស្ទាន។ វានឹងមានដប់ដងមួយលានដង ពាន់លានដងនៃចំនួនគ្រីស្ទាន និងជាប់គាំងក្នុងជីវិត ដែលចូលខុសទ្វារ។ ព្រះយេស៊ូវមានបន្ទូលដូច្នេះ។

"តើមានប៉ុន្មាននាក់នឹងចូលទៅ?"

112 ខ្ញុំមិនដឹងថាប៉ុន្មាននាក់នឹងចូលទៅ។ តែរឿងដែលសំខាន់នោះគឺ "ព្រះអង្គអើយ សូមឲ្យទូលបង្គំជាម្នាក់ក្នុងចំណោមពួកគេ!" ហ្នឹងហើយ។ ទ្រង់ជាចៅក្រម "សូមឲ្យទូលបង្គំជាម្នាក់ក្នុងនោះដែរ"។

113 អ្នកនិយាយ "បងប្អូនប្រុសប្រានហាំ តើអ្នកអាចប្រាប់ដូច្នេះយ៉ាងម៉េចជាគ្រីស្ទានស្រេចហើយ?"

114 ខ្ញុំមិនដឹងទេ។ ប៉ុន្តែចូរឲ្យខ្ញុំប្រាប់អ្នកពីអ្វីដែលព្រះគម្ពីរនិយាយ។ ប្រាកដណាស់អ្នកជឿបែបនោះ។ ពេលព្រះវិញ្ញាណបរិសុទ្ធត្រូវបានបញ្ជូនមកផែនដី ព្រះមានបន្ទូលតាមរយៈព្រះវិញ្ញាណបរិសុទ្ធ។ ទ្រង់បញ្ជូនទេវតាទៅ—ទៅ ដំបូង។ ហើយទ្រង់មានបន្ទូល "ព្រះយេហូវ៉ាទ្រង់មានព្រះបន្ទូលទៅអ្នកនោះថា ចូរដើរបង្ហួតទីក្រុង គឺបង្ហួតកណ្តាលក្រុងយេរូសាឡិមទៅ ហើយធ្វើទីសំគាល់នៅថ្ងាសរបស់ពួកមនុស្ស ដែលដកដង្ហើមធំហើយថ្ងូរ ដោយព្រោះការគួរស្អប់ខ្ពើមដែលមនុស្សប្រព្រឹត្តនៅក្នុងទីក្រុងនោះ"។

115 អ្វីជាគួរស្អប់ខ្ពើម? ស្ត្រីដែលស្លៀកពាក់សម្លៀកបំពាក់សម្រាប់បុរស។ វាធ្វើឲ្យព្រះមិនសព្វព្រះទ័យ។ តើអ្នកមិនធ្លាប់នៅជិតអ្វីដែលគួរខ្ពើមទេវី? តើធ្វើឲ្យអ្នកឈឺយ៉ាងណា! អ្នកមិនអាចទ្រាំបានទេ។ ស្ត្រីដែលស្លៀកសម្លៀកបំពាក់បុរសនោះជារបៀបធ្វើឲ្យព្រះស្អប់ខ្ពើម អ្នកអាចច្រៀងចម្រៀងក្នុងក្រុមចម្រៀងអធិស្ឋានរៀងរាល់ថ្ងៃ ឬរស់នៅសម្រាប់ព្រះរៀងរាល់ថ្ងៃ អ្នកត្រូវបានកាត់ទោសនៅក្នុងព្រះវត្តមានព្រះហើយ។ នោះជាអ្វីដែលបទគម្ពីរបាននិយាយ។ "ស្អប់ខ្ពើម"ហើយអ្នកកាន់ខ្ជាប់បែបនោះនឹងមានចំណែកនោះ។

116 ព្រះប្រទានព្រះគុណឲ្យយើងឈរទាស់ប្រឆាំងវា។ បើអ្នកត្រូវឈរដោយខ្លួនឯង ឈរនៅទីនោះនឹងក្តោប ព្រះបន្ទូលរបស់ព្រះក្នុងដៃ។ វាមិនដែលបរាជ័យឡើយ។

117 ឥឡូវយើងបានមកដល់សម័យមួយ ជាកន្លែង ភាពស្អប់ខ្ពើមរបស់មនុស្ស។ ហើយទេវតាបានចេញទៅហើយវាយត្រាម្តងទៀត។ រកខ្ញុំនូវមនុស្សម្នាក់នៅជេហ្វើសាន់វីល បើអ្នកចង់ដឹងថានរណានឹងត្រូវធ្វើ សូមរកមនុស្សម្នាក់ឲ្យខ្ញុំក្នុងក្រុងដែលដកដង្ហើមធំនិងយំ មានការខ្វល់ខ្វាយ និងបារម្ភ និងអធិស្ឋានពីភាពស្អប់ខ្ពើមដែលបានធ្វើក្នុងក្រុង។ តើអ្នកអាចលើកដៃដាក់លើមនុស្សម្នាក់ទៀតបានទេ? រួចយកខគម្ពីរនេះ "តែឯទ្វារដែលនាំទៅឯជីវិត នោះតូច ហើយចង្អៀតវិញ ក៏មានមនុស្សតិចណាស់ដែលរកផ្លូវនោះឃើញ។" នោះគឺតែមួយប៉ុនោះដែលទទួលបានការបោះត្រា។

118 អូ ខ្ញុំអាចបង្ហាញអ្នកពីមនុស្សជាច្រើនទៅព្រះវិហារ។ ខ្ញុំអាចបង្ហាញអ្នកពីមនុស្សជាច្រើនច្រៀងចម្រៀងក្រុម។ ខ្ញុំអាចបង្ហាញអ្នកពីមនុស្សជាច្រើនបង្រៀនថ្នាក់ថ្ងៃអាទិត្យ។ ខ្ញុំអាចបង្ហាញអ្នកដឹកនាំ—នៃសង្គមធំៗ។ ខ្ញុំអាចបង្ហាញអ្នកពីមនុស្សជាច្រើនស្រែក និយាយភាសាដទៃ និងធ្វើការក្នុងដំណឹងល្អជាច្រើន។

119 ប៉ុន្តែបង្ហាញខ្ញុំពីមនុស្សម្នាក់ដែលក្នុងជំរៅចិត្តរបស់គេ យំសោកដោយសារបាបក្នុងលោកិយ! បង្ហាញខ្ញុំគ្រូអធិប្បាយសព្វថ្ងៃហ៊ានឈរនិងកាត់ទោសពួកនិកាយ។ បង្ហាញខ្ញុំគ្រូអធិប្បាយ ដែលនឹងឈរប្រឆាំង និងថ្កោលទោសពួកនិកាយ។ គាត់គួរតែកុំធ្វើអី គាត់នឹងត្រូវគេទាត់ចេញ នោះជាឆ្នាំងបាយរបស់គាត់។

120 មិនឆ្ងល់ទេដែល ប៊ីលីហ្គ្រាហាំ(Billy Graham)ប្រាប់ជេកម័រ(Jack Moore) ថា កុំមើលថាតើការប្រជុំរបស់ខ្ញុំយ៉ាងម៉េច និយាយ "គាត់មិនមែនជា បាបទីស្ទ ក៏មិនមែនជាមេតូឌីស្ទ ឬពេនទីកុស្ទ" និយាយ "ហើយពួកគេទាំងអស់ទាស់នឹងគាត់" ប្រាកដណាស់ខ្ញុំមិននិយាយបែបនោះឡើយ...ហេតុផលដែលខ្ញុំនិយាយ ខ្ញុំមិនអាចនិយាយវាចេញជាសាធារណៈ។ ខ្ញុំនិយាយវាទៅកាន់ក្រុមជំនុំរបស់ខ្ញុំ។ ខ្ញុំកំពុងមានតយុទ្ធ ព្រោះពេលវេលាសាកល្បងកំពុងមានចំពោះខ្ញុំ។

121 ពួកគេនិយាយ "បើអ្នកមក វាមិនជាអ្វីទេ ប៉ុន្តែតើអ្នកមិននិយាយអ្វីពីវាទេ។" អ្នកគ្រាន់តែសន្សំដង្ហើមអ្នកទុកចុះ។

122 ខ្ញុំនឹងអធិប្បាយអ្វីដែល ព្រះមានបន្ទូលឲ្យអធិប្បាយ! ត្រូវហើយ!។ មួយក្នុងចំណោមប្រាំបីនាក់នៃពួកគេនឹងនៅកន្លែងណាមួយ។ ម្នាក់ក្នុងចំណោមពួកគេនឹងនៅកន្លែងណាមួយ។ ប៉ុន្តែនៅថ្ងៃនោះខ្ញុំមិនចង់មានកំហុសដោយនិយាយបែបចុះចូលព្រោះតែគោលជំនឿឬគោលលទ្ធិក្រុមជំនុំ ឬនិកាយណាមួយនោះទេ។ ខ្ញុំត្រូវអធិប្បាយនូវសេចក្តីពិត។

123 ពួកគេនិយាយ "ហេតុអ្វីអ្នកមិន ហេតុអ្វីព័ន្ធកិច្ចរបស់អ្នកមិនបងប្អូនប្រុសប្រានហាំ ដែលហាក់ដូចជាធំ ហេតុអ្វីវាមិនបោសចេញដូចមនុស្សផ្សេងកំពុងធ្វើ?"

124 នោះគឺអញ្ចឹងហើយ។ នោះហើយ។ ខ្ញុំទៅក្នុងក្រុង តើអ្នកគិតថាក្រុមជំនុំគ្រួសារព្រះនឹងសហការជាមួយខ្ញុំវឺ? អត់ទេ ខ្ញុំជឿថាពួកគេមិនឡើយ។ ទទួលបានម្តងមួយៗប៉ុនោះ។ តើអ្នកគិតថាមេតូឌីស្ទនឹងទទួល? ព្យាយាម និងរកឃើញហើយ។ ចូរធ្វើជាអ្នកចាត់ចែងឲ្យខ្ញុំមួយសប្តាហ៍ចុះ។ បើអ្នកចូលទៅ អ្នកនឹងទៅក្នុងព្រះនាមព្រះយេស៊ូវ។ នោះត្រូវហើយ។

125 អូ ពិតណាស់ ពួកគេមានអ្នកនៅទីនោះ ប្រាកដណាស់ យកអ្នកទៅកន្លែងណាមួយ ហើយអ្នកមិនភ្ជាប់ជាមួយពួកគេក្នុងរបៀបនោះឡើយ។ ហើយបន្ទាប់មកពេលអ្នកចាកចេញ គេនិយាយថា "អូ ឥឡូវ បងប្អូនប្រុសប្រាណហាំមានបញ្ហាខួរក្បាលបន្តិច អ្នកដឹងទេ។ គាត់..."

126 បើខ្ញុំមានបញ្ហាខួរក្បាល ដូច្នេះព្រះគម្ពីរក៏មានបញ្ហាដែរ។ នោះជាអ្វីដែលព្រះគម្ពីរនិយាយ! ត្រូវហើយ។ មើល!

127 ព្រះយេស៊ូវមានបន្ទូល "ហេតុអ្វីអ្នកហៅខ្ញុំថា 'បៀសេបាប់'? អ្នកជឿសាឡូម៉ូនទីសម្គាល់របស់ទ្រង់ស្គាល់ខុសស្គាល់ត្រូវ។ អ្នកជឿសម័យរបស់គាត់។ ម្ចាស់ក្សត្រិយ៍ នៃភាគខាងត្បូងបាន មើលអំណោយតែមួយជុំពិភពលោក ដើម្បីមើលអំណោយទាននោះ ហើយនាងបានជឿពេលបានឃើញ។ ហើយអ្នកអង្គុយនិងមើលវារាល់ថ្ងៃ តែបែរជាមិនជឿវិញ។"

128 ហើយបងប្អូនប្រុសរបស់ទ្រង់មិនជឿដល់ទ្រង់។ និយាយ "អ្នកទៅចូលរួមពិធីជប់លៀង" ទ្រង់មានបន្ទូល "ប៉ុន្តែខ្ញុំមិនឡើងឥឡូវឡើយ" ទ្រង់ឡើងទៅផ្លូវមួយទៀត ព្រោះបងប្អូនប្រុសផ្ទាល់របស់ទ្រង់មិនជឿទ្រង់ឡើយ។ នោះត្រូវហើយ

"តែឯទ្វារដែលនាំទៅឯជីវិត នោះតូច ហើយចង្អៀតវិញ ក៏មានមនុស្សតិចណាស់ដែលរកផ្លូវនោះឃើញ"។

129 នៅពេលវាមកដល់ពួកសាវក បានបង្ហាញថា ពួកគេនៅឯណា? ស្ត្រីនិង បុរសឈរក្បែរឈើឆ្កាងជាមួយទ្រង់យ៉ូហាននិងម៉ារី។ ពួកគេក្រៅពីនោះរត់បាត់។

130 នេះជាការបង្ហាញថា។ ដល់ពេលហើយ។ នេះជាពេលដែលព្រះកំពុងធ្វើ។ នេះជាពេលព្រះមេស្ស៊ីនៅលើផែនដី។ នេះជាពេលនៃអំណាចរបស់ព្រះដែលកំពុងធ្វើចលនាលើរាស្ត្ររបស់ទ្រង់។ ហើយគេហៅពួកគេថា "ពួកអ្នកបរិសុទ្ធ ល្ងីល្ងើរ" អូ អ្វីដូចនោះ។ ប៉ុន្តែពេលវេលាគឺនៅទីនេះ!

131 ប្រាកដណាស់មានការអស់សង្ឃឹមធំនៅថ្ងៃជំនុំជម្រះ។

132 អូអ្នករកស៊ីបិតស្រាលួចលាក់គាត់ដឹងថាគាត់នៅកន្លែងណានៅថ្ងៃជំនុំជម្រះ។ ដូច្នេះអ្នកញៀនស្រាបៀដឹងកន្លែងដែលគាត់ទៅ។ ស្ត្រីពេស្យាក៏ដូច្នេះដែរ នាងដឹងកន្លែងដែលនាងឈរ។ អ្នកលេងល្បែងក៏ដឹងដែរថា គាត់ឈរនៅកន្លែងណា។ មនុស្សប្រមឹកក៏ដឹងកន្លែងដែលគាត់ឈរដែរ។ គាត់មិនខកចិត្តឡើយ។

133 ប៉ុន្តែត្រូវខកចិត្តកន្លែងណា គឺអស់អ្នកដែលពួកគេគិតថាខ្លួនត្រូវ។ នោះហើយជាកន្លែងដែលត្រូវខកចិត្ត។ "ពេលពួកគេក្រោកឡើងទីនោះ និយាយ 'ប្រាកដទូលបង្គំដេញអារក្សដោយព្រះនាមទ្រង់។ ពួកទូលបង្គំជាគ្រូអធិប្បាយ។ ពួកទូលបង្គំជាកម្មសិទ្ធិក្រុមជំនុំមួយជាក់លាក់។ ទូលបង្គំធ្វើការអស្ចារ្យ។ អូ ទូលបង្គំអធិប្បាយ! ហេតុអ្វី ទូលបង្គំបាន—បានបម្រើក្នុងក្រុមជំនុំ។ ខ្ញុំជាចាស់ទុំ ខ្ញុំជាបែប*នេះ*' ចេញពីយើងទៅ អ្នកធ្វើការទុច្ចរិតអើយ យើងមិនស្គាល់អ្នកឡើយ" នោះគឺជាអ្នកហើយ។ នោះជាការខកចិត្ត។ ទ្រង់មានបន្ទូល "ចៅរបស់ពួកគេនឹងចូលមក និង តាំងអង្គុយក្នុងនគរ និយាយ 'យើងមានសិទ្ធិនៅទីនេះ' ហើយពួគេត្រូវបោះចេញទៅក្រៅនៅទីងងឹត ដែលគេយំនិងស្រែកថ្ងូរសង្កៀតធ្មេញ"។ "តែឯទ្វារដែលនាំទៅឯជីវិត នោះតូច ហើយចង្អៀតវិញ ក៏មានមនុស្សតិចណាស់ដែលរកផ្លូវនោះឃើញ។"

134 ចំពោះអ្នកជាមនុស្សជាទីស្រឡាញ់របស់ខ្ញុំអើយ នៅព្រឹកនេះ សូមស្តាប់សេចក្តីនេះ។ ខ្ញុំមិនធ្វើវាឡើយ។ ខ្ញុំមានទំនួលខុសត្រូវក្នុងការប្រាប់ពីវា។ នោះ

ជា ទំនួលខុសត្រូវរបស់ខ្ញុំ។ បើសិនជាខ្ញុំមិនអធិប្បាយសេចក្ដីណាក្នុងជីវិតរបស់ខ្ញុំ ដែលមិនមែនជាសេចក្ដីពិត:គឺមានមនុស្សតិចតួចណាស់ទទួលបានការសង្គ្រោះ។ សូមចងចាំថា: មានតិចតួចណាស់។ អ្នកជាម្នាក់ក្នុងចំណោមពួកគេ។

135 "ពួកគេជានរណា បងប្អូនប្រុសប្រានហាំ?" ខ្ញុំមិនដឹងឡើយ។ គ្មាននរណាម្នាក់ដឹងឡើយ។ យើងធ្វើការសម្រាប់សេចក្ដីសង្គ្រោះខ្លួនឯងដោយការកោតខ្លាច និងញាប់ញ័រ។

136 ប៉ុន្ដែអ្នកត្រូវនៅជួរជាមួយព្រះ។ បើចិត្តរបស់អ្នក មិនលោតតាមចង្វាក់ព្រះគម្ពីរ នោះមានអ្វីមួយខុសហើយ មានអ្វីមួយខុសហើយ។ មិនថាក្រុមជំនុំនិយាយអ្វី អ្នកមិនអាចទៅក្នុងក្បែរនោះបានទេ។ អ្នកត្រូវចូលទៅតាមអ្វីដែលព្រះមានបន្ទូល។ នេះជាសៀវភៅ អ្នកនឹងទទួលការកាត់ទោស គឺព្រះគម្ពីរ។ នៅជាប់ជាមួយវាចុះ!

137 "អូ" អ្នកនិយាយ "ល្អ ខ្ញុំបានជ្រមុជទឹកក្នុងព្រះនាមព្រះអម្ចាស់យេស៊ូវ" នោះគឺត្រឹមត្រូវ នោះគឺតាមព្រះគម្ពីរ។ ប៉ុន្ដែបើជីវិតមិនទៅតាមនោះ នោះវាមិនធ្វើអ្វីបានច្រើនឲ្យល្អក្នុងការជ្រមុជទឹកនោះឡើយ។

138 អ្នកនិយាយ "ល្អ ខ្ញុំបានទទួលព្រះវិញ្ញាណបរិសុទ្ធ។" នោះល្អ នោះជាអ្វីដែលអ្នកគួរតែធ្វើ។ ប៉ុន្ដែ បើជីវិតមិននៅទីនោះទេ!

139 ចងចាំ ស្រងែក៏ទទួលអំណាចដែលធ្លាក់លើស្រូវសាឡីឲ្យបានលូតលាស់ដែរ វាធ្វើឲ្យស្រងែស្រែកដែរ។ ស្រងែចាស់តូចបានក្រោកឡើងនិងរីករាយដូចជាស្រូវសាឡីដែរ។ នោះត្រូវហើយ រស់នៅជាជីវិតដូចគ្នា។ ហើយមនុស្សបាបនៅក្នុងព្រះវត្តមានរបស់ព្រះ ស្រែកជ័យជំនះ និងរស់នៅដូចជាគ្រីស្ទាន។ ប៉ុន្ដែបើមិនមានអ្វីប្លែកក្នុងចិត្ត! គាត់អាចមានអំណាចដូចគ្នាក្នុងការដេញវិញ្ញាណអាក្រក់។ ព្រះយេស៊ូវមានបន្ទូលដូច្នោះ។ គាត់អាចអធិប្បាយដំណឹងល្អ បានល្អដូចជាគ្រូអធិប្បាយផ្សេងទៀតអាចធ្វើ។ នោះពិតជាអ្វី ដែលព្រះយេស៊ូវមានបន្ទូលដូច្នោះ។ ព្រះគម្ពីរបង្រៀនវា។ ហ្នឹងហើយ។ "ទោះបើខ្ញុំចេះនិយាយ ជាភាសារបស់មនុស្សជាតិទាំងប៉ុន្មាន និងភាសារបស់ពួកទេវតាផង ទោះបីខ្ញុំប្រគល់រាងកាយឲ្យគេដុតជាយញ្ញបូជា ឬប្រគលទ្រព្យសម្បតិទាំងអស់ឲ្យទៅអ្នកក្រ ហើយបើខ្ញុំ—ខ្ញុំមានគ្រប់ទាំងសេចក្ដីជំនឿល្មមនឹងឲ្យភ្នំរើចេញបាន ខ្ញុំធ្វើគ្រប់ការទាំងអស់នេះបាន ខ្ញុំអធិប្បាយដោយនូវព្រះនាមទ្រង់ ខ្ញុំដេញអារក្សដោយនូវព្រះនាមទ្រង់ គាត់

និយាយ "នោះគ្មានប្រយោជន៍ដល់ខ្ញុំសោះ" ដូច្នេះគាត់អាចធ្វើវាបាន និង "គ្មានអ្វីសោះ"។ យល់ពីគំនិតឬទេ?

140 ឥឡូវអ្វីដែលត្រូវធ្វើគឺ ធ្វើជាគ្រីស្ទាន ចេញពីចិត្ត ឥឡូវចូលក្នុងទ្វាតូច ព្រោះផ្លូវទៅកាន់ការហិនវិនាសនោះធំទូលាយ ហើយមនុស្សរាប់លាននាក់រាប់លានដងនៅក្នុងជំនាន់អ្នកជឿនេះនឹងទៅកន្លែងនោះ។ ព្រោះទ្វាតូចនិងចង្អៀតមានតែអ្នកនិងព្រះគ្រីស្ទប៉ុណ្ណោះ។

141 "តែឯទ្វារដែលនាំទៅឯជីវិត នោះតូច ហើយចង្អៀតវិញ ក៏មានមនុស្សតិចណាស់ដែលរកផ្លូវនោះឃើញ។" ឥឡូវនោះជាព្រះបន្ទូលរបស់ព្រះអម្ចាស់។ ខ្ញុំអើយ! តើទ្រង់បានកំពុងធ្វើអ្វី? ឈរនៅទីនោះ យល់ពីគំនិតរបស់ពួកគេ។

142 ហើយគាត់និយាយ "ទ្រង់ជាបៀលសេបាប់។ អើតើទ្រង់អាចជាព្រះម្តេចកើត? ទ្រង់ជាមនុស្ស! តើប្រាជ្ញានេះមកពីណា?" ពួកគេនិយាយនៅក្នុងក្រុងផ្ទាល់របស់ទ្រង់។

143 ពេលអ្នកដើរចូលទៅ ក្នុងក្រុងនោះ វាហាក់ដូចជា...ខ្ញុំមិននិយាយការមិនយកចិត្តទុកដាក់នេះទៅកាន់អ្នកដែលជាមនុស្សឡើយ អ្នកជាគ្រីស្ទាន អ្នកស្រឡាញ់ខ្ញុំ។ អ្នកដើរទៅក្នុងក្រុងទីនេះ ហើយវាដូចជាអំណាចរបស់សាតាំងផ្តួលអ្នកចុះ។ កន្លែងនេះមានការកាត់ទោស។ ក្រុងនេះគឺមានការកាត់ទោស។

144 តើ ប៊ីលីហ្គ្រាហាំ និយាយអ្វីពេលគាត់ចូលដល់ល្វីសវីល? គាត់និយាយថា "ជាកន្លែងមានអំណាច-អារក្សបំផុត)" គាត់មិនធ្លាប់ឃើញក្នុងជីវិត។ ដាក់វានៅក្នុងក្រដាស និយាយ "អ្នកអាចត្រឹមតែមានអារម្មណ៍ការសង្កត់នៃអារក្ស"។

145 ព្រោះ ខ្ញុំមានអារម្មណ៍ពីវា។ ហេតុអ្វី? នេះជាផ្ទះផ្ទាល់របស់ខ្ញុំ។ ពេលព្រះយេស៊ូវ ត្រឡប់ទៅរកផ្ទះផ្ទាល់របស់ទ្រង់ ទ្រង់មានបន្ទូលពីកិច្ចការមានអំណាចជាច្រើនដែលទ្រង់មិនអាចធ្វើ ព្រោះតែការមិនជឿរបស់ពួកគេ។ និយាយ "ព្យាការីមិនមែនគ្មានការគោរពទេ គួរអធិប្បាយ លើកលែងតែនៅ—ប្រទេសរបស់គាត់ចំណោមមនុស្សរបស់គាត់" ឃើញទេ? អ្នកមិនអាចជួយបានទេ ខគម្ពីរនិយាយដូច្នេះ។ ឃើញទេ?

146 ឥឡូវ ពេលអ្នកដើរនៅក្នុងទីក្រុងនេះ! ហើយមិនប្រាប់ខ្ញុំ ខ្ញុំមិនដឹងទេ។ ខ្ញុំដើរទៅជួបមនុស្សដែលចាប់ដៃខ្ញុំនិងនិយាយថា "អូ បងប្អូនប្រុសប្រានហាំ ខ្ញុំ

ស្រឡាញ់អ្នក" ហើយអ្នកដឹងថាវាជាការកុហក! អ្នកដឹងថាជាការកុហក។ បើសិនព្រះអាចប្រាប់ខ្ញុំពីការស្គាល់ចិត្តមនុស្ស រឿងអីដែលទ្រង់មិនអាចមានបន្ទូលប្រាប់ខ្ញុំពីរឿងនោះ?

147 ប្រាកដណាស់ និងមាននៅក្នុងចំណោមមនុស្សបងប្អូនផ្ទាល់នៅជុំវិញក្រុង! ពេលពួកគេជួបអ្នក និយាយ "ល្អ អ្នកដឹង ខ្ញុំបានឃើញត្រង់ចំណុចពិតប្រាកដ-ប្រាកដ..."

"កន្លែងណា? វានៅឯណា?"

"នោះ..."

"ហា! យើងស្គាល់មនុស្សនោះ!"

148 អ្នកមានអារម្មណ៍ពីវា។ ចូរឲ្យខ្ញុំប្រាប់អ្នក អ្នកអនុញ្ញាតិ ឲ្យនរណា ម្នាក់មកផ្ទះរបស់អ្នកដែលគេមិនចូលចិត្តអ្នក អង្គុយក្នុងផ្ទះរបស់អ្នកបន្តិច និងមានអារម្មណ៍ថាដូចអស់សំណើច។ កើនចំនួនដល់មួយម៉ឺនបួនពាន់ឥឡូវ ដូច្នេះអ្នកនឹងយល់ថាខ្ញុំនិយាយពីអ្វី។ បន្ទាប់មកអ្នកនឹងទៅដល់ចំណុច ដែលអ្នកគ្រប់គ្នាស្រឡាញ់អ្នកនោះជាអារម្មណ៍ស្វាគមន៍ ដូច អូ ខ្ញុំអើយ ហើយអ្នកអាចនៅទីនោះរហូត ឃើញទេ។ នោះគឺបែបនោះ ឃើញ វាជាវិញ្ញាណ។ ហើយមនុស្សមិនស្គាល់ថាវាជាអ្វីឡើយ ពួកគេឆ្ងល់ថាហេតុអ្វីមនុស្សមានភាពអាក្រក់។

149 អ្វីទៅដែលធ្វើឲ្យស្ត្រីក្លាយជាល្អ អ្វីទៅដែលធ្វើឲ្យស្ត្រីល្អ ដោយពាក់លើខ្លួនសម្លៀកបំពាក់អាប់ឱននិងចេញទៅក្រៅ? អ្វីទៅធ្វើឲ្យទោះជាឥឡូវពេលវានៅត្រជាក់នៅឡើយ។ ក្មេងស្រីតូចមួយអាយុដប់ប្រាំមួយឆ្នាំ នៅជាមួយសម្លៀកបំពាក់ដែលនាងមិនគួរស្លៀកនៅពីមុខម្តាយរបស់នាង និងចេញទៅតាមផ្លូវ? វាដោយសារ មិនមែនកូននោះទេ(កូនមិនដឹងថាអ្វីដែលប្រសើរនោះទេ" ប៉ុន្តែពីព្រោះគ្រូអធិប្បាយនៅលើតុវេទិការបរាជ័យក្នុងការបំពេញតួនាទី។ នោះគឺត្រូវហើយ។ ប្រាកដណាស់។ ស្ត្រីទៅតាមផ្លូវ និងស្លៀកពាក់សិចស៊ី និងអ្វីបែបនោះ និងមនុស្សមានបាបសម្លឹងមើលពួកគេនិងមិនដឹងថានាងពិតជាមានកំហុសពេលនាងរស់នៅជាមួយបុរសនោះទេ។ ព្រះយេស៊ូវមានបន្ទូលបែបនេះ! ព្រះយេស៊ូវមានបន្ទូល "ប៉ុន្តែ ខ្ញុំប្រាប់អ្នករាល់គ្នាថា សូម្បីតែអ្នកណាដែលគ្រាន់តែក្រឡេកឃើញ

ស្រ្តី ហើយមានដំរេកសំរើបចង់បាន នោះឈ្មោះថា បានប្រព្រឹត្តសេចក្តីកំផិតនឹង នាង នោះ នៅក្នុងចិត្តខ្លួនហើយ។" ទ្វារនាំទៅឯជីវិតនោះគឺតូចចង្អៀត!

150 ខ្ញុំដឹងថាអ្នកគិតថាខ្ញុំជាមនុស្សពិបាក។ ខ្ញុំមិនពិបាកឡើយ! ខ្ញុំជាបងប្អូនប្រុស របស់អ្នក ហើយខ្ញុំស្រឡាញ់អ្នក។

151 រត់គេចពីសេចក្តីក្រោធដែលមកដល់! ចូរទៅកាន់ឈើឆ្កាងរួចស្រែកយំ រហូតដល់ចិត្តរបស់អ្នកពេញដោយ ព្រះវិញ្ញាណរបស់ទ្រង់ ដែលអាចបែរខ្នងរបស់ អ្នកចេញពីអ្វីៗនៃលោកកិយ និងដើរដោយកោតខ្លាចព្រះនៅពីមុខទ្រង់ ជាមួយ ចិត្តឆេះឆួលពីទ្រង់។ សេចក្តីស្រឡាញ់! មិនមែនជាកាតព្វកិច្ចទេ។ ព្រះគ្រីស្ទ មិនមែនជាកាតព្វកិច្ចឡើយ ក្នុងការបម្រើព្រះគ្រីស្ទ វាជាសេចក្តីស្រឡាញ់ដែល បម្រើព្រះគ្រីស្ទ។ វាទាញពង្រឹងអ្នក វាបានបង្គាប់ដល់អ្នក រហូតដល់រាល់ជីបចរ របស់អ្នកលោតជាមួយទ្រង់។ នៅពេលអ្នកធ្វើបាប។

152 ហើយទ្រង់យំពីផែនដីនេះ។ វាធ្វើឲ្យទ្រង់ព្រួយនៅថ្ងៃរបស់ណូអេ ពេលទ្រង់ បានឃើញចិត្ត។ ហើយព្រះយេស៊ូវត្រូវបានដាក់នៅលើភ្នំ ហើយមានបន្ទូល "ឱយេ រូសាឡិម ក្រុងយេរូសាឡិមអើយ ឯងដែលសំឡាប់ពួកហោរា ហើយយកថ្មចោល ពួកអ្នកដែលបានចាត់មកឯឯង តើប៉ុន្មានដងហើយ ដែលអញចង់ប្រមូលកូនឯង ទាំងប៉ុន្មាន ដូចជាមេមាន់ក្រុងកូនវាឲ្យជ្រកក្រោមស្លាប តែឯងមិនព្រមទេ មើល ផ្ទះ ឯងនឹងត្រូវចោលស្ងាត់"។

153 ដូច្នេះ វាជាការមកដល់របស់ព្រះបុត្រាឆាប់ៗ ចិត្តរបស់អ្នកជឿពិតគឺខ្មៅចខ្លាំ។ គាត់ឃើញឥឡូវមានការទួញសោកផ្ទុះឡើងពេញដែនដីនេះ។ តើវាអាចមាន តាមរយៈក្រុមពួកអ្នកមិនស្របច្បាប់ដូចម្តេចបាន? តើវាអាចជាយ៉ាងម៉េច ពេល ការកាត់ទោសនឹងត្រូវចាប់ផ្តើមជាមួយគ្នា?

154 នគររបស់ព្រះដូចជាមនុស្សម្នាក់បោះសំណាញ់ទៅក្នុងសមុទ្រ ហើយពេល គាត់ទាញមកបានអណ្តើក ធីរ៉ាភីន(terrapin) ពស់ កង្កែប និងត្រីខ្លះៗ។ តើគាត់ មិន មែនមិនសម្រេចចិត្តមួយណា ដែលគាត់ត្រូវបោះទៅលើច្រាំងឬ។ នោះជាអ្វី ដែលដំណឹងល្អធ្វើការដែរ។ នោះជាអ្វី លោកប៊ីលីហ្គ្រាហាំ(Billy Graham) អូរ៉ាល់ ប៊ឺត (Oral Roberts) ខ្លួនខ្ញុំផ្ទាល់ និងគ្រូអធិប្បាយទាំងអស់ដែលផ្សាយដំណឹង ល្អ បោះវាទៅ ទាញវាចូលមកវិញ "ពួកគេនៅទីនោះ ព្រះអម្ចាស់" ប៉ុន្តែ យើងធ្វើអ្វី គ្រប់ពេលនោះ? យើងរកឃើញ មុននឹងអ្នកអាចមកវិញម្តងទៀត ពួកគេនឹងលោត

ចូលស្រះម្តងទៀត។ នោះជាអ្វី? ដើម្បីចាប់ផ្តើមវិញ វាជាអណ្តើក។ នោះមិនអាចផ្លាស់ប្តូរឲ្យចាប់យកមកក្នុងសំណាញ់ នៃដំណឹងល្អបានឡើយ។ គាត់ចាប់ផ្តើមជាអណ្តើក។ គាត់ជាធីរ៉ាភីន(Terrapin)ដែលចាប់ផ្តើមមក។ គាត់ចាប់ផ្តើមមកជាសត្វពស់។ ពួកគេជាអ្នកកំពុតមុនគេមកព្រះវិហារ។ គាត់មិនមានបំណងចិត្តបោះបង់ការផឹកស្រានិងលេងល្បែង ជក់បារី និងកុហក និងលួចឡើយ។ គាត់បានមកគឺព្រោះតែគាត់ខ្លាចស្ថាននរកប៉ុណ្ណោះ។ អ្នកបានធ្វើខ្លួនឯងឲ្យក្លាយជាបេក្ខជនមួយដែរ ពេលអ្នកធ្វើបែបនោះ។ នោះគឺពិតហើយ។ "តែឯទ្វារដែលនាំទៅឯជីវិតនោះតូច ហើយចង្អៀតវិញ ក៏មានមនុស្សតិចណាស់ដែលរកផ្លូវនោះឃើញ។"

ចូរអធិស្ឋាន។

155 ព្រះអម្ចាស់អើយ អូ សូមស្វែងរកទូលបង្គំ។ ពិនិត្យករណីទូលបង្គំឥឡូវនេះ ព្រះអម្ចាស់អើយ។ កុំឲ្យទូលបង្គំត្រូវទៅមុខការជំនុំជម្រះពីមុខទ្រង់ឡើយ បន្ទាប់ពីអធិប្បាយបែបនេះ។ អូ បើសិនជាមានអ្វីមិនស្អាតក្នុងទូលបង្គំ ព្រះអម្ចាស់អើយ សូមយកវាចេញ! ពួកទូលបង្គំបានឃើញសម័យដែលកំពុងរស់នៅ ពេលមនុស្សប្រុសស្រីក្លាយជារឹងទទឹង។ គេមានសេចក្តីខ្មាស។ ទ្រង់មានបន្ទូលម្តងទៀត "នឹងមិនមានសេចក្តីអៀនខ្មាសក្នុងពួកកូនស្រីក្រុងស៊ីយ៉ូនផង"។ ភាពរម្យទមបានយកចេញរហូតដល់ពួកគេមិនមានសេចក្តីខ្មាសទៀតឡើយ។ អូ ព្រះអម្ចាស់អើយ សូមព្រះតម្រិះ! ហើយដឹងថាពេលវេលាបានលោតឆ្ងាយម្តងបន្តិចៗ មួយនាទីឬពីរនាទីទៀត ហើយសេចក្តីហិនវិនាសកំពុងមក ដូច្នេះចូរឲ្យពួកអ្នកមានការអាក្រក់នៅតែមានទៀតចុះ។

156 ព្រះអើយ សូមដាស់ទូលបង្គំទាំងអស់គ្នានៅព្រឹកនេះ។ សូមអង្រួនពួកទូលបង្គំ ព្រះអម្ចាស់! ពួកទូលបង្គំឃើញទីសម្គាល់បានលេចឡើង។ ពួកទូលបង្គំបើកភ្នែកមើល។ ទូលបង្គំឃើញមនុស្សរាប់លាន រាប់លាននាក់ ព្រះអម្ចាស់ នោះគឺបែរខ្នងពួកគេនិងដើរចេញ។ ទូលបង្គំឆ្ងល់ថាតើត្រូវអធិប្បាយបន្ថែម ឬអធិស្ឋានបន្ថែម អ្វីផ្សេងទៀតថែម សូមជួយទូលបង្គំ ព្រះអម្ចាស់ នោះជាការដែលទូលបង្គំគួរនាំសារមកកាន់មនុស្ស។ តើទូលបង្គំធ្វើយ៉ាងម៉េច? ប៉ុន្តែពួកគេបន្តបែរវាទៀត។ ទ្រង់បានធ្វើទីសម្គាល់យ៉ាងធំរបស់ទ្រង់និងសម្តែងការអស្ចារ្យឡើង តែមនុស្សនៅតែមិនអាចភ្ជាប់ខ្លួនមកបានទៀត។ គឺតើវាជាបទគម្ពីររបស់ទ្រង់ ត្រូវតែបំពេញ ឬ តើវាជាពេលវេលាដែល "គ្មានអ្នកណាអាចនឹងមកឯខ្ញុំបានទេ លើកតែព្រះវរបិតា

ទ្រង់ទាញគេ ហើយអស់អ្នកណាដែលទ្រង់ឲ្យមកខ្ញុំ នឹងមកឯខ្ញុំ?″ ព្រះអម្ចាស់ជាព្រះ សូមទទួលព្រមនៅព្រឹកនេះដែលមនុស្សនឹងភ្ញាក់ឡើង និង ឃើញទីសម្គាល់ចុងក្រោយនេះ។ ទូលបង្គំអធិស្ឋាន ព្រះអើយ នោះទ្រង់នឹងទទួលអ្វីៗចំពោះមនុស្ស។

157 មានពរហើយមនុស្សតិចតួចនេះនៅទីនេះក្នុងព្រឹកនេះ។ ព្រះ ចាប់ផ្តើមជាមួយបងប្អូនប្រុស Neville ព្រះអម្ចាស់។ ព្យាបាលរាងកាយរបស់គាត់។ គាត់ឈឺនៅព្រឹកនេះ ព្រះអម្ចាស់ បញ្ហាក្រពះ។ ទូលបង្គំអធិស្ឋានដែលការប្រោសឲ្យជារបស់ទ្រង់នឹងកើតមានចំពោះទ្រង់។ កក្កូរព្រលឹងរបស់គាត់។

158 ព្រះអង្គ សូមយាងទៅកាន់ក្រុមជំនុំនេះ។ មានមនុស្សប្រុសស្រីអង្គុយនៅទីនេះព្រឹកនេះដែលទូលបង្គំអាចនឹងមិនបានជួបពួកគេម្តងទៀតរហូតដល់ថ្ងៃជំនុំជម្រះ ដូច្នេះទូលបង្គំនឹងផ្តល់នូវសេចក្តីទទួលខុសត្រូវ។ ប៉ុន្តែទូលបង្គំអាចព្រះបន្ទូលទ្រង់ ‟ តែឯទ្វារដែលនាំទៅឯជីវិត នោះតូច ហើយចង្អៀតវិញ ក៏មានមនុស្សតិចណាស់ដែលរកផ្លូវនោះឃើញ។″ អូ ព្រះអម្ចាស់សូមឲ្យសេចក្តីបានជាដូច្នោះ ‟តិច″ នៃ ចំណោមពួកគេ ទ្រង់នឹង ព្រះអម្ចាស់? សូមទទួលគ្រប់មនុស្សននៅទីនេះ។

159 ទូលបង្គំអធិស្ឋានជាមនុស្សអាចបានត្រឹមតែអធិស្ឋាន។ ព្រះអម្ចាស់ មនុស្សទាំងនេះនឹងអាចធ្វើអ្វីដល់ទូលបង្គំ ដើម្បីជួយទូលបង្គំ។ បើទូលបង្គំឃ្លាន ពួកគេចំអែតទូលបង្គំ។ ពេលទូលបង្គំត្រូវការសម្លៀកបំពាក់ ពួកគេទិញមក។ ពួកគេរួមគ្នាហើយទិញឡានសម្រាប់ទូលបង្គំ ដើម្បីអធិប្បាយដំណឹងល្អ។ ពួកគេធ្វើអ្វីៗតាមផ្លូវនោះ។ អូ ព្រះបិតា សូមស្វែងរកព្រលឹងរបស់ពួកគេនៅព្រឹកនេះ សូមធ្វើ និងឲ្យពួកគេស្វែងរកនៅពីមុខទ្រង់។ ទូលបង្គំមិនដឹង ទូលបង្គំទុកចិត្តគ្រប់គ្នានៅក្នុងការជ្រើសរើសនោះ។ និងដាក់ទូលបង្គំនៅទីនោះផងដែរ ព្រះអម្ចាស់។ ហើយ បើមានហេតុផលនៅក្នុងទូលបង្គំ ដែលទូលបង្គំ មិននៅចំណុចនោះ ព្រះអម្ចាស់សូមទ្រង់បង្ហាញទូលបង្គំ ទូលបង្គំនឹងធ្វើវាឲ្យបានត្រឹមត្រូវវិញ។ ទូលបង្គំបានភាពប្រាកដ ព្រះអម្ចាស់ថា ពីពេលព្រឹកនោះតទៅមិនមានបញ្ហាទៀតនៅទន្លេ។ ទូលបង្គំចង់ទៅនៅថ្ងៃនោះ។ ហើយទូលបង្គំមិនដឹងថាជាថ្ងៃណាវាប្រហែលមិនទាន់នៅថ្ងៃនេះ។ ដូច្នេះ សូមជួយទូលបង្គំឲ្យដឹង ជួយមនុស្សទាំងនេះឲ្យបានដឹង។

160 ហើយពេលយើងឃើញចិត្ត របស់អ្នកមានការយកចិត្តទុកដាក់! អូ យើងរីករាយជាមួយសារដ៏ល្អក្នុងការស្ដាប់តាមវិទ្យុ ឬទៅព្រះវិហារ។ យើងរីករាយជាមួយសារល្អ។ យើងមិនមានបញ្ហាអ្វី ក្នុងការនិយាយពីព្រះយេស៊ូវនៅកន្លែងណាក៏ដោយ ។ ប៉ុន្តែ ព្រះអម្ចាស់ គឺជាបាបដែលជាបន្ទុកដល់យើង និងវានាំទឹកភ្នែកមកកាន់ភ្នែករបស់យើងដកដង្ហើមធំនិងយំនិងខំប្រឹងទាស់ប្រឆាំងវាដែលគ្រប់យ៉ាង ជាការស្អប់ខ្ពើមដែលធ្វើនៅក្នុងក្រុង? ព្រះអម្ចាស់ ចូរឲ្យទេវតានៃទ្រង់ឃើញសេចក្ដីនោះចំពោះពួកទូលបង្គំ និងដៅសម្គាល់ពួកទូលបង្គំ។ សូមទទួលព្រះអម្ចាស់។

161 ទោះបីជាត្រូវមក ព្រះអម្ចាស់យេស៊ូវ ឥឡូវនិងសូមរៀបចំចិត្តទូលបង្គំ និងប្រទានឲ្យ ទូលបង្គំនូវទីសម្គាល់ពិតរបស់ទ្រង់ ដែលទ្រង់នៅកណ្ដាលពួកទូលបង្គំនោះដើម្បីឲ្យ បានដឹងថាពួកទូលបង្គំបានទទួល—ទទួលទីសម្គាល់ចុងក្រោយមុនចុងបញ្ចប់សម័យនេះ។

162 ហើយពួកទូលបង្គំឃើញភាពមិនស្របច្បាប់ ពេលមនុស្សរស់នៅក្នុងប្រជាជាតិ ហើយមានកូនកើតមកជាប្រពន្ធរបស់បុរសផ្សេង ហើយ—និងមានក្មេងស្រីតូចដើរតាមផ្លូវ ហើយមនុស្សរាប់រយអ្នកចេញពីសាលារៀងរាល់ឆ្នាំ ហើយក្មេងជំទង់ក្លាយជាម្ដាយរបស់គេ និងគ្មានការគោរពសោះឡើយ ហើយនោះហើយដែលស្ត្រីក្លាយជាពុលវង្វេង ដោយខ្លួនឯង ដោយការជក់បារី និង—និងផឹកស្រា និងទូរទស្សន៍និងផ្សេងទៀតដែលបង្ខូចគំនិតរបស់ក្មេងៗ។ អូ ព្រះអម្ចាស់ តើវាអាចឈរបានយូប៉ុណ្ណា? ហើយទ្រង់ ជាព្រះបរិសុទ្ធ!

163 អូ ព្រះបិតា ទូលបង្គំ—ទូលបង្គំមានអារម្មណ៍យ៉ាងចម្លែកនៅថ្ងៃនេះនោះជាអ្វីដែលត្រូវធ្វើឲ្យបានឆាប់ព្រះអម្ចាស់អើយ។ ទូលបង្គំមិនដឹងអ្វីត្រូវនិយាយឡើយ ប៉ុន្តែទូលបង្គំអធិស្ឋាន ព្រះអម្ចាស់អើយ ទ្រង់នឹងដាក់ក្នុងចិត្តរបស់ពួកទូលបង្គំនូវអ្វីដែលត្រូវធ្វើ។ សូមទទួលសេចក្ដីទាំងនេះ ព្រះអម្ចាស់អើយ។ ពួកទូលបង្គំទូលសូមក្នុងព្រះនាមព្រះយេស៊ូវ។ អាម៉ែន។

164 ពេលវេលាជិតមកដល់ហើយ។ គ្រប់មនុស្សដែលដឹង ដោយវិញ្ញាណដែលមានហេតុផល ដឹងថាមានអ្វីមួយបម្រុងនឹងកើតឡើង។ មិនមានមនុស្សក្នុងអាគារដែលមានគំនិតត្រឹមត្រូវឡើយ ប៉ុន្តែដឹងថាពិភពលោកនេះមិនអាចឈរក្រោមស្ថានភាពទាំងនេះឡើយ។

យើងមិនអាចឈរបានឡើយ សម្លាញ់អើយ។ មិនមែនជាអ្វីតែមួយឡើយ ពេលគ្រូគង្វាលរបស់អ្នកនិងបងប្អូនរបស់អ្នក មិនមានអ្វីមួយដែលខ្ញុំអាចដឹកនាំអ្នកមកកាន់ព្រឹកនេះក្រៅពីមកឯយេស៊ូព្រះគ្រីស្ទឡើយ។ មិនមានអ្វីដែលខ្ញុំដឹង។ សូមគិតពីអ្វីដែលបានថ្លែងជាទំនាយមកមុនការលើកឡើងកើតមាន គ្រប់យ៉ាងដែលខ្ញុំដឹងត្រូវបានបំពេញ។

165 អ្នកនិយាយថា "ចុះអ្វីជាទីសម្គាល់សត្វជើងបួន?" នោះជាការមកក្នុងគ្រាវេទនា។ ក្រុមជំនុំនឹងបាត់ទៅ។ មិនត្រូវការទីសម្គាល់ទាំងនេះ វានឹងសម្រេចបានឃើញទេ។ ទីសម្គាល់កំពុងតែធ្វើហើយ។ ទីសម្គាល់នឹងបង្ហាញជាស្នាម។ រត់ទៅកាន់ព្រះ រត់ទៅកាន់ទ្រង់ឲ្យបានរហ័ស!

166 ខ្ញុំឆ្ងល់ថានៅព្រឹកនេះ ពេលយើងកំពុងតែរង់ចាំនៅទីនេះមួយភ្លែត។ ហើយខ្ញុំមានអារម្មណ៍ដូចអ្នករាល់គ្នា។ ខ្ញុំ—ខ្ញុំអាចមានអារម្មណ៍ដឹងពីអារម្មណ៍អ្នក គ្រប់គ្នាព្យាយាមគិត "អូ ព្រះអម្ចាស់អើយ សូមពិនិត្យទូលបង្គំ!" នោះជារបៀបដែលខ្ញុំមានអារម្មណ៍ដែរ។ ខ្ញុំដឹងថាសារទាំងនេះគឺបែបនោះ សម្លាញ់អើយមិនមែនភាពល្បីល្បាញក្នុងចំណោមមនុស្សឡើយ។ អ្នកកាត់ទោសពួកគេហើយអ្នកកាត់–... អ្នក—អ្នកធ្វើឲ្យគេទន់ទាប។ ត្រូវតែមានម្នាក់ធ្វើបែបនោះ។ ខ្ញុំចង់ឲ្យនរណាម្នាក់ផ្សេងទៀត។ ប៉ុន្តែបើសិនជាធ្លាក់មកឲ្យខ្ញុំធ្វើបែបនោះ បើខ្ញុំត្រូវធ្វើជាស្ត្រីដែលដុសលាង ខ្ញុំត្រូវតែដុសលាង។ បើខ្ញុំជា...ដាវីឌនិយាយ "ខ្ញុំស៊ូធ្វើជាកម្រាលជូតនៅមាត់ទ្វាក្នុងដំណាក់នៃព្រះ ប្រសើរជាងរស់នៅក្នុងតង់នៃបាប" នោះគឺត្រូវហើយ។ អ្វីដែលព្រះសព្វព្រះទ័យឲ្យអ្នកធ្វើ ចូរធ្វើចុះ។ កុំខ្មាស។ បើមាន...

167 ហើយចងចាំ ខ្ញុំដឹងថាជារឿងធំ។ និយាយ "បងប្អូនប្រុសប្រានហាំ អ្នកនិយាយត្រឹមតែព្រលឹងប្រាំបីដែលបានសង្គ្រោះរឺ?"

168 ខ្ញុំមិនដឹងថាប៉ុន្មាននាក់ដែលបានសង្គ្រោះនោះទេ ខ្ញុំមិនអាចប្រាប់អ្នកឡើយ។ ប៉ុន្តែខ្ញុំនិយាយរឿងមួយ: នឹងមានមនុស្សតិចណាស់ ក្នុងថ្ងៃដូចនេះ។ សូមគិត នៅក្នុងថ្ងៃដែលទ្រង់គង់នៅ តើប៉ុន្មាននាក់ដែលបានសេចក្ដីសង្គ្រោះ។ គិតពីថ្ងៃរបស់ណូអេ និងថ្ងៃរបស់ឡុត—ឡុត និងពួកគេទាំងអស់ ទ្រង់មានបន្ទូល "ដូច្នេះពេលបុត្រមនុស្សយាងមកក៏ដូច្នោះដែរ ព្រោះ តែឯទ្វារដែលនាំទៅឯជីវិត នោះតូច ហើយចង្អៀតវិញ" អ្នកឃើញទេ អ្នកទៅដោយខ្លួនឯង ជាមួយទ្រង់ ហើយនោះគឺត្រូវហើយ។ ឃើញ? "ក៏មានមនុស្សតិចណាស់ដែលរកផ្លូវនោះ

ឃើញ" គឺមានត្រឹមតិចតួច។ តើប៉ុន្មាននាក់នឹងជឿសេចក្តីពិតនោះ? ព្រះយេស៊ូវមានបន្ទូលដូច្នេះ "ក៏មានមនុស្សតិចណាស់ដែលរកផ្លូវនោះឃើញ" ចូរឲ្យបានក្លាយជាម្នាក់ក្នុងចំណោមនោះ។ ខ្ញុំដឹងថាវាពិបាក វាជាការប្រើកម្លាំងខ្លាំងក្លា។ និងវាជាការពិបាកសម្រាប់ខ្ញុំនិយាយបែបនោះ ជាអារម្មណ៍សេចក្តីស្រឡាញ់មនុស្សសម្រាប់អ្នក ប៉ុន្តែសេចក្តីស្រឡាញ់របស់ព្រះជម្រុញឲ្យខ្ញុំប្រាប់ដល់អ្នក។

169 ឥឡូវ ព្រះវិញ្ញាណបរិសុទ្ធដដែលដែលសម្តែងឡើងនៅសម័យលោកអ័ប្រាហាំ សម្តែងក្នុងថ្ងៃនៃព្រះគ្រីស្ទ សន្យាថានឹងនៅទីនេះធ្វើការដូចគ្នា។ ទ្រង់គង់នៅទីនេះ។ ឥឡូវ បើខ្ញុំប្រាប់អ្នកពីសេចក្តីពិត ព្រះមានកាតព្វកិច្ចចំពោះសេចក្តីពិតនោះ។

170 បើខ្ញុំមិនរក្សាពាក្យសំដីរបស់ខ្ញុំ ខ្ញុំមិនមែនមនុស្សដែលគោរពពាក្យខ្លួនឡើយ។ បើអ្នកមិនរក្សាពាក្យរបស់អ្នក អ្នកមិនមែនជាម្ចាស់ពាក្យរបស់អ្នកឡើយ។ ឥឡូវខ្ញុំអាចសន្យាចំពោះអ្នកហើយខ្ញុំមិនអាចធ្វើវាបាន ប៉ុន្តែ—ប៉ុន្តែមកប្រាប់អ្នក។ បើខ្ញុំជំពាក់អ្វីមួយ ហើយលាក់ពីអ្នក ខ្ញុំជាមនុស្សកំពុត។ បើខ្ញុំមកប្រាប់អ្នក "ខ្ញុំជំពាក់អ្នក តែខ្ញុំមិនអាចសងបាន ប៉ុន្តែខ្ញុំនឹងខិតខំអស់ពីលទ្ធភាពតាមតែអាចធ្វើបាន" បន្ទាប់មកអ្នកអត់ទោសឲ្យខ្ញុំនិងជួយខ្ញុំ។ ឃើញទេ?

171 យើងទាំងអស់គ្នាជំពាក់ព្រះអ្វីមួយ។ យើងជំពាក់ជីវិតយើងចំពោះទ្រង់។ សូមឲ្យស្មោះត្រង់ពីវា។ ដើរចេញនិងនិយាយ...កុំនិយាយ "ល្អ ឥឡូវសូមមើលខ្ញុំ—ខ្ញុំជាព្រីសប៊ីធីរៀន។ ខ្ញុំជាមេតូឌីស្ទ។ ខ្ញុំជាពេនទីកុស្ទ។ ខ្ញុំជាព្រះវិហាររបស់ព្រះ។ ខ្ញុំជាណាសារីន។ ខ្ញុំជាអ្នកបរិសុទ្ធ" កុំគិតបែបនោះ! មានមនុស្សរាប់លាននាក់បែបនោះនៅក្នុងស្ថាននរក។ អ្នកជាគ្រីស្ទបរិស័ទ ក្នុងព្រះគ្រីស្ទ។

172 តើប៉ុន្មាននាក់នឹងនិយាយ "បងប្អូនប្រុសប្រានហាំ សូមចងចាំខ្ញុំក្នុងសេចក្តីអធិស្ឋានផង ឥឡូវ ខ្ញុំចង់លើកដៃឡើងៗ? សូមព្រះប្រទានពរអ្នក។

173 ព្រះអម្ចាស់ ទ្រង់ឃើញដៃរបស់គេ។ ពេលវេលាជិតដល់ហើយ ព្រះវិញ្ញាណបរិសុទ្ធដ៏អស្ចារ្យបានបិទអាគារនេះនៅព្រឹកនេះ។ ទូលបង្គំមានអារម្មណ៍ដឹងពីព្រះវត្តមានទ្រង់។ ទូលបង្គំដឹងថាទ្រង់គង់នៅទីនេះដើម្បីតម្កើងព្រះបន្ទូលរបស់ទ្រង់។ "អញនេះគឺព្រះយេហូវ៉ា ជាអ្នកថែរក្សា អញនឹងស្រោចទឹកជានិច្ច ហើយនឹងមើលថែទាំងយប់ទាំងថ្ងៃក្រែងអ្នកណាធ្វើឲ្យអន្តរាយ"។ ទ្រង់បញ្ជូនព្រះបន្ទូលទ្រង់មកដើម្បី

ធ្វើតាមបំណងទ្រង់ ហើយវា—វាត្រូវធ្វើបែបនោះព្រះអម្ចាស់។ ខគម្ពីរនិយាយថា ទ្រង់នៅដូចថ្ងៃម្សិលមិញ ថ្ងៃនេះ និងរៀងរហូតទៅ។

174 ពួកគេមិនអាចជឿថា ពួកគេជា មនុស្សនៅក្នុងថ្ងៃរបស់ទ្រង់ មិនអាចជឿថា ព្រះវិញ្ញាណបរិសុទ្ធនៅក្នុងទ្រង់។ ហើយទ្រង់បានធ្វើព្រះអង្គទ្រង់ផ្ទាល់(ជាមនុស្ស) ជាព្រះ ដែល ទ្រង់ជាបុត្រាកើតមកពីស្ត្រីព្រហ្មចារីរបស់ព្រះ និងយាងមកលើផែនដី ដើម្បីរំដោះពួកទូលបង្គំ ពីបាបរបស់ពួកទូលបង្គំ។ ហើយដោយព្រោះថាពួកគេ ឃើញវិញ្ញាណរបស់ ព្រះនៅក្នុងទ្រង់ ពួកគេព្យាយាមធ្វើឲ្យវាមានភាពខុសប្លែក។ ហើយទ្រង់មានបន្ទូលប្រាប់គេ ព្រះអម្ចាស់ "ខ្ញុំមិនធ្វើការអ្វីដោយអាងខ្លួនខ្ញុំ គឺខ្ញុំ និយាយសេចក្តីទាំងនេះ តាមដែលព្រះវរបិតាបានបង្រៀនខ្ញុំវិញ ព្រះអង្គនោះ ដែលចាត់ឲ្យខ្ញុំមក ក៏គង់ជាមួយនឹងខ្ញុំ។ បើអ្នកហៅអ័ប្រាហាំថាជា 'ឪពុក'របស់ អ្នក អ័ប្រាហាំបានឃើញថ្ងៃរបស់ខ្ញុំ" ប្រាកដណាស់ គាត់ឃើញ ពេលគាត់ឈរ ក្បែរទ្រង់ ឃើញទ្រង់ធ្វើការនោះជាទីសម្គាល់ "គាត់បានឃើញថ្ងៃរបស់ខ្ញុំនិងមាន អំណរ" និយាយ "អ្នកខុសហើយ មិនស្គាល់ខគម្ពីរនិងមិនស្គាល់អំណាចរបស់ ព្រះ របៀបដែលព្រះអាចគ្របបាំងស្ត្រីក្រមុំ និងនាំចេញជាព្រះបុត្រា(ដោយកំណើត ស្ត្រីក្រមុំ) និងរស់នៅផ្ទាល់អង្គទ្រង់ក្នុងភាពពេញលេញនៃអំណាចរបស់ទ្រង់ ក្នុង មនុស្សម្នាក់"។

175 ហើយរបៀបដែលទ្រង់អាច យកឈាមនោះពីរាងកាយ ដែលទ្រង់ជាជា យញ្ញបូជា ជាមនុស្សដែលបានស្អាតដែលទ្រង់អាចយកនឹងគង់នៅ បន្តការងារ របស់ទ្រង់ដល់ចុងបញ្ចប់នៃការប្រើប្រាស់! អូ ព្រះអើយ សូមដាស់មនុស្សឲ្យបាន ឃើញការនោះ។ សូមទទួល។ សង្គ្រោះគ្រប់គ្នាដែលលើកដៃរបស់ពួកគេ។ សំអាតចិត្តរបស់ពួកគេ។ ព្រះអម្ចាស់ ដៃទូលបង្គំលើកឡើង។ សូមសំអាត ទូលបង្គំ។ នេះជាផ្ទះ។ នេះជាកន្លែងដែលយើងបានសំអាត។ សូមឲ្យព្រះវិញ្ញាណ បរិសុទ្ធសំអាតយើងនៅព្រឹកនេះ និងសំអាតយើងពីការពុកផុយ។

176 ទូលបង្គំអធិស្ឋាន ព្រះអម្ចាស់ មិនមានមនុស្សចេញពីទីនេះ ប៉ុន្តែតើអ្វីបាន ដែលបានបំពេញដោយព្រះវិញ្ញាណរបស់ទ្រង់។ ប្រហែលមិនមានអារម្មណ៍តែមួយ ពីខាងក្រៅពេលវាកើតឡើង។ ប៉ុន្តែ ព្រះអម្ចាស់ សូមទៅខាងក្នុង ទាញសំបក ចេញ និងបង្ហាញទូលបង្គំថាទូលបង្គំជាអ្វី ព្រះអម្ចាស់។ សូមទទួលយក។ និង បំពេញពួកទូលបង្គំដោយព្រះវិញ្ញាណរបស់ទ្រង់ ជាមួយចិត្តដែលពិតនិងបរិសុទ្ធ។

និងនៅពេលការបៀតបៀននេះ និងទុក្ខលំបាក សូម ទ្រង់កាន់តែផ្អែមល្ហែមនិងស្និទ្ធស្នាលជាមួយពួកទូលបង្គំកាលបើដើរជាមួយទ្រង់ រង់ចាំថ្ងៃនោះ។ កាលកំពុងដែលទឹកភ្នែករត់កាត់ថ្ពាល់ទូលបង្គំ ដោយសារបាបនៃក្រុង សូមព្រះវិញ្ញាណបរិសុទ្ធទតមកនិងមានបន្ទូល "មានសេចក្ដីមួយដែល យើងអាចដៅបាន គាត់ជារបស់យើង នាងជារបស់យើង" សូមទទូល ព្រះអម្ចាស់។ សូមឲ្យវាមានក្នុងចំណោមទូលបង្គំនៅថ្ងៃនេះ។ ទូលបង្គំទូលសូមក្នុង ព្រះនាមព្រះយេស៊ូវ។ អាម៉ែន។

ពេលខ្ញុំមកទន្លេនៅថ្ងៃបញ្ចប់
ហើយខ្យល់នៃទុក្ខចុងក្រោយបានបក់
នឹងមានអង្គណាមួយរង់ចាំដើម្បីបង្ហាញផ្លូវដល់ខ្ញុំ
ខ្ញុំមិនត្រូវឆ្លងកាត់ទន្លេយ័រដាន់ម្នាក់ឯងឡើយ។

ខ្ញុំមិនត្រូវឆ្លងកាត់ទន្លេយ័រដាន់ម្នាក់ឯងឡើយ
ព្រះយេស៊ូវសុគតបាបខ្ញុំទាំងអស់ត្រូវបានលោះ
ពេលភាពងងឹត ខ្ញុំឃើញ ទ្រង់រង់ចាំខ្ញុំ
ខ្ញុំមិនត្រូវឆ្លងកាត់ទន្លេយ័រដាន់ម្នាក់ឯងឡើយ។

177 ខ្ញុំចង់ស្គាល់ទ្រង់ឥឡូវ។ សូមចាប់ដៃទូលបង្គំ ព្រះអម្ចាស់ដ៏ថ្លៃថ្លា សូមដឹកនាំទូលបង្គំទៅ ឲ្យទូលបង្គំឈរមាំ។ សូមឲ្យទូលបង្គំឈរនៅទីនេះ ព្រះអម្ចាស់ប្រឆាំងអ្វីៗដែលហៅថាខុស គ្រប់យ៉ាងដែលមើលទៅខុស។ ខ្ញុំមិនខ្វល់ថានរណានិយាយអ្វីឡើយ សូមឲ្យទូលបង្គំឈរឡើង ព្រះអម្ចាស់អើយ ។ ពេលទូលបង្គំអាចធ្វើអ្វីបាន សូមជួយទូលបង្គំឲ្យឈរ។ សូមចាប់ដៃទូលបង្គំទាញឆ្លងកាត់ព្រះអម្ចាស់។ សូមធ្វើអ្វីមួយ សូមឲ្យទូលបង្គំឈរ។ ពេលអ្វីៗបានមក ទ្រព្យធននៃលោកកិយនេះនិងអស់ទាំងភាពរុងរឿងរបស់វា បាំងភ្នែកទូលបង្គំចំពោះវា សូមឲ្យទូលបង្គំបានឃើញតែអង្គដែលសុគតជួសទូលបង្គំ។ បើវាត្រូវចំណាយមិត្តគ្រប់គ្នាចំពោះការនោះ បើវាត្រូវចំណាយគ្រប់យ៉ាងដែលខ្ញុំមាន នោះមិនមានន័យថាជារបស់តែមួយ ទូលបង្គំសូមដាក់ចុះចូលលើអាសនា។ នោះគឺបែបនោះ សូមឲ្យទូលបង្គំឈរដោយស្មោះត្រង់។ និងនៅថ្ងៃណាមួយពេលខ្យល់ដង្ហើមទាស់នឹងមុខទូលបង្គំ និងទូលបង្គំដឹងថាចិត្តទូលបង្គំ រលាយទៅហើយថ្ងៃទូលបង្គំបានបញ្ចប់ និងពេលវេលាអស់ហើយ និងកាតរបស់ទូលបង្គំបានដកចេញពីប្រដាប់

ព្យួរ ទូលបង្គំមិនចង់ឆ្លងទន្លេយ័ដាន់តែម្នាក់ឯងឡើយ។ ទ្រង់នឹងគង់នៅទីនោះ។ មែន ហើយ។ ពេលភាពងងឹតខ្ញុំឃើញ នោះទ្រង់នៅទីនោះរងចាំខ្ញុំ ខ្ញុំមិនឆ្លងទន្លេយ័រ ដាន់តែម្នាក់ឯងឡើយ។ បើខ្ញុំឈរសម្រាប់ទ្រង់ឥឡូវ ទ្រង់នឹងឈរសម្រាប់ខ្ញុំក្រោយមកដែរ។ ទូលបង្គំនឹងរស់សម្រាប់ទ្រង់ដែលសុគតសម្រាប់ទូលបង្គំ តើជីវិតទូលបង្គំនឹងសប្បាយយ៉ាងណា។ នោះជាផ្លូវដែលខ្ញុំចង់ឈរ។

178 ខ្ញុំយល់ថាមានអ្នកជំងឺនៅទីនេះ។ តើគាត់បានចែកកាតទេ? ខ្ញុំភ្លេច។ គេចែកកាតទេ? តើមានកាតចែកឲ្យគេរឺនៅ? មានអ្នកទទួលបានកាតអធិស្ឋានរឺទេ? ទេ។

179 ខ្ញុំកំពុងរង់ចាំព្រះវិញ្ញាណបរិសុទ្ធ បើអ្នកគ្រាន់តែជឿ អ្នកមានជំនឿ កុំសង្ស័យ។ បើព្រះបើកសម្តែងមកកាន់ខ្ញុំពីបញ្ហារបស់អ្នក...អ្វីក៏ដោយខ្ញុំមិនស្គាល់។ បើអ្នកលើកដៃរបស់អ្នក អ្នកមិនស្គាល់ខ្ញុំ ខ្ញុំក៏មិនស្គាល់អ្នក។ ដូច្នេះបើព្រះបើកសម្តែងទីនេះអ្នកនឹងជឿវាដូចជាទេវតាដដែលនាំសារមុនការវិនាសកាលមុន វាដូចជាទេវតាដដែលដែលបាននាំវាមកឥឡូវ មុនការវិនាសមកដល់។ តើអ្នកជឿរឺទេ? បើអ្នកជឿសូមលើកដៃរបស់អ្នក។ ត្រូវហើយ។ ត្រូវហើយ សូមព្រះអម្ចាស់ទទួល។

180 ទ្រង់អង្គុយទីនេះក្បែរខ្ញុំ។ មានអ្នកផ្សេងទៀតអង្គុយក្បែរខ្ញុំ គឺអ្នកស្រីស្នៃឌឺ (Mrs. Snyder) នៅទីនេះ ឬ លោកស្រីមឺហ្វី (Murphy) នៅទីនេះ តើគាត់ឈ្មោះអ្វី អង្គុយនៅទីនេះ។ ខ្ញុំស្គាល់ពួកគេ។

181 ខ្ញុំមិនស្គាល់បុរសនេះឡើយ គាត់ជាមនុស្សថ្មីសម្រាប់ខ្ញុំ។ ប៉ុន្តែព្រះស្គាល់គាត់។ បើព្រះនឹងបើកសម្តែងមកកាន់ខ្ញុំ តើអ្នករាល់គ្នាប៉ុន្មាននាក់ ដែលដឹងថាវាគឺមិន...

182 កុំមើលមកខ្ញុំ។ ខ្ញុំអើយ ខ្ញុំជាក្មេងប្រុសមកពីតំបន់ភ្នំកេនតាគី ឆ្ងាយណាស់បើគិតទៅ។ ខ្ញុំ—ខ្ញុំមិនមានការអប់រំគ្រប់គ្រាន់ផង ពិបាក ទៅ—ទៅសរសេរឈ្មោះខ្លួនឯង។ ប៉ុន្តែមានរឿងមួយដែលខ្ញុំដឹង ខ្ញុំស្គាល់ទ្រង់។ ហើយនោះ នោះ—នោះជាអ្វីខ្ញុំបារម្ភក្នុងការស្វែងយល់។ ឥឡូវ កុំ—កុំផ្តោតអារម្មណ៍លើវេយ្យាករណ៍។

183 ហើយអ្នកអាចគិតថា សេចក្តីអធិប្បាយរបស់ខ្ញុំ ព្រឹកនេះគឺឃ្លាតពីបន្ទាត់ និង គ្រប់យ៉ាង អ្នកដាក់វានៅខ្សែជាមួយព្រះគម្ពីរម្តង និងឃើញថាតើអ្នកមិនត្រូវចំគោលដៅសោះ។ មើលថាបើអ្នកសម្លឹងតម្រង់មិនចំពេលអ្នក—ពេលអ្នកដាក់វានៅទីនោះ។ កុំតម្រង់បន្ទាត់ជាមួយគំនិតរបស់អ្នក ប៉ុន្តែតម្រង់វាជាមួយអ្វីទ្រង់

មានបន្ទូល "តែឯទ្វារដែលនាំទៅឯជីវិត នោះតូច ហើយចង្អៀតវិញ ក៏មានមនុស្សតិចណាស់ដែលរកផ្លូវនោះឃើញ។ ចូរឲ្យចូលតាមទ្វារចង្អៀត ដ្បិតទ្វារដែលនាំទៅឯសេចក្ដីហិនវិនាស នោះធំ ហើយទូលាយផង ក៏មានមនុស្សជាច្រើនដែលចូលតាមទ្វារនោះ" មនុស្សរាប់លានរាប់លានដងដែលចូលទៅ។ ប្រហែលមានម្នាក់ក្នុងចំណោមមួយលានបានរកផ្លូវមកបាន។ នោះគឺជាអ្នក។ នោះជាអ្វីដែលទ្រង់មានបន្ទូល។ ឥឡូវ ទ្រង់មិនបានផ្ដល់ចំនួនទេ ប៉ុន្តែទ្រង់មានបន្ទូល "ដូចសម័យលោកណូអេ ព្រលឹងប្រាំបីនាក់។ វាដូចសម័យក្រុងសូដុម បីនាក់" ចេញពីអ្វីទាំងមូល បីនាក់បានសង្គ្រោះ ដោយភ្លើង។ ដូច្នេះវាបែបនេះ!

184 ឥឡូវ បើនរណាម្នាក់មានភាពខាងវិញ្ញាណពិត ខ្ញុំចង់ឲ្យអ្នកសម្លឹងមើលបុរសម្នាក់អង្គុយនៅទីនេះ គាត់មើលមកខ្ញុំតាមតែគាត់ឃើញបាន។ លើកដៃរបស់គាត់ ខ្ញុំមិនស្គាល់គាត់ទេ មិនដែលឃើញគាត់ឡើយ ហើយខ្ញុំមិនដឹងអ្វីទាំងអស់ពីទ្រង់។ គាត់អង្គុយទីនោះសម្លឹងមើលមកខ្ញុំ។ ប៉ុន្តែមើល គាត់ធ្វើការទាក់ទងគាត់កំពុងអធិស្ឋាន។ ឥឡូវត្រូវហើយ។ ឥឡូវ បើព្រះអម្ចាស់នឹងប្រាប់ខ្ញុំ...បុរសនោះអង្គុយឆ្ងាយមើលមកខ្ញុំ ហើយនេះជាលើកទីមួយ ដែលយើងបានជួបគ្នាហើយគាត់អង្គុយនៅទីនោះ។ បើព្រះបើកសម្ដែងមកខ្ញុំពីអ្វីដែលគាត់...ខ្ញុំ—ខ្ញុំមិនអាចព្យាបាលគាត់ឡើយ។ ខ្ញុំមិន ខ្ញុំមិនអាចធ្វើបានឡើយ ព្រោះព្រះជាអ្នកធ្វើរួចហើយ។ ប៉ុន្តែវាអាចបន្ថែមជំនឿដល់អ្នកបាន។ គ្រប់គ្នាឃើញឥឡូវ ទ្រង់នៅទីនេះ ជាវិញ្ញាណដដែល។ ហើយសូមចាំ ព្រះយេស៊ូវបានសន្យាបែបនេះ មុនពេលបញ្ចប់មកដល់។ វាតែងមានទីសម្គាល់ចុងក្រោយ។

185 ថ្ងៃមួយលីអូ(Leo)និងខ្ញុំអង្គុយនៅតាមផ្លូវ ហើយយើងក៏និយាយគ្នាខ្លះៗ។ ខ្ញុំមានអារម្មណ៍ជានិច្ចថាមានអ្វីប្លែក មានអ្វីផ្លាស់ប្ដូរចូលមក។ ពេលយើងនិយាយពីវា វាមិនបានផ្លាស់ប្ដូរព័ន្ធកិច្ចខ្ញុំឡើយ ព្រោះវាមិនអាច ប៉ុន្តែវាជាការផ្លាស់ប្ដូរក្នុងខ្ញុំ។ ខ្ញុំតែងតែជាមនុស្សទន់និងឲ្យគេដឹកនាំខ្ញុំ និងបញ្ជូន*របៀបនេះ*និង*របៀបនោះ*។ បើខ្ញុំធ្វើអ្វីដែលព្រះអម្ចាស់ប្រាប់ខ្ញុំឲ្យធ្វើជាយូមក ហើយខ្ញុំមិនមាន បញ្ហានោះទេសព្វថ្ងៃ។ ខ្ញុំចេញទៅនៅសប្ដាហ៍បន្ទាប់ ដើម្បីចំណាយពេលជាមួយព្រះតែម្នាក់ឯង។ បាទ លោក ខ្ញុំ—ខ្ញុំត្រូវតែឮពីស្ថានសួគ៌។ ខ្ញុំមិនចង់ទន់ខ្សោយ ខ្ញុំចង់ឈរក្នុងការកាត់ទោសក្នុងចិត្តដោយខ្លួនឯង។

186 បុរសម្នាក់ វានៅបន្តជាមួយគាត់ គាត់អង្គុយនៅខាងក្រោយ ព្រោះបុរសនោះជាអ្នកជឿ គាត់បានជឿពិត។ ខ្ញុំមើលអ្នកចូលរួមគ្រប់កន្លែង និងវាបានទៅត្រង់ជាមួយបុរសនោះ។ គាត់ត្រូវការជំនួយ មានបន្ទុក ប៉ុន្តែគាត់មានបន្ទុកសម្រាប់អ្នកផ្សេងទៀត។ នោះត្រូវហើយ។ អ្នកកំពុងអធិស្ឋានឲ្យនរណាផ្សេងទៀត។ អ្នកមានមនុស្សផ្សេងទៀតក្នុងចិត្ត។ នោះត្រូវហើយ គឺដូច្នេះរឺ? ជាមិត្តភក្តិ។ បើខ្ញុំប្រាប់អ្នកពីបញ្ហារបស់មិត្តម្នាក់នោះ តើអ្នកជឿខ្ញុំធ្វើជាអ្នកបម្រើព្រះទេ? វាជាបញ្ហាស្រា។ ត្រូវហើយ បើនោះជារឿងត្រូវ សូមលើកដៃ។

187 តើអ្នកជឿទេ? មាននរណាម្នាក់នៅទីនោះលើកដៃរបស់គេ ស្ត្រីនៅទីនោះនរណាម្នាក់។ បាទ មែន។ អ្នកមិនស្គាល់ខ្ញុំទេរឺ? ខ្ញុំជាមនុស្សថ្មីចំពោះអ្នកទាំងអស់គ្នារឺ? ខ្ញុំមិនស្គាល់អ្នកទេ ប៉ុន្តែព្រះស្គាល់អ្នក។ អ្នកជឿទេ? បើព្រះបើកសម្តែងឲ្យខ្ញុំដឹងពីចិត្តរបស់អ្នក តើអ្នកជឿថាខ្ញុំជាអ្នកបម្រើទ្រង់រឺទេ? ស្ត្រីតូច អ្វីដែលអ្នកខ្វល់ខ្វាយគឺទារកនៅត្រង់នោះ។ ត្រូវហើយ។ និងទារកនោះមានបញ្ហាត្រអកលើមុខ។ ដុកទ័រមិនអាចធ្វើបានពីបញ្ហានោះទេ។ អ្នកជាមនុស្សថ្មីនៅទីនេះ និងអ្នក និងអ្នកស្រឡាញ់ម្នាក់អង្គុយនៅទីនោះ។ អ្នកជឿថាព្រះអាចប្រាប់ខ្ញុំអ្នកជានរណានិងអ្នកមកពីណាទេ? អ្នកជឿទេ? តើ អ្នកទទួលការប្រោសឲ្យជាដល់ទារកថាតើទ្រង់អាចទេ? [ស្ត្រីនិយាយ "ចាស"—Ed។] ត្រូវហើយ អ្នកអាចទៅ សាមឺសេតកេតតាគី(Somerset Kuntucky)ជាកន្លែងដែលអ្នកមក។ និងជឿថាគាត់នឹងជាជំងឺត្រអករបស់អ្នកនឹចេញពីទារក បើអ្នកគ្រាន់តែជឿ។

188 ពេលខ្ញុំបញ្ចោក់ពាក្យនោះ មានអ្នកឈរនៅខាងក្រោយសាល ពីសាមឺសេតកេនតាគី(Somerset, Kentucky) អធិស្ឋាន ជាមួយបញ្ហាក្នុងចិត្ត។ អ្នកជឿថាព្រះអាចធ្វើឲ្យបានប្រសើរវិញទេ? បើអ្នកជឿវាចេញពីចិត្ត និងជឿថាព្រះអាចព្យាបាលនិងធ្វើអ្វីៗឲ្យប្រសើរឡើង។

189 ទីនេះ ទីនេះ ខ្ញុំជឿថាមានអ្នកលើកដៃតាមទីនេះ តាមកន្លែងនេះ ជាស្ត្រី។ បាទ ខ្ញុំឃើញដៃរបស់អ្នកហើយ។ ខ្ញុំជាមនុស្សចម្លែកសម្រាប់អ្នក ស្ត្រី? ខ្ញុំមិនស្គាល់អ្នក។ យើងមិនដែលជួបគ្នាទេ។ តើអ្នកជឿថាខ្ញុំជាអ្នកបម្រើទ្រង់ទេ?[ស្ត្រីនិយាយ "អាម៉ែន"—Ed។] ជឿទេ? អ្នកមានបន្ទុកនៅក្នុងចិត្តរបស់អ្នក អ្វីមួយ។ អ្នកអាចជឿថាព្រះបើកសម្តែងវាមកខ្ញុំ អ្នកជឿថាវាជាវិញ្ញាណដដែលដែលនៅក្នុងព្រះគ្រីស្ទទេ? ប្តីរបស់អ្នកអង្គុយនៅទីនោះ គាត់ជឿដូចគ្នា ដែរ? តើអ្នកជឿថាជារឿងដូចគ្នា

ទេ? វាជាបញ្ហានៃកូនស្រីតូចដែលអង្គុយក្បែរអ្នក។ ត្រូវហើយ នាងមានមហារីក។ ប៉ុន្តែអ្នកជឿថាព្រះនឹងព្យាបាលនាងទេ? បើអ្នកជឿ លើកដៃរបស់អ្នក។ ត្រូវហើយ ដាក់ដៃលើកូនចុះ។

190 ព្រះអម្ចាស់យេស៊ូវ ក្នុងព្រះវត្តមាននៃព្រះវិញ្ញាណទ្រង់ ទូលបង្គំកាត់ទោសអារក្ខដែលកំពុងសម្លាប់ក្មេងនេះ។ ទូលបង្គំដាក់ ដោយជំនឿ ព្រះលោហិតព្រះយេស៊ូវគ្រីស្ទរវាងអ្នកសម្លាប់និងក្មេងនោះ។ សូមឲ្យមានជីវិតរស់។ អាម៉ែន។

191 មានជំនឿក្នុងព្រះ។ កុំសង្ស័យ។ "ចូរឲ្យមានជំនឿនោះអ្វីៗនឹងសម្រេចបាន" បើអ្នកគ្រាន់តែជឿ អ្វីៗនឹងសម្រេចបាន។ ត្រូវហើយ។

192 មានម្នាក់ទៀតហើយនៅខាងក្រោយលើកដៃ នៅកន្លែងណាមួយ អ្នក ស្ត្រីនៅខាងចុង។ អ្នកជឿថាខ្ញុំជាអ្នកបម្រើរបស់ព្រះ? ខ្ញុំមិនស្គាល់អ្នក អ្នកមិនស្គាល់ខ្ញុំ។ អ្នកជឿថាព្រះអាចបើកសម្តែងមកកាន់ខ្ញុំពីអ្វីដែលជាបញ្ហារបស់អ្នកទេ? តើអ្នកទទួលថាព្រះយេស៊ូវជាអ្នកប្រោសអ្នកឲ្យជា និងជាអង្គផ្គត់ផ្គង់អ្នកទេ អ្វីក៏ដោយ—អ្វីក៏ដោយ វាជា...? អ្នកជឿដូច្នេះទេ? ត្រូវហើយ ដូច្នេះនឹងបំបែកការភ័យខ្លាចរបស់គាត់ ដែលអ្នកមាន។ បើនោះជាការត្រឹមត្រូវ សូមឈរឡើង បើវាត្រឹមត្រូវដូច្នេះមនុស្សនឹងឃើញថាវាជាសេចក្តីពិត។ ត្រូវហើយវានឹងចេញពីអ្នក។ ទៅផ្ទះនិងបានជា។ សូមព្រះប្រទានពរ។

អ្នកមកពីកេតាគី(Kentucky)ដែរ។ អះ ហះ ត្រូវហើយ។

193 ស្ត្រីអង្គុយក្បែរអ្នក មកពី Kentucky ដែរ។ នាងគឺ ដូចគ្នា។ ខ្ញុំមិនស្គាល់អ្នកឡើយ ខ្ញុំស្គាល់ទេ? ប៉ុន្តែខ្ញុំអាចប្រាប់អ្នកពីអ្វីខុសនៅក្នុងអ្នក។ បើខ្ញុំអាចប្រាប់អ្នកពីអ្វីជាបញ្ហានៅក្នុងអ្នក អ្នកទទួលព្រះគ្រីស្ទជាអង្គព្យាបាលអ្នកឬទេ? វាជាត្រគៀករបស់អ្នក។ បើដូច្នេះ សូមលើកដៃរបស់អ្នក ឲ្យខ្ពស់ដើម្បីឲ្យមនុស្សអាចមើលឃើញ។ ត្រូវហើយ ទៅផ្ទះចុះ វាបាត់ហើយ។ ជំនឿរបស់អ្នកបានជួយអ្នកឲ្យជា។

ខ្ញុំជម្រុញអ្នកឲ្យបានជា។ ខ្ញុំជម្រុញជំនឿរបស់អ្នកឲ្យជឿ។

194 មានស្ត្រីម្នាក់អង្គុយនៅទីនេះ អង្គុយ មានកន្សែងដៃរបស់នាងលើមុខ។ ខ្ញុំមិនស្គាល់អ្នកឡើយ។ ព្រះស្គាល់អ្នក។ អ្នកមកពីជោលាត(Joliet)អ៊ីលីណ័យ (Illinois) និងអ្នកមានជំងឺដុះសាច់។ ត្រូវហើយ។ អ្នកប្រហែលជាឆ្ងល់...(បាទនោះ

ជា—ស្ត្រីរ៉ូសេឡានាំមក។ ត្រូវហើយ។ រង់ចាំបន្តិចនាងប្រាប់ខ្ញុំពីវា ប៉ុន្តែនាងមិនស្គាល់ ខ្ញុំក៏មិនស្គាល់គាត់ដែរ។ នោះត្រូវហើយ។ កើតមានជាស្ត្រីមានជំនឿយ៉ាងធំ) ខ្ញុំនឹងប្រាប់អ្នករឿងមួយអ្នក-អ្នកដឹងថា ខ្ញុំមិនដឹងទេ។ អ្នកអធិស្ឋានឲ្យក្មេងដែលកំពុងអង្គុយទីនេះនៅខាងចុង គាត់ឈឺ។ ជាកូនរបស់អ្នក។ ត្រូវហើយ។ អាម៉ែន។ អ្នកដឹងថាខ្ញុំមិនដឹងទេ។

195 វាគឺបែបនោះ វាជាព្រះវិញ្ញាណបរិសុទ្ធ! អ្នកជឿទេ? អ្នកទទួលវាទេ? ដូច្នេះបើវាត្រូវ ខ្ញុំនិយាយពី "ឯទ្វារដែលនាំទៅឯជីវិតនោះតូចហើយចង្អៀតវិញ" គឺត្រឹមត្រូវ។ ព្រះយេស៊ូវគ្រីស្ទ ព្រះបុត្រារបស់ព្រះ គង់នៅទីនេះឥឡូវ។ វិញ្ញាណនៃ ព្រះដែលមានព្រះជន្មរស់គង់នៅទីនេះ។ អ្នកជឿទេ? ដូច្នេះ ដើម្បីឲ្យអ្នកដឹងថាខ្ញុំមិនមែនជាអ្នកដែលព្យាបាល មិនមែនជាអ្នកព្យាបាលទេ ប៉ុន្តែព្រះវិញ្ញាណនៃព្រះ ដែលបានជ្រើសរើសខ្ញុំដើម្បីបង្ហាញព្រះអង្គទ្រង់ផ្ទាល់។ ខ្ញុំមិនមានការអប់រំ។ ខ្ញុំមិនមានចំណេះដឹងអ្វី។ ប៉ុន្តែ ជាព្រះវិញ្ញាណទ្រង់ដែលធ្វើឡើង អ្នកឃើញ និងទ្រង់ចង់ឲ្យអ្នកបានស្គាល់អ្វីដែលខ្ញុំបានប្រាប់អ្នកពីសេចក្តីពិត។

196 នេះជាសេចក្តីពិត នោះជាព្រះយេស៊ូវដែលធ្វើឲ្យអ្នកគ្រប់គ្នាបានប្រសើរឥឡូវបើអ្នកជឿ។ ឥឡូវសូម...បើវាមាននៅក្នុងឃីនស្តុន(Kingston) ដែលជាកន្លែងមានបេសកជនជាច្រើន ឬនរណាក៏ដោយនៅទីនោះ បានឃើញការនោះកើតឡើង មានមនុស្សរាប់ពាន់អ្នកបានជា ហេតុអ្វីមិនអាចកើតនៅទីនេះបាននោះជា អាមេរិកាំង ដែលយើងមានរបៀបនោះដែរ? ហេតុអ្វីយើងមិនអាចជឿបាននោះ? ព្រោះយើងមិនអាចឆ្លងកាត់ត្រើយខាងភ្លើងតូចបានទេ។ តើអ្នកជឿទេ? សូមលើកដៃ?

197 ឥឡូវ ដៃដូចគ្នានេះ ដាក់លើនរណាម្នាក់ក្បែរអ្នក ចូរឲ្យខ្ញុំអធិស្ឋានសម្រាប់គាត់ពីទីនេះ និងកុំឲ្យអ្នកមានការសង្ស័យក្នុងចិត្តទេ វានឹងបញ្ចប់។

198 អូ បងប្អូនប្រុសរបស់ខ្ញុំអើយនេវីល(Nerville)! តើខ្ញុំប៉ងប្រាថ្នាយ៉ាងម៉េច តើខ្ញុំអធិស្ឋានយ៉ាងណា យ៉ាងណាខ្ញុំ...អ្នកប្រហែលគិតថាខ្ញុំនៅខាងខ្លួនឯង ខ្ញុំមិនមែនឡើយ។ ខ្ញុំដឹងថាខ្ញុំនៅឯណា។ បើខ្ញុំអាចត្រឹមផ្តល់អ្វីតូចមួយនេះដល់អ្នក! តើអ្នកទទួលស្គាល់ទេថាព្រះយេស៊ូវគ្រីស្ទ ព្រះបុត្រារបស់ព្រះ គង់នៅកណ្តាលចំណោមមនុស្សនៅព្រឹកនេះ ឥឡូវ បច្ចុប្បន្ននេះ បង្ហាញអង្គទ្រង់?

ល្អ អ្នកនិយាយ "បងប្អូនប្រុសប្រានហាំ *អ្នក* និយាយនោះ។"

199 តើខ្ញុំនិយាយយ៉ាងម៉េច? ខ្ញុំមិនស្គាល់អ្នក។ មានស្ត្រីផ្សេងទៀតមានជំងឺរបេង។ អ្នកបានជាហើយបងប្អូនស្រី។ ព្រះប្រទានពរ។ ខ្ញុំអង្វរសូមអត់ទោសអ្នកអធិស្ឋានសម្រាប់ស្ត្រីមានជំងឺរបេង ព្រោះជាស្ត្រីមានសក់ពណ៌ប្រផេះ។ បាទត្រូវហើយ ជឿចុះ។ ត្រូវហើយ។ ទ្រង់គង់នៅទីនេះ។ វាជាព្រះវត្តមានទ្រង់។

200 ឥឡូវ នេះជាអ្វីដែលទ្រង់មានបន្ទូល "ទីសំគាល់ទាំងនេះនឹងជាប់តាមអស់អ្នកដែលជឿ។ គេនឹងដាក់ដៃលើមនុស្សជំងឺឲ្យបានជាផង"។ តើទ្រង់អាចកុហកម្តេចបាន? មើល វាមិនមែនលើទ្រង់ឡើយ មិនមែនខ្ញុំផង ឥឡូវ វានៅលើអ្នកវិញ។ ឥឡូវ អ្នកជឿ។

201 ខ្ញុំកំពុងស្វែងរកស្ត្រីតូចមួយអង្គុយនៅខាងក្រោយទីនោះ នាងមានជំនឿច្រើនណាស់។ នាងនិងប្តីរបស់អ្នកទើបតែចូលមកព្រះអម្ចាស់។ នាងអង្គុយនៅក្នុងការប្រជុំនេះ មានស្នាមវះដែលដុកទ័រទើបតែវះកាត់លើនាងពីមុន ហើយកូនរបស់នាងដល់ពេលជិតកើតហើយ។ ហើយដុកទ័រនឹងវះកាត់បន្ទាប់ពីនោះ ប៉ុន្តែកូនក៏កើតមកហើយពួកគេមិនអាចរកឃើញជំងឺក្លនទៀតឡើយ។ វាបាត់ហើយ។ ឃើញ? ហេតុអ្វី? នាងត្រឹមតែរៀបចំដូច...នាងមិនដែលឡើងមក ទីនេះ នៅវេទិការបែបនោះឡើយ។ នាងត្រឹមតែអង្គុយនៅខាងក្រោយហើយជឿ។ នោះគឺត្រូវហើយលោកស្រីហ្គ្រីន(Green) ខ្ញុំជឿវា កាលនោះ? ត្រូវហើយ។ ឃើញដៃរបស់នាងទេ? ដុកទ័រមិនអាចរកឃើញស្នាមវះផង វាបាត់អស់ហើយ។ ហេតុអ្វី? នាងជឿ គ្រាន់តែបោះជំហានទៅ ហើយនិយាយ "វាត្រូវហើយ!"

202 ឥឡូវ អ្នកធ្វើដូចគ្នា និងរាល់ទុក្ខវេទនាអ្នកនឹងមានឆន្ទះដើម្បីចេញទៅ។ ព្រះជាអង្គអាច—អង្គអាចបញ្ជូនអ្វីមួយចូលទៅក្នុងរាងកាយមនុស្សបាន ចូលក្នុងពស់នោះដែលអាចចឹកចំជើងមនុស្ស បាញ់ពិស ដើម្បីសម្លាប់គាត់ ហើយអាចបញ្ឈប់វា និងសម្លាប់វានៅត្រង់នោះ តើទ្រង់អាចសម្លាប់ជំងឺក្នុងរាងកាយអ្នកជាងយ៉ាងណាទៅទៀត។ ព្រោះនោះជាមនុស្សរងសម្ពាធហើយគាត់ត្រូវតែមានជំនួយ។ អ្នកត្រូវតែមានផងដែរ។ បើអ្នកមិនមានអ្នកនឹងស្លាប់។

203 ឥឡូវ រក្សាដៃអ្នកនៅលើគ្នាទៅវិញទៅមក។ តើអ្នកមិនមែនអធិស្ឋានសម្រាប់ខ្លួនឯងទេរីចូរអធិស្ឋានសម្រាប់មនុស្សនៅក្បែរអ្នក។ គ្រីស្ទានត្រូវធ្វើដូចនោះហ្វៀ។

204 រៀនពីការនេះ រៀនពីការនេះ នោះ ពេលអ្នកធ្វើសម្រាប់គ្នា អ្នកក៏ធ្វើសម្រាប់ព្រះគ្រីស្ទដែរ។ ពេលអ្នកធ្វើល្អជាមួយនរណាម្នាក់ អ្នកល្អជាមួយព្រះគ្រីស្ទហើយ។ បើអ្នកធ្វើមិនល្អដាក់នរណាម្នាក់ អ្នកធ្វើមិនល្អដាក់ព្រះគ្រីស្ទដែរ។ អូ ខ្ញុំអើយ!

205 អូ បើខ្ញុំមានត្រឹមតែធ្វើឲ្យវារំលងទៅ បើខ្ញុំត្រឹមតែឲ្យមនុស្សបានឃើញ អ្វីដែលខ្ញុំកំពុងមើល និងអ្វីដែលខ្ញុំមានអារម្មណ៍ និងអ្វីដែលខ្ញុំស្គាល់ថាកើតឡើង មើល។ តើព្រះគ្រីស្ទនឹងរុញចូលមក បន្ទាប់ពីសារនោះនៅព្រឹកនេះយ៉ាងណា ដើម្បីចូលក្នុងចិត្តមនុស្សនិងបង្កើតអ្វីមួយនៅទីនោះ។ មិនមែនជាការភ្ញាក់ផ្អើល មិនមែនជាអារម្មណ៍(វាបានមកជាមួយវា) ប៉ុន្តែជាការបង្កើតជំនឿមិនចេះស្លាប់ទីនោះដែលមិនអាចនិយាយបាន ផ្ដល់រង្វាស់មួយអិញដល់ខ្មាំងសត្រូវឡើយ។

206 ឥឡូវ ទ្រង់ឮសេចក្ដីអធិស្ឋានរបស់ខ្ញុំ ទ្រង់នឹងឮសេចក្ដីអធិស្ឋានរបស់អ្នក។ អ្នកអធិស្ឋានសម្រាប់គ្នាឥឡូវ កាលបើខ្ញុំអធិស្ឋានសម្រាប់អ្នកទាំងអស់គ្នា។

207 អូ ព្រះអម្ចាស់ ឱកាសសំខាន់នេះ ទូលបង្គំដឹងថានេះមានន័យខុសគ្នារវាងសេចក្ដីស្លាប់និងជីវិត ចំពោះមនុស្សជាច្រើន។ ហើយទូលបង្គំញាប់ញ័រក្នុងព្រះវត្តមានទ្រង់ ព្រោះទូលបង្គំដឹង ព្រះអម្ចាស់ជាព្រះ នោះទូលបង្គំត្រូវតែអធិស្ឋានចេញពីចិត្ត។ ទូលបង្គំដឹងថាទោះបីជាមិនមានអ្នកជំងឺ ក្នុងចំណោមពួកទូលបង្គំក្នុងប្រាំនាទីទៀតក្ដី នោះមនុស្សគ្រប់គ្នានៅទីនេះនឹងស្គាល់ថា ទ្រង់គង់នៅទីនេះ។ ទីនេះពួកគេឈរនៅព្រឹកនេះ ព្រះអម្ចាស់។ ចូរឲ្យពួកគេលើកដៃឡើងជាអ្នកដែលដឹងថាទូលបង្គំមិនស្គាល់ពួកគេ និងមិនស្គាល់អ្វីពីពួកគេ។ ប៉ុន្តែព្រះវិញ្ញាណទ្រង់អាចស្គាល់ពួកគេ។ ទ្រង់ជ្រាបអាថ៌កំបាំងក្នុងចិត្តរបស់ពួកគេ តើទ្រង់នឹងស្គាល់សេចក្ដីលំបាកនិងការឈឺចាប់របស់គេជាងយ៉ាងណាទៅទៀត! ដូច្នេះ ព្រះអម្ចាស់ សូមឲ្យថ្ងៃនេះ សូមឲ្យឥឡូវនេះព្រះវិញ្ញាណ ទ្រង់នឹងពាល់រាងកាយអ្នកជំងឺទាំងនេះ។ សូមទទួល ព្រះអម្ចាស់។ ពួកគេកំពុងអធិស្ឋានសម្រាប់ គ្នាទៅវិញទៅមក។

208 ហើយទូលបង្គំអធិស្ឋាន ព្រះជាទីស្រឡាញ់ ដែលព្រះវិញ្ញាណបរិសុទ្ធនឹងធ្វើឲ្យក្លាយជាការពិតដល់ពួកគេ ដែលពួកគេនឹងមិនស្ដាប់បង្គាប់ទៀតឡើយ។ ហើយមានជំងឺមួយទៀត ព្រះអម្ចាស់អើយ។ ដែលឆ្ងាយជាងនិងធំជាងជំងឺសាច់ឈាម នេះណាស់ គឺជំងឺខាងវិញ្ញាណ។ សូមឲ្យចិត្តទាំងអស់បានបើកឡើង។

209 ព្រះអម្ចាស់ ដែលទ្រង់អាចឈរជិតអ័ប្រាហាំយ៉ាងនោះបែបណា និងសម្តែងការនេះដូចគ្នា ប្រាប់សារ៉ាដែល "នៅពីក្រោយ"ទ្រង់ ខគម្ពីរនិយាយថា "នាងសើចនៅក្នុងតង់ជំរុំ" ហើយទ្រង់ប្រាប់ដល់នាង។ ហើយអ័ប្រាហាំស្គាល់ថានោះជាព្រះអេឡូហ៊ីម ជាព្រះដ៏ធំ។ បីប្អូននាទីទ្រង់ក៏រលាយបាត់ពីភ្នែកគាត់ទៅ។

210 ហើយព្រះអម្ចាស់ ពេលព្រះ យេស៊ូវក្រោកឈរឡើងនិងធ្វើការដូចគ្នា និងមានបន្ទូលថា "អ្នកហៅអ័ប្រាហាំថាជា 'ឪពុក' ហើយអ្នកនៅនិយាយថាមិនស្គាល់បទគម្ពីរឡើយ" មានបន្ទូល "នោះព្រះយេស៊ូវទ្រង់មានព្រះបន្ទូលទៅគេថា អ្នករាល់គ្នាភាន់ច្រឡំទេ ពីព្រោះមិនយល់គម្ពីរ ឬព្រះចេស្តានៃព្រះសោះ" និងគេហៅទ្រង់ថាជា "បៀសេបាប់"។

211 ប៉ុន្តែទ្រង់សន្យាថានៅថ្ងៃ ចុងក្រោយនោះទ្រង់ នឹងចាក់ព្រះវិញ្ញាណទ្រង់ម្តងទៀត។ ហោរ៉ាបាននិយាយថា "ប៉ុន្តែលុះដល់ពេលព្រលប់ នោះនឹងមានពន្លឺវិញ" ហើយយើងនៅទីនេះ។

212 ពេលភាពមិនស្របច្បាប់នៃលោកកិយ៍នេះដួលរលំក្រោមបាប ដូចជាមនុស្សស្រវឹងដែលទ្រេតទ្រោតនៅពេលយប់ មិនយូទេនាងនឹងផ្ទុះខ្យល់នៅពេលកណ្តាលយប់ មិនទាំងមានកំទិចភ្នំភ្លើងផង ពិបាក ចេញមក។ និងយើងឃើញពេលវេលាបានគោះចេញទៅ។

213 អូ ព្រះអង្គអើយ សូមយកការសង្ស័យចេញពីទូលបង្គំ។ សូមនាំទូលបង្គំទៅក្នុងរង្វង់នោះឥឡូវ។ សូមយាងមកព្រះវិញ្ញាណបរិសុទ្ធ។ សូមទប់ស្លាបដ៏ធំរបស់ទ្រង់ សូមជញ្ជឹងគិតក្នុងចំណោមអ្នកចូលរួមតូចនេះ និងសូមឲ្យទ្រង់ផ្ទាល់បានជ្រមុជជោគជាំក្នុងចិត្តរបស់ពួកគេ និងសូមឲ្យពួកគេដឹងថាទ្រង់នៅក្នុងព្រះវត្តមានរបស់ព្រះដែលជាទ្រង់"យើងជាព្រះអម្ចាស់ដែលប្រោសអ្នកឲ្យបានជា"។ហើយ សូមឲ្យព្រះវត្តមានទ្រង់ធ្វើអ្វីចំពោះចិត្តរបស់ពួកគេដែលនឹងនាំ ឲ្យពួកគេចេញទៅចាប់ពីត្រង់នេះ ព្រឹកនេះ ជឿអ្វីដែលនៅក្នុងពួកគេ។ និងសូមឲ្យអ្នកជំងឺទាំងអស់និងអ្នកទុក្ខលំបាកបានជា។

214 ក្នុងនាមជាអ្នកបម្រើទ្រង់ ទូលបង្គំឈរនិងថ្កោលទោសរាល់អារក្ស ថ្កោលទោសរាល់ជំងឺ ថ្កោលទោសរាល់សាតាំង។

215 អ្នកបានវង្វេង អ្នកមិនមែនជាអ្វីក្រៅតែពីសេចក្តីអាក្រក់។ និងយើងបានហៅដៃរបស់អ្នកនៅព្រឹកនេះ ក្នុងព្រះនាមព្រះយេស៊ូវគ្រីស្ទ។ និងភាពជាអ្នកបម្រើទ្រង់ ការអធិប្បាយព្រះបន្ទូលទ្រង់និងប្រាប់មនុស្សពីសេចក្តីពិត ដើម្បីឲ្យមានភាពត្រឹមត្រូវនិងត្រូវខ្សែបន្ទាត់ជាមួយព្រះបន្ទូលព្រះ ខ្ញុំថ្កោលទោសអ្នក សាតាំង ក្នុងព្រះនាមព្រះយេស៊ូវគ្រីស្ទ។ ត្រូវចេញពីមនុស្សម្នាក់ៗគ្រប់គ្នានៅទីនេះទាំងអ្នកមកពីឆ្ងាយនិងជិតក្តី ឲ្យគេបានជា។ អ្នកត្រូវចេញពីអ្នកចូលរួមនិងពីមនុស្សនេះ។ យើងបង្គាប់ឯងដោយព្រះដ៏មានព្រះជន្ម។ និងព្រះគម្ពីរនិយាយ "នោះពាក្យអធិស្ឋាននៃសេចក្តីជំនឿ នឹងជួយសង្គ្រោះដល់មនុស្សឈឺនោះ ហើយព្រះអម្ចាស់ទ្រង់នឹងប្រោសឲ្យគាត់បានជាឡើង បើគាត់បានធ្វើបាបអ្វី នោះនឹងបានអត់ទោសឲ្យផង។" ហើយមានមនុស្សសុចរិតជាច្រើនបានដាក់ដៃលើអ្នកជំងឺព្រឹកនេះនៅទីនេះ។ អូសាតាំង ឯងព្យាយាមធ្វើឲ្យពួកគេគិតថា វាគឺដោយសារយើង រួចអ្នកយកសិរីរុងរឿងពីគេ។ ប៉ុន្តែវាជាជំនឿនៅក្នុងព្រះ ដែលពួកគេជឿព្រះ។ និងឯងត្រូវតែចេញ ដោយជំនឿរបស់ពួកគេ។ ដូច្នេះធ្វើដំណើរចេញពីទីនេះ និងទៅកន្លែងងងឹតខាងក្រៅដែលជាកន្លែងសម្រាប់ឯង។ យើងកាត់ទោសឯង ក្នុងព្រះនាមព្រះយេស៊ូវគ្រីស្ទ ដោយអំណាចព្រះគម្ពីររបស់ព្រះ បេសកកម្មរបស់ខ្ញុំដោយទេវតា។ ឥឡូវ ត្រូវតែចេញក្នុងព្រះនាមព្រះយេស៊ូវគ្រីស្ទ និងចូរឲ្យពួកគេមានសេរីភាព។ អាម៉ែន។

216 តើអ្នកជឿទេ អស់ពីចិត្តអ្នក ដែលអ្នកនឹងជា? លើកដៃរបស់អ្នក និយាយ "ឥឡូវខ្ញុំទទួលព្រះគ្រីស្ទជាព្រះប្រោសឲ្យជា។ ស្រមោលទាំងអស់បានរលាយទៅពីខ្ញុំ។ ខ្ញុំទទួលទ្រង់ក្នុងភាពពេញលេញនៃអំណាចរបស់ទ្រង់ ក្នុងភាពជាព្រះពរនៃព្រះវត្តមានទ្រង់។ ខ្ញុំទទួលទ្រង់"។

ជំនឿខ្ញុំ មើលទៅទ្រង់
ជាចៀមនៃកាល់វ៉ារី
អង្គសង្គ្រោះ
ឥឡូវទ្រង់ឮ ពេលខ្ញុំអធិស្ឋាន
សូមដកយកបាបខ្ញុំចេញ
ហើយកុំឱ្យខ្ញុំវង្វេង
ចេញពីទ្រង់ឡើយ។

ឥឡូវសូមលើកដៃរបស់អ្នកជាភាពរួសរាយទៅកាន់ទ្រង់ឥឡូវ ពេលផ្លូវជីវិតងងឹតខ្វាត់ខ្វែងដែលខ្ញុំដើរ

ពេលជីវិតងងឹតសង្កត់ខ្ញុំ
មានទុក្ខព្រួយនៅជុំវិញ
ទ្រង់ធ្វើជាអ្នកនាំផ្លូវ ឱព្រះអង្គអើយ
ដេញងងឹតទៅជាពន្លឺថ្ងៃនេះ
កំចាត់ទុក្ខព្រួយឱ្យឆ្ងាយ
កុំឱ្យខ្ញុំវង្វេង
ចេញពីទ្រង់ឡើយ។

[បងប្អូនប្រុសប្រានហាំចាប់ផ្ដើមគ្រហឹមច្រៀង *ជំនឿ របស់ខ្ញុំ សម្លឹងមើលទៅកាន់ទ្រង់*—Ed។] ...ព្រះគុណបរិបូរណ៍!

**ទ្វារដែលនាំទៅឯជីវិត** KHM59-0301M

(Strait Is The Gate)

**តំណាមេរៀនអំពីក្រុមជំនុំ**

សារដែលធ្វើឡើងដោយបងប្រុសWilliam Marrion Branham នេះ ត្រូវបានចែកចាយនៅព្រឹកថ្ងៃអាទិត្យ ថ្ងៃទី 01 មិនា 1959 នៅរោងឧបោសថ Branham, Jeffersonville, Indiana, U.S.A.។ រាល់ការខិតខំត្រូវបានធ្វើឡើងដោយការផ្ទៀងផ្ទាត់យ៉ាងត្រឹមត្រូវ ជាសារសម្លេងចេញពីខ្សែរអាត់ថតចម្លង និង បោះពុម្ពដោយរក្សាសិទ្ធពីភាសារអង់គ្លេស។ ការបក ប្រែជាភាសារខ្មែរនេះ គឺត្រូវបោះពុម្ព និង ចែកចាយដោយ សម្លេងព្រះជាម្ចាស់ដែលបានថតទុក ។

KHMER

©2019 VGR, ALL RIGHTS RESERVED

VOICE OF GOD RECORDINGS
P.O. BOX 950, JEFFERSONVILLE, INDIANA 47131 U.S.A.
www.branham.org

## ការរក្សាសិទ្ធ

សៀវភៅនេះត្រូវបានរក្សាសិទ្ធ។ សៀវភៅនេះអាចថតចម្លង បានជាការប្រើប្រាស់ផ្ទាល់ខ្លួន ដោយសេរី ឥតគិតថ្លៃ ដើម្បីផ្សព្វផ្សាយដំណឹងល្អអំពីព្រះយេស៊ូគ្រិស្ត។ សៀវភៅនេះ មិនអាចលក់ ផលិតជាទ្រង់ទ្រាយធំ យកទៅដាក់ក្នុងវែបសាយ លក់តាមប្រព័ន្ធអេលេចត្រូនីក ឬ បកប្រែ ដោយគ្មានការអនុញ្ញាតិពី វ៉យ អូហ្វ ហ្គត់ រីខខតឌីង (VOICE OF GOD RECORDINGS®.)ឡើយ។

សម្រាប់ទំនាក់ទំនងបន្ថែម និង ឬសម្រាប់តម្រូវការទាក់ទងនឹងឯកសារសូមទំនាក់ទំនង៖

វ៉យស៍ អូហ្វ ហ្គត់ រីខខតឌីង (VOICE OF GOD RECORDINGS)

P.O. BOX 950, JEFFERSONVILLE, INDIANA 47131 U.S.A.

WWW.BRANHAM.ORG